សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## សារណាបញ្ចប់ការសិក្សា

# ការលើកកម្ពស់សេដ្ឋកិច្ចគ្រួសារតាមរយៈ ការអប់រំរបស់ស្ត្រី

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


តាក់តែងឡើងដោយ
និស្សិតឈ្មោះ **ទី មាឌធន់**
**ឈិន ស្រីនិច**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **ឈុន ពហុ**


ថ្នាក់បរិញ្ញាបត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍
ជំនាន់ទី ៤

ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីរនាក់ ទី មារទង់ និង ឈិន ស្រីនិច ជានិស្សិតឆ្នាំទី៤ ជំនាន់ទី៤ នៃថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖**

អ្នកមានគុណទាំងពីរ ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាយើងខ្ញុំទាំងពីរនាក់ តាំងពីតូចរហូតដល់ធំ។ លោកទាំងពីរបានខិតខំប្រឹងប្រែងប្រកបរបររកស៊ី ដើម្បីផ្គត់ផ្គង់ឲ្យកូនៗបានសិក្សារៀនសូត្រ ដោយមិនគិតពីការលំបាកនានា ព្រមទាំងផ្តល់នូវការទូន្មានប្រៀនប្រដៅល្អៗ ដើម្បីឲ្យយើងខ្ញុំក្លាយទៅជាធនធានមនុស្សសម្រាប់ជួយដល់សង្គម។

ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យទាំងអស់ដែលបានយកចិត្តទុកដាក់បង្រៀន និងផ្តល់ចំណេះដឹងថ្មីៗ ក៏ដូចជាចែករំលែកនូវបទពិសោធន៍នានាដល់យើងខ្ញុំ ដើម្បីយកទៅអនុវត្តនិងអភិវឌ្ឍប្រទេសឲ្យកាន់តែរីកចម្រើនឡើង។

លោកសាស្ត្រាចារ្យ ឈុន ពហុ ដែលតែងតែចំណាយពេលវេលាដ៏មានតម្លៃរបស់លោកដើម្បីជួយណែនាំនិងផ្តល់ជាគំនិតល្អៗជាច្រើនដល់យើងខ្ញុំ ក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះបានដោយជោគជ័យ និងទុកជាឯកសារសម្រាប់សិស្សានុសិស្សជំនាន់ក្រោយសិក្សារៀនសូត្របន្ថែម។

មិត្តភក្តិរបស់យើងខ្ញុំដែលតែងតែលើកទឹកចិត្ត ព្រមទាំងផ្តល់នូវយោបល់ល្អៗយ៉ាងច្រើន ដើម្បីឲ្យយើងខ្ញុំទាំងពីរនាក់បញ្ចប់សារណានេះទៅបានយ៉ាងរលូន។

ជាចុងក្រោយ យើងខ្ញុំក៏សូមអរគុណដល់ស្ត្រីដែលបម្រើការងារនៅក្នុងរាជធានីភ្នំពេញដែលពួកគាត់បានចំណាយពេលវេលាដើម្បីបំពេញនូវកម្រងសំណួរសម្រង់មតិរបស់យើងខ្ញុំផងដែរ៕

# អារម្ភកថា

ការអប់រំគឺជាកត្តាដ៏សំខាន់មួយដែលមនុស្សម្នាក់ៗនៅក្នុងសង្គមមិនអាចខ្វះបាន ព្រោះវាគឺជាដំណើរការដែលអាចនាំយើងទៅរកភាពជោគជ័យនៅក្នុងជីវិត។ កាលណាយើងមានការអប់រំខ្ពស់ នោះយើងនឹងមានការងារល្អធ្វើ មានប្រាក់ខែខ្ពស់ មានគេស្រឡាញ់រាប់អានច្រើន។ ដូច្នេះហើយទើបមនុស្សគ្រប់គ្នា តែងតែប្រាថ្នាចង់ក្រេបជញ្ជក់យកចំណេះវិជ្ជាមកដាក់ក្នុងខ្លួនឲ្យបានច្រើន ដើម្បីរស់នៅក្នុងសង្គមប្រកបដោយភាពសុខដុមរមនា។

មនុស្សគ្រប់រូបមានសិទ្ធិទទួលបានការអប់រំ ជាពិសេសស្ត្រីព្រោះពួកគាត់ចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍប្រទេសឲ្យរីកចម្រើនទៅមុខ ដូចពាក្យចាស់លោកពោលថា "ស្ត្រីជាមាតាពិភពលោក"។ កាលណាស្ត្រីមានចំណេះវិជ្ជា ពួកគាត់នឹងយល់ដឹងបានច្រើនទាក់ទងនឹងបញ្ហានានា ដូចជា បញ្ហាសុខភាពគាត់និងកូន បញ្ហាសេដ្ឋកិច្ច បញ្ហានយោបាយជាដើម។ យ៉ាងណាមិញ ប្រជាជននៅប្រទេសកម្ពុជាយើង តាំងពីសម័យបុរាណមកហាក់មិនសូវឲ្យតម្លៃលើការអប់រំរបស់ស្ត្រីទេ ដោយពួកគាត់ជឿថា "ស្ត្រីបង្វិលចង្ក្រានមិនជុំ" ដូច្នេះហើយ ឪពុកម្តាយភាគច្រើនមិនអនុញ្ញាតឲ្យកូនស្ត្រីរបស់ពួកគាត់ចូលសាលារៀន ដើម្បីក្រេបជញ្ជក់យកចំណេះវិជ្ជាទេ ទើបធ្វើឲ្យស្ត្រីមិនមានលទ្ធភាពជួយផ្គត់ផ្គង់ជីវភាពគ្រួសារបាន។ ដោយយល់ឃើញពីបញ្ហានេះហើយ ទើបជំរុញឲ្យក្រុមរបស់នាងខ្ញុំជ្រើសរើសយកប្រធានបទ **ការលើកកម្ពស់សេដ្ឋកិច្ចគ្រួសារតាមរយៈការអប់រំរបស់ស្ត្រី** យកមកធ្វើការសិក្សាស្រាវជ្រាវ ក្នុងគោលបំណងស្វែងយល់ពីភាពខុសគ្នារវាងស្ត្រីដែលទទួលបានការអប់រំច្រើននិងស្ត្រីដែលទទួលបានការអប់រំតិច ឬមិនដែលទទួលបានការអប់រំទាល់តែសោះ ព្រមទាំងអត្ថប្រយោជន៍ដែលសង្គម ក៏ដូចជាគ្រួសាររបស់ស្ត្រីផ្ទាល់ ទទួលបាននៅពេលដែលពួកគាត់ផ្តល់ឱកាសឲ្យស្ត្រីទទួលបានការអប់រំ។

យើងខ្ញុំសង្ឃឹមថាសៀវភៅមួយក្បាលនេះ នឹងអាចជួយជាប្រយោជន៍ដល់សិស្សានុសិស្សជំនាន់ក្រោយដែលធ្វើការស្រាវជ្រាវទាក់ទងនឹងប្រធានបទនេះ។ យើងខ្ញុំសូមអភ័យទោសនូវរាល់កំហុសខុសឆ្គងទាំងឡាយដែលកើតមានឡើងនៅក្នុងសៀវភៅមួយនេះ ហើយយើងខ្ញុំក៏រីករាយនឹងទទួលនូវមតិរិះគន់ដើម្បីស្ថាបនាពីមិត្តអ្នកអានផងដែរ។ ជាចុងក្រោយ យើងខ្ញុំសូមប្រសិទ្ធពរឲ្យអ្នកទាំងអស់គ្នាជួបតែពុទ្ធពរទាំងបួនប្រការគឺអាយុះ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕

# មាតិកា

**ទំព័រ**


បញ្ជីតារាង ........ iv

## សេចក្តីផ្តើម

១. លំនាំបញ្ហា ........ ១

២. ចំណោទបញ្ហា ........ ២

៣. គោលបំណងនៃការស្រាវជ្រាវ ........ ២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ២

៥. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៣

៦. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៤

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤

## ជំពូកទី១ រំលឹកទ្រឹស្តីពាក់ព័ន្ធ

១.១. និយមន័យ ........ ៥

១.១.១. ការអប់រំ ........ ៥

១.១.២. ស្ត្រី ........ ៥

១.១.៣. សេដ្ឋកិច្ចគ្រួសារ ........ ៦

១.២. ប្រវត្តិនៃការអប់រំ ........ ៦

១.២.១. ការអប់រំនៅសម័យអាណានិគមបារាំង (១៨៦៣ ដល់ ១៩៥៣) ........ ៦

១.២.២. ការអប់រំនៅសម័យសង្គមរាស្ត្រនិយម (១៩៥៣ ដល់ ១៩៧០) ........ ៧

១.២.៣. ការអប់រំនៅសម័យសាធារណៈរដ្ឋខ្មែរ (១៩៧០ ដល់ ១៩៧៥) ........ ៨

១.២.៤. ការអប់រំនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ ដល់ ១៩៧៩) ........ ៩

១.២.៥. ការអប់រំនៅក្នុងសម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩ ដល់ ១៩៨៩) ........ ១០

១.២.៦. ការអប់រំនៅក្នុងសម័យរដ្ឋកម្ពុជា (១៩៨៩ ដល់ ១៩៩៣) ........ ១១

១.២.៧. ការអប់រំនៅក្នុងបច្ចុប្បន្ន (១៩៩៣ ដល់ បច្ចុប្បន្ន) ........ ១២

១.៣. រចនាសម្ព័ន្ធនៃប្រព័ន្ធអប់រំរបស់ប្រទេសកម្ពុជា ........ ១៤

១.៣.១. ការអប់រំកម្រិតមត្តេយ្យសិក្សា ........ ១៤

១.៣.២. ការអប់រំនៅកម្រិតបឋមសិក្សា ........ ១៦

១.៣.៣. ការអប់រំនៅកម្រិតអនុវិទ្យាល័យ......១៧
១.៣.៤. ការអប់រំនៅកម្រិតវិទ្យាល័យ......១៩
១.៣.៥. ការអប់រំកម្រិតឧត្តមសិក្សា......២១
១.៤. ស្ថានភាពទូទៅនៃស្ត្រីក្នុងសង្គមខ្មែរ......២២
១.៤.១. ស្ត្រី និងការអប់រំ......២២
១.៤.២. ស្ត្រី និងសេដ្ឋកិច្ចគ្រួសារ......២៣
១.៤.៣. ស្ត្រី និងសេដ្ឋកិច្ច......២៤
១.៤.៤. ស្ត្រី និងការចូលរួមក្នុងសង្គម......២៤
១.៥. គោលនយោបាយក្នុងការអប់រំស្ត្រី......២៥
១.៥.១. គោលនយោបាយក្នុងការអប់រំស្ត្រីរបស់ធនាគារពិភពលោក......២៥
១.៥.២. គោលនយោបាយពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គម......២៧

**ជំពូកទី២ ស្ថានភាពទូទៅរបស់ស្ត្រីបម្រើការងារនៅក្នុងរាជធានីភ្នំពេញ**

២.១. ការអប់រំ និង មុខតំណែងរបស់ស្ត្រីបម្រើការងារនៅតាមស្ថាប័នក្នុងរាជធានីភ្នំពេញ......២៩
២.១.១. ការអប់រំរបស់ស្ត្រីបម្រើការងារនៅតាមស្ថាប័នក្នុងរាជធានីភ្នំពេញ......៣០
២.១.២. កត្តាដែលជំរុញឲ្យស្ត្រីទទួលបានមុខតំណែងនេះ......៣០
២.១.៣. បញ្ហាប្រឈមនៃការទទួលបានមុខតំណែងនេះ......៣១
២.១.៤. ជីវភាពគ្រួសាររបស់ស្ត្រីបម្រើការងារនៅតាមស្ថាប័នក្នុងរាជធានីភ្នំពេញ......៣១
២.២. ការអប់រំ និង មុខតំណែងរបស់ស្ត្រីបម្រើការងារក្នុងរោងចក្រកាត់ដេរ......៣២
២.២.១. ការអប់រំរបស់ស្ត្រីបម្រើការងារក្នុងរោងចក្រកាត់ដេរ......៣២
២.២.២. កត្តាដែលជំរុញឲ្យស្ត្រីទទួលបានមុខតំណែងនេះ......៣៣
២.២.៣. បញ្ហាប្រឈមនៃការទទួលបានមុខតំណែងនេះ......៣៣
២.២.៤. ជីវភាពគ្រួសាររបស់ស្ត្រីបម្រើការងារក្នុងរោងចក្រកាត់ដេរ......៣៤
២.៣. ការលើកទឹកចិត្តឲ្យស្ត្រីទទួលបានការអប់រំ......៣៥
២.៣.១. ស្ត្រីខ្លួនឯងផ្ទាល់......៣៥
២.៣.២. គ្រួសាររបស់ស្ត្រី......៣៥
២.៣.៣. សង្គម......៣៥
២.៣.៤. រាជរដ្ឋាភិបាល......៣៦

## ជំពូកទី៣ ការវិភាគលើលទ្ធផលស្រាវជ្រាវ


៣.១. ការវិភាគតាមបែបពិពណ៌នា ............ ៣៧

៣.១.១. ស្ថានភាពទូទៅនៃស្ត្រីបម្រើការងារនៅតាមស្ថាប័ននានា និងនៅក្នុងរោងចក្រកាត់ដេរនៅរាជធានីភ្នំពេញ ............ ៣៧

៣.១.១.១. អាយុ ............ ៣៧

៣.១.១.២. ស្ថានភាពគ្រួសារ ............ ៣៨

៣.១.១.៣. សមាជិកគ្រួសារ ............ ៣៩

៣.១.១.៤. កម្រិតនៃការសិក្សា ............ ៤០

៣.១.១.៥. មុខរបរនិងមុខតំណែងរបស់ស្ត្រី ............ ៤១

៣.១.២. កម្រិតនៃប្រាក់ចំណូលជាមធ្យម ............ ៤២

៣.១.៣. សារៈសំខាន់នៃការអប់រំរបស់ស្ត្រី ............ ៤៣

៣.១.៤. ឥទ្ធិពលនៃការអប់រំទៅលើជីវភាពគ្រួសារ ............ ៤៤

៣.១.៥. កត្តាដែលជំរុញឲ្យស្ត្រីចូលរួមក្នុងការអប់រំ ............ ៤៥

៣.១.៦. បញ្ហាប្រឈមដែលស្ត្រីជួបប្រទះក្នុងការអប់រំ ............ ៤៦

៣.១.៧. ភាគីដែលរួមចំណែកក្នុងការអប់រំរបស់ស្ត្រី ............ ៤៨

៣.១.៨. វិធានការក្នុងការលើកកម្ពស់ការអប់រំរបស់ស្ត្រី ............ ៤៩

៣.១.៩. បទពិសោធន៍របស់ស្ត្រីផ្ទាល់ដើម្បីទទួលបានការអប់រំ ............ ៥០

៣.១.១០. ទស្សនៈរបស់ស្ត្រីក្នុងការលើកកម្ពស់សេដ្ឋកិច្ចគ្រួសារតាមរយៈការអប់រំ ............ ៥១


## សេចក្តីសន្និដ្ឋាន និងអនុសាសន៍


១. សេចក្តីសន្និដ្ឋាន ............ ៥៣

២. អនុសាសន៍ ............ ៥៤

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីតារាង

**ទំព័រ**


តារាងទី ១៖ អាយុ ....................................................................................... ៣៧
តារាងទី ២៖ ស្ថានភាពគ្រួសារ ....................................................................................... ៣៨
តារាងទី ៣៖ សមាជិកគ្រួសារ ....................................................................................... ៣៩
តារាងទី ៤៖ កម្រិតនៃការសិក្សា ....................................................................................... ៤០
តារាងទី ៥៖ មុខរបរនិងមុខតំណែងរបស់ស្ត្រី ....................................................................................... ៤១
តារាងទី ៦៖ កម្រិតនៃប្រាក់ចំណូលជាមធ្យម ....................................................................................... ៤២
តារាងទី ៧៖ សារៈសំខាន់នៃការអប់រំរបស់ស្ត្រី ....................................................................................... ៤៣
តារាងទី ៨៖ ឥទ្ធិពលនៃការអប់រំទៅលើជីវភាពគ្រួសារ ....................................................................................... ៤៤
តារាងទី ៩៖ កត្តាដែលជំរុញឲ្យស្ត្រីចូលរួមក្នុងការអប់រំ ....................................................................................... ៤៥
តារាងទី ១០៖ បញ្ហាប្រឈមដែលស្ត្រីជួបប្រទះក្នុងការអប់រំ ....................................................................................... ៤៦
តារាងទី ១១៖ ភាគីដែលរួមចំណែកក្នុងការអប់រំរបស់ស្ត្រី ....................................................................................... ៤៨
តារាងទី ១២៖ វិធានការក្នុងការលើកកម្ពស់ការអប់រំរបស់ស្ត្រី ....................................................................................... ៤៩

# សេចក្តីផ្តើម

# សេចក្ដីផ្ដើម

សេដ្ឋកិច្ចគ្រួសារមួយរឹងមាំប្រៀបបានដូចជាសសរគ្រឹះមួយដ៏រឹងមាំ ដែលអាចនាំឲ្យប្រទេសជាតិមួយឈានដល់ការអភិវឌ្ឍ និងមានការរីកចម្រើនទៅមុខជានិរន្តន៍។ អ្វីដែលប្រទេសកំពុងអភិវឌ្ឍន៍នីមួយៗតែងតែធ្វើជាចាំបាច់នោះគឺ ការពង្រឹងប្រព័ន្ធនៃការអប់រំប្រកបដោយតម្លាភាព តាមរយៈការផ្ដល់ឲ្យប្រជាជនគ្រប់ៗរូបនូវការទទួលបានការអប់រំស្មើៗគ្នាទាំងស្ត្រី និងបុរស មិនថាប្រជាជនដែលរស់នៅជនបទ ឬទីក្រុងឡើយ។ តាមរយៈរបាយការណ៍របស់ធនាគារពិភពលោកប្រចាំនៅប្រទេសកម្ពុជា បានបង្ហាញឲ្យឃើញថា ធនាគារនេះបានចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍវិស័យអប់រំនៅប្រទេសកម្ពុជា ដោយបានបញ្ចប់នូវគម្រោងអភិវឌ្ឍវិស័យអប់រំចំនួន ៣ ធំៗនាពេលថ្មីៗនេះ។ តាមរយៈគម្រោងទ្រទ្រង់វិស័យអប់រំទី ២ នេះ វាបានផ្ដល់អាហារូបករណ៍ដល់សិស្សក្រីក្រ បានបណ្ដុះបណ្ដាលគ្រូបង្រៀន និងបានកសាងសាលាបឋមសិក្សា ព្រមទាំងបានបង្កើតកម្មវិធីអប់រំកុមារតូចៗនិងមជ្ឈមណ្ឌលនៅក្នុងសហគមន៍ផងដែរ។ នៅចុងបញ្ចប់នៃគម្រោង ក្នុងឆ្នាំ ២០១៧ កុមារចំនួន ៣៨% ដែលមានអាយុចន្លោះពី ៣ ទៅ ៥ឆ្នាំ បានចុះឈ្មោះចូលរៀនជាផ្លូវការនៅសាលារៀនចំនួន ១០០ កន្លែង និងសាលាមត្តេយ្យសហគមន៍ចំនួន ៥០០ កន្លែងដែលគាំទ្រដោយគម្រោងនេះ។ គ្រូបង្រៀន និងម្ដាយនៅក្នុងសហគមន៍ដែលអប់រំកុមារតូចៗចំនួន ៣,៨៦១នាក់ ត្រូវបានបណ្ដុះបណ្ដាល ហើយមានសិស្សប្រមាណ ១២៥,៣៣៧ នាក់ ដែលមានអាយុចន្លោះពី ៣ ទៅ ៥ឆ្នាំ បានទទួលផលដោយផ្ទាល់ពីសកម្មភាពនៃគម្រោងនេះ។ អាស្រ័យហេតុនេះ ស្ត្រីបានចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងការលើកកម្ពស់សេដ្ឋកិច្ចគ្រួសារតាមរយៈចំណេះដឹង និងកម្រិតនៃការអប់រំដែលពួកគាត់ទទួលបានផងដែរ។

## ១. លំនាំបញ្ហា

ប្រទេសដែលកំពុងអភិវឌ្ឍន៍មួយចំនួននៅលើពិភពលោកយើងនេះ កំពុងតែយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើប្រព័ន្ធអប់រំ ជាពិសេសទៅទៀតនោះគឺការអប់រំរបស់ស្ត្រីគ្រប់ៗរូប ដោយសារតែវិស័យអប់រំដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកដល់ការអភិវឌ្ឍជាតិ។ យើងអង្កេតឃើញថា កាលពីសម័យមុន ស្ត្រីដែលរស់នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើនគឺពុំមានចំណេះដឹងជ្រៅជ្រះនោះទេ ដោយពួកគាត់មិនបានយល់ដឹងពីអត្ថប្រយោជន៍នៃការសិក្សា ព្រមទាំងសិទ្ធិដែលពួកគាត់ត្រូវទទួលបានឡើយ ទើបជាហេតុធ្វើឲ្យពួកគាត់ពុំសូវមានឱកាសការងារច្រើន និងទទួលបានប្រាក់ចំណូលទាបជាងបុរស។

យ៉ាងណាមិញ ស្ត្រីមិនមែនមានតួនាទីត្រឹមតែជាមេផ្ទះមួយមុខទេ តែស្ត្រីក៏មានតួនាទីដូចបុរសផងដែរ ពោលគឺប្រៀបបានទៅនឹងពាក្យស្លោកខ្មែរយើងដែលពោលថា **សម្លឆ្ងាញ់ក៏ព្រោះតែគ្រឿង ឯគ្រួសាររុងរឿងក៏ព្រោះតែស្ត្រី**។ ដូច្នេះស្ត្រីប្រៀបបានដូចជាមេគ្រួសារមួយរូបផងដែរ គឺនៅពេលដែលពួកគាត់ទទួលបានការ

អប់រំកាន់តែខ្ពស់ នោះសេដ្ឋកិច្ចគ្រួសាររបស់ពួកគាត់ក៏កាន់តែល្អប្រសើរ និងរីកចម្រើនទៅមុខបានមួយកម្រិតទៀតផងដែរ។

ដោយសារតែការយល់ដឹងពីអត្ថប្រយោជន៍ទាំងនេះហើយ ទើបក្នុងពេលបច្ចុប្បន្ននេះ យើងបានកត់សម្គាល់ឃើញថា សង្គមព្រមទាំងរាជរដ្ឋាភិបាល បានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការអប់រំ និងការផ្តល់សិទ្ធិអំណាចទៅឲ្យស្រ្តី ដោយផ្តល់ឱកាសឲ្យពួកគាត់បានសិក្សារៀនសូត្រខ្ពង់ខ្ពស់ អាចធ្វើការងារដូចបុរស និងមានលទ្ធភាពរកចំណូលដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសាររបស់ពួកគាត់ផងដែរ។ ជាក់ស្តែងយើងក៏សង្កេតឃើញថាចំនួនស្រ្តីដែលមានចំណេះដឹងខ្ពង់ខ្ពស់ មានឱកាសការងារច្រើន និងមានមុខតំណែងខ្ពស់មានការកើនឡើង មិនចាញ់បុរសដែលកំពុងធ្វើការនៅតាមបណ្តាស្ថាប័ននានា មិនថាស្ថាប័នរដ្ឋ ឬ ឯកជនឡើយ។

## ២. ចំណោទបញ្ហា

តាមរយៈការអប់រំ ស្រ្តីបានកែប្រែខ្លួនពីមេផ្ទះដែលទន់ខ្សោយឲ្យក្លាយទៅជាស្រ្តីដែលរឹងមាំ និងមានតួនាទី និងឋានៈខ្ពង់ខ្ពស់នៅក្នុងការប្រកបការងារមិនចាញ់ទៅនឹងស្វាមីឡើយ ព្រមទាំងអាចរកប្រាក់ចំណូលដើម្បីលើកកម្ពស់សេដ្ឋកិច្ចគ្រួសារបានមួយកម្រិតទៀត។ ដូច្នេះហើយ តាមរយៈការស្រាវជ្រាវនេះ យើងចង់ដឹងពីសំណួរមួយចំនួនដែលទាក់ទងនឹងការអប់រំរបស់ស្រ្តីដូចខាងក្រោម៖

- តើការអប់រំមានសារៈសំខាន់អ្វីខ្លះចំពោះស្រ្តី?
- តើស្រ្តីជួបប្រទះនូវបញ្ហាអ្វីខ្លះក្នុងការទទួលបានការអប់រំ?
- តើការអប់រំរបស់ស្រ្តីបានលើកកម្ពស់សេដ្ឋកិច្ចគ្រួសារយ៉ាងដូចម្តេចខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ មានគោលបំណង៖

- ស្វែងយល់ពីប្រវត្តិនៃការអប់រំរបស់ស្រ្តី
- ស្វែងយល់ពីផលប្រយោជន៍ដែលស្រ្តីទទួលបានពីការអប់រំ
- ស្វែងយល់ពីបញ្ហាប្រឈម និងផលពិបាករបស់ស្រ្តីក្នុងការទទួលបានការអប់រំ
- ស្វែងយល់ពីបទពិសោធន៍ដែលស្រ្តីជួបប្រទះផ្ទាល់ក្នុងការអប់រំ
- បង្ហាញពីការចូលរួមចំណែកលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ តាមរយៈការអប់រំរបស់ស្រ្តី។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

នៅក្នុងប្រធានបទនេះ យើងខ្ញុំនឹងធ្វើការសិក្សាទៅលើកម្រិតនៃការអប់រំរបស់ស្រ្តី បញ្ហាប្រឈម និង

ផលពិបាករបស់ស្ត្រីក្នុងការទទួលបានការអប់រំ កម្រិតប្រាក់ចំណូល កត្តាជះឥទ្ធិពលផ្សេងៗ ដោយផ្តោតសំខាន់ទៅលើការអប់រំរបស់ស្ត្រី ដែលចូលរួមចំណែកលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ តាមរយៈទិន្នន័យចម្បងដែលមកពីកម្រងសំណួរទាំងស្រុង។ ការប្រមូលទិន្នន័យនេះ គឺគិតចាប់ពីថ្ងៃទី២៥ ដល់ថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០២០។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការប្រមូលទិន្នន័យសម្រាប់ការស្រាវជ្រាវនេះ គឺពឹងផ្អែកទាំងស្រុងទៅលើទិន្នន័យចម្បង ដោយយើងខ្ញុំនឹងធ្វើការស្រង់ស្ថិតិពីស្ត្រីដែលធ្វើការនៅតាមបណ្តារោងចក្រកាត់ដេរ និងនៅតាមស្ថាប័ននានានៅក្នុងរាជធានីភ្នំពេញ។ កម្រងសំណួរដែលយើងខ្ញុំបានចងក្រងឡើងនេះនឹងផ្តោតសំខាន់ទៅលើការអប់រំ មុខរបរ មុខតំណែង និងប្រាក់ចំណូលដែលស្ត្រីទទួលបាន បញ្ហាប្រឈមដែលពួកគាត់ជួបប្រទះ ព្រមទាំងកត្តានានាដែលបានចូលរួមចំណែកក្នុងការលើកកម្ពស់សេដ្ឋកិច្ចគ្រួសាររបស់ពួកគាត់។

- **ទិន្នន័យចម្បង (ទិន្នន័យទី១)**

ដោយសារតែពេលវេលាដែលត្រូវធ្វើការស្រាវជ្រាវមានរយៈពេលខ្លី គួបផ្សំនឹងធនធានថវិកាដែលត្រូវចំណាយមានកម្រិត ហេតុនេះហើយយើងខ្ញុំសម្រេចជ្រើសរើសគំរូតាងដែលជាទិន្នន័យចម្បងរបស់យើង ពោលគឺយើងនឹងធ្វើការស្រង់ស្ថិតិតាមរយៈកម្រងសំណួរដោយផ្ទាល់ និងតាមប្រព័ន្ធអ៊ីនធើណេត ពីស្ត្រីដែលត្រូវបានជ្រើសរើសដោយចៃដន្យចំនួន ១០០ នាក់ ដែលក្នុងនោះស្ត្រីចំនួន ៥០ នាក់ ជាអ្នកធ្វើការងារនៅតាមបណ្តាស្ថាប័នរដ្ឋ និងឯកជននានា និងស្ត្រីចំនួន ៥០ នាក់ទៀត ជាអ្នកធ្វើការងារនៅក្នុងរោងចក្រកាត់ដេរនៅក្នុងរាជធានីភ្នំពេញ។

- **ទិន្នន័យបន្ទាប់បន្សំ (ទិន្នន័យទី២)**

ក្រៅពីទិន្នន័យចម្បង ពួកយើងក៏បានធ្វើការស្រាវជ្រាវពីទិន្នន័យបន្ទាប់បន្សំផ្សេងៗដូចជា ឯកសារ ឬរបាយការណ៍នានារបស់ធនាគារពិភពលោកប្រចាំនៅកម្ពុជា និងក្រសួងអប់រំយុវជន និងកីឡាជាដើម ព្រមទាំងស្វែងរកឯកសារតាមរយៈគេហទំព័រដែលមានប្រភពច្បាស់លាស់មួយចំនួនទៀតដើម្បីទទួលបានទិន្នន័យជាក់លាក់ដែលមានស្រាប់សម្រាប់ជាជំនួយក្នុងការវិភាគ និងជាឯកសារយោងរបស់ពួកយើងផងដែរ។

- **ការវិភាគទិន្នន័យ**

ក្រោយពីទទួលបានទិន្នន័យហើយពួកយើងនឹងធ្វើការបញ្ចូលទិន្នន័យទាំងនោះទៅក្នុងកម្មវិធី SPSS ដើម្បីធ្វើការវិភាគទៅតាមលទ្ធផលដែលយើងទទួលបាន។ បន្ទាប់មកទើបយើងធ្វើការសន្និដ្ឋាន និងផ្តល់ជាអនុសាសន៍ខ្លះៗទៅលើលទ្ធផលទាំងនោះ។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ បានផ្ដល់ចំណេះដឹងទាក់ទងទៅនឹងការលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ តាមរយៈការអប់រំរបស់ស្ត្រី ព្រមទាំងអាចឲ្យយើងបានយល់ដឹងអំពីបញ្ហាប្រឈមនានាដែលស្ត្រីបានជួបប្រទះ និងអត្ថប្រយោជន៍ដែលស្ត្រីទទួលបានពីការអប់រំ។ ក្រោយពីបញ្ចប់ការស្រាវជ្រាវនេះ យើងសង្ឃឹមយ៉ាងមុតមាំថា បណ្ដាស្ថាប័ននានា មិនថារដ្ឋ ឬឯកជន នឹងជួយដោះស្រាយបញ្ហាទាំងឡាយដែលស្ត្រីជួបប្រទះ ព្រមទាំងជួយលើកទឹកចិត្តឲ្យស្ត្រីទទួលបានការអប់រំគ្រប់ៗគ្នា។ ម្យ៉ាងវិញទៀត សម្ភិទ្ធិផលនៃការស្រាវជ្រាវមួយនេះ នឹងក្លាយជាប្រយោជន៍សម្រាប់សិស្សានុសិស្សគ្រប់ៗរូប ដែលមានបំណងចង់សិក្សាស្វែងយល់បន្ថែមពីព័ត៌មានដែលទាក់ទងនឹងការលើកកម្ពស់សេដ្ឋកិច្ចគ្រួសារតាមរយៈការអប់រំរបស់ស្ត្រីផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះចែកចេញជា ៣ ជំពូក ដែលមានដូចខាងក្រោម៖

- ជំពូកទី១ រំលឹកទ្រឹស្តីពាក់ព័ន្ធ
- ជំពូកទី២ ស្ថានភាពទូទៅរបស់ស្ត្រីបម្រើការងារនៅក្នុងរាជធានីភ្នំពេញ
- ជំពូកទី៣ ការវិភាគលើលទ្ធផលស្រាវជ្រាវ

# ជំពូកទី១

# រំលឹកទ្រឹស្តីពាក់ព័ន្ធ

# ជំពូកទី១ រំលឹកទ្រឹស្តីពាក់ព័ន្ធ

## ១.១. និយមន័យ

### ១.១.១. ការអប់រំ

ការអប់រំ គឺជាការហាត់ចិត្ត បង្វឹកចិត្ត ជួសជុលចំណេះវិជ្ជា ឬកិរិយាមារយាទ ហ្វឹកហាត់ឲ្យស្ទាត់ជំនាញជាងមុន កែឲ្យបានល្អប្រពៃជាងមុនជាលំដាប់ ខំប្រឹងបំពេញនិស្ស័យឲ្យបរិបូណ៌ ខំសាងសន្សំបុណ្យកុសលរក្សាទុកពុំឲ្យមានហ្មង មានថ្នាំងថ្នាក់។[1]

ការអប់រំ គឺជាដំណើរការនៃការបង្រៀន ការបណ្តុះបណ្តាល និងការរៀនសូត្រ ជាពិសេសនៅក្នុងសាលារៀន មហាវិទ្យាល័យ ឬសាកលវិទ្យាល័យ ដើម្បីបង្កើនចំណេះដឹង និងអភិវឌ្ឍជំនាញ។[2]

តាមរយៈច្បាប់ស្តីពីការអប់រំ និយមន័យនៃការអប់រំ គឺសំដៅដល់កិច្ចដំណើរការអភិវឌ្ឍការសិក្សា ឬការបណ្តុះបណ្តាលកាយសម្បទា សតិបញ្ញា និងសីលធម៌ តាមរយៈគ្រប់សកម្មភាពអប់រំដែលធ្វើឲ្យអ្នកសិក្សាទទួលបានសំណុំចំណេះដឹង ជំនាញ សមត្ថភាព និងតម្លៃ ដើម្បីឲ្យក្លាយខ្លួនជាបុគ្គលដែលមានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោក។[3]

### ១.១.២. ស្ត្រី

ស្ត្រី គឺជាមនុស្សជាតិដែលមានភេទទីទៃពីបុរស។[4]

តាមរយៈប្រពៃណីរបស់ប្រទេសកម្ពុជាយើង ស្ត្រីត្រូវបានគេរំពឹងថា ជាមនុស្សដែលមានចរិកលក្ខណៈសុភាពរាបសា មានសម្តីទន់ភ្លន់ មានដំណើរស្រាលៗ មានសុជីវធម៌ ឧស្សាហ៍ព្យាយាមនៅក្នុងក្រុមគ្រួសារ ព្រមទាំងដើរតួជាអ្នកចិញ្ចឹមបីបាច់ និងថែរក្សាគ្រួសារ និងជាអ្នកគ្រប់គ្រងហិរញ្ញវត្ថុក្នុងគ្រួសារ។ ក្នុងនាមជាអ្នកគ្រប់គ្រងហិរញ្ញវត្ថុ ស្ត្រីនៅប្រទេសកម្ពុជាអាចត្រូវបានគេកំណត់ថា មានសិទ្ធិអំណាចនៅក្នុងគ្រួសារផងដែរ។ ម៉្យាងវិញទៀត ស្រីក៏មានតួនាទីជាអ្នកការពារផ្ទះសម្បែង រក្សាព្រហ្មចារីរហូតដល់ថ្ងៃរៀបអាពាហ៍ពិពាហ៍ ដើម្បីក្លាយជាភរិយាស្មោះត្រង់ និងធ្វើជាទីប្រឹក្សា និងអ្នកបម្រើដល់ប្តីរបស់ពួកគាត់។[5]

---

[1] ដកស្រង់ចេញពីវចនានុក្រមខ្មែរ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស ២៥១១ គ.ស ១៩៦៧

[2] ដកស្រង់ចេញពីវចនានុក្រម Oxford Learner's Dictionaries

[3] ច្បាប់ស្តីពីការអប់រំ រាជកិច្ច ទំព័រ ៩៨០២ មាត្រាទី៤

[4] ដកស្រង់ចេញពីវចនានុក្រមខ្មែរសម្តេចព្រះសង្ឃរាជជួនណាត

[5] Chey Elizabeth *THE STATUS OF KHMER WOMEN*, Mekong.net
http://www.mekong.net/cambodia/women.htm (ចូលទស្សនាថ្ងៃទី ១០ មិថុនា ២០២០)

### ១.១.៣ សេដ្ឋកិច្ចគ្រួសារ

សេដ្ឋកិច្ចគ្រួសារ គឺសំដៅទៅលើការចាត់ចែងទាំងឡាយនៅក្នុងផ្ទះដោយមេគ្រួសារ។

គ្រួសារប្រឈមមុខនឹងការសំរេចចិត្តជាច្រើនដូចជា ការបែងចែកតួនាទី និងកាតព្វកិច្ចឲ្យសមាជិកម្នាក់ៗធ្វើ គិតគូរអំពីប្រាក់ចំណូលដែលរកបាន ថាតើត្រូវសន្សំប៉ុន្មាននិងចាយវាយប៉ុន្មាន ថាតើត្រូវចាយវាយលើអ្វីខ្លះ រាប់ចាប់តាំងពីការចំណាយប្រចាំថ្ងៃ ការចំណាយលើការសិក្សារបស់កូនៗ ការដាក់ទុនរកស៊ី។ល។ ពោលគឺគ្រួសារនីមួយៗត្រូវបែងចែកធនធានរបស់ខ្លួនក្នុងចំណោមសមាជិក ដោយផ្អែកលើសមត្ថភាព ការខិតខំប្រឹងប្រែង ចំណង់ចំណូលចិត្តរបស់ពួកគាត់ម្នាក់ៗ និងត្រូវធ្វើយ៉ាងណាដើម្បីរក្សាលំនឹងស្ថានភាពគ្រួសារផងដែរ។[6]

## ១.២. ប្រវត្តិនៃការអប់រំ

### ១.២.១. ការអប់រំនៅសម័យអាណានិគមបារាំង (១៨៦៣ ដល់ ១៩៥៣)

នៅសម័យអាណានិគមបារាំងយើងសង្កេតឃើញថាការអប់រំពុំសូវមានការរីកចម្រើនគួរឲ្យកត់សម្គាល់នោះឡើយ ប៉ុន្តែរាជការបារាំងក៏បានកែប្រែបរិបទនៃការសិក្សាមួយចំនួនផងដែរ ដោយនាំយកនូវការអប់រំបែបទំនើបមកចូលក្នុងប្រទេសកម្ពុជា។ ទន្ទឹមនឹងនេះ ការអប់រំតាមបែបប្រពៃណីក៏នៅតែត្រូវបានអនុវត្ត ដោយការបញ្ជូនកូនប្រុសឲ្យទៅបួសរៀននៅវត្តអារាមដែលមានព្រះសង្ឃជាអ្នកបង្ហាត់បង្រៀន។ ចំណែកកូនស្រីមិនត្រូវបានគេអនុញ្ញាតឲ្យទទួលបានចំណេះវិជ្ជាដូចកូនប្រុសឡើយ ដោយសារតែឪពុកម្តាយរបស់ពួកគាត់នៅតែប្រកាន់ទំនៀមទម្លាប់ កូនស្រីបង្វិលចង្ក្រានមិនជុំ ព្រមទាំងគិតអំពីសុវត្ថិភាពរបស់កូនស្រីពួកគាត់ដែលត្រូវទៅរៀនឆ្ងាយពីផ្ទះ។ ទោះជាយ៉ាងនេះក្តី វត្តអារាមនៅតែជាកន្លែងដ៏សំខាន់សម្រាប់អប់រំ និងបណ្តុះបណ្តាលកុមារក្នុងការអាន និងការសរសេរ។[7]

ការសិក្សាក្នុងវត្តអារាមនេះត្រូវបានគេបែងចែកជាបួនដំណាក់កាលសំខាន់ៗគឺ៖

ដំណាក់កាលទី១៖ កុមារត្រូវរៀនអាន និងសរសេរ

ដំណាក់កាលទី២៖ កុមារត្រូវមើលសាស្ត្រាច្បាប់ ដូចជាច្បាប់ព្រះរាជសម្ភារ ច្បាប់ប្រុស ច្បាប់ស្រីជាដើម

ដំណាក់កាលទី៣៖ កុមារត្រូវរៀនមើលសាស្ត្រាល្បែង ដូចជាប្រលោមលោកសម័យបុរាណដែលសរសេរជាកំណាព្យ ដូចជាសាស្ត្រាជុច ហង្សយន្ត និងសព្វសិទ្ធិជាដើម

ដំណាក់កាលទី៤៖ កុមារត្រូវរៀនមើលសាស្ត្រាទេសន៍ ដូចជាទសជាតក៍ជាដើម។

---

[6] *សេដ្ឋកិច្ច និងសេដ្ឋសាស្ត្រ,* ដកស្រង់ចេញពីគេហទំព័រ https://www.wikiwand.com/km (ចូលទស្សនាថ្ងៃទី១១ មិថុនា ២០២០)

[7] វ៉ាន់ វី (២០១២), *ការសិក្សាអប់រំនៅសម័យអាណានិគមបារាំង* ភ្នំពេញ: ភូមិស្រុកខ្មែរ។

ចាប់តាំងពីឆ្នាំ ១៩០០ មក កំណែទម្រង់ប្រព័ន្ធអប់រំថ្មីតាមបែបទំនើបក៏លេចចេញនូវរូបរាងឡើង។[8] រាជការបារាំងបានបង្កើតសាលាបឋមសិក្សានៅតាមឃុំ និងកែប្រែសាលាវត្តឲ្យមានការបង្រៀនតាមបែបទំនើប ដោយបារាំងបានបន្ថែមនូវគរុកោសល្យថ្មីតាមបែបបស្ចិមប្រទេស ដូចជាការបង្ហាត់បង្រៀនព្រះសង្ឃដែលមានតួនាទីបង្រៀនសិស្សឲ្យទៅរៀនពីវិធីសាស្ត្រគំរូនានា ដូចជាវិធីធ្វើសំបុត្រ រៀនអាន គិតលេខ និងប្រើប្រាស់រង្វាស់រង្វាល់ រៀនប្រវត្តិសាស្ត្រកម្ពុជា ព្រមទាំងរៀនពីវិធីបង្ការជំងឺនានា បន្ថែមពីលើការសិក្សាតាមផ្លូវធម៌។[9] ប៉ុន្តែការអនុវត្តបែបនេះហាក់មិនទទួលបានលទ្ធផលល្អដូចការរំពឹងទុកនោះឡើយ។ ដូច្នេះហើយ នៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩១២ បារាំងក៏បានចេញច្បាប់មួយដែលកំណត់ឲ្យឪពុកម្តាយត្រូវតែបញ្ជូនកូនឲ្យទៅរៀននៅសាលាវត្ត បើមិនដូច្នោះទេនឹងត្រូវទទួលពិន័យ។[10] ចាប់តាំងពីពេលនោះមកសាលាវត្តក៏ចេះតែកើនឡើងបន្តិចម្តងៗដោយឪពុកម្តាយនាំគ្នាបញ្ជូនកូនឲ្យទៅរៀន។ យ៉ាងណាមិញ បារាំងក៏មានបំណងចង់ឲ្យកុមារីបានចូលរៀនដែរ ប៉ុន្តែដោយប្រពៃណីខ្មែរមិនអនុញ្ញាតឲ្យក្មេងស្រីចូលរៀនក្នុងសាលាវត្ត ទើបកំណែទម្រង់នេះមិនសូវមានប្រសិទ្ធភាព។[11]

### ១.២.២. ការអប់រំនៅសម័យសង្គមរាស្ត្រនិយម (១៩៥៣ ដល់ ១៩៧០)

ក្រោមការដឹកនាំរបស់សម្តេចសីហនុ ប្រទេសកម្ពុជាបានទទួលឯករាជ្យភាពដោយសន្តិភាពពីប្រទេសបារាំងនៅឯសន្និសីទទីក្រុងហ្សឺណែវ នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣។ បន្ទាប់មក សម្តេចសីហនុ បានខិតខំជំរុញគោលនយោបាយអប់រំយ៉ាងខ្លាំង ពីការអប់រំជាមូលដ្ឋាន ដល់ការអប់រំកម្រិតឧត្តម ដើម្បីប្រែក្លាយប្រទេសឲ្យទៅជារដ្ឋទំនើប ដែលមានទាំងឧស្សាហកម្ម និងបច្ចេកវិទ្យាក្នុងតំបន់។ រដ្ឋាភិបាលរបស់សម្តេចសីហនុបានចំណាយច្រើនជាង ២០% នៃការចំណាយប្រចាំឆ្នាំរបស់ខ្លួន ទៅលើកម្មវិធីលើកកម្ពស់ការអប់រំដ៏ធំមួយ ដើម្បីបង្រួបបង្រួមមនោគមវិជ្ជា "សង្គមនិយមព្រះពុទ្ធសាសនា" របស់គាត់ដើម្បីអប់រំនិស្សិត និងយុវជនកម្ពុជាឲ្យប្រកាន់ខ្ជាប់នូវភាពស្មោះត្រង់ចំពោះរបបរាជានិយម។ លើសពីនេះទៅទៀត គាត់បានធ្វើកំណែទម្រង់កម្មវិធីសិក្សាដែលទាក់ទងនឹងបារាំង ដែលជាមរតកនៃអាណានិគមនិយម បញ្ចូលទៅក្នុងកម្មវិធីសិក្សារបស់ប្រទេសកម្ពុជាដែលគ្របដណ្តប់លើវប្បធម៌ ប្រវត្តិសាស្ត្រ សិល្បៈ វិទ្យាសាស្ត្រ និងអក្សរសាស្ត្រខ្មែរ។ល។ ជាពិសេសជាងនេះទៅទៀត រាជរដ្ឋាភិបាលបានធ្វើការស្ថាបនានូវអគារសិក្សាតាំងពីថ្នាក់បឋមសិក្សា រហូតដល់សាកលវិទ្យាល័យ ដើម្បីបង្កើនលទ្ធភាពឲ្យមានការសិក្សានៅគ្រប់តំបន់នានាក្នុងព្រះរាជាណាចក្រកម្ពុជា រួមទាំងតំបន់

[8] សៅ ឆាត (១៩៩៣) *ឯកសារប្រវត្តិសាស្ត្រវិបត្តិកម្ពុជា* ភ្នំពេញ

[9] ឃឹន សុខ (២០០៣) *កម្មវិធីប្រវត្តិសាស្ត្រខ្មែរ* ភ្នំពេញ

[10] សូ អឿ (២០០៤) *ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាជាមួយប្រទេសអណ្ណាម និងប្រទេសសៀមក្រោយសតវត្សទី១៦*

[11] ខ្លូត ធីតា (២០០៥) *ទំនាក់ទំនងសីលធម៌និងច្បាប់នៅក្នុងសង្គមខ្មែរ* ភ្នំពេញ។

ព្រៃភ្នំនៃខេត្តមួយចំនួនដូចជា ខេត្តកំពង់ស្ពឺ មណ្ឌលគីរី រតនៈគីរី ស្ទឹងត្រែង និងឧត្តរមានជ័យជាដើម។[12] ជាលទ្ធផលនៃគោលនយោបាយនេះ ចំនួនបឋមសិក្សា អនុវិទ្យាល័យ និងសាកលវិទ្យាល័យថ្មីៗបានកើនឡើងយ៉ាងខ្លាំងនៅទូទាំងប្រទេស។ ការចុះឈ្មោះចូលរៀនរបស់សិស្សានុសិស្សពីឆ្នាំ ១៩៥៥ ដល់ឆ្នាំ ១៩៦៨ នៅកម្រិតបឋមសិក្សាកើនពី ៣១១,០០០នាក់ ដល់ ១,០២៥,០០០នាក់ ចំណែកឯនៅកម្រិតអនុវិទ្យាល័យ និងវិទ្យាល័យកើនពី ៥,៣០០នាក់ ដល់ ១១៧,០០០នាក់ រីឯនៅគ្រឹះស្ថានឧត្តមសិក្សាមានការកើនឡើងយ៉ាងខ្លាំងពីចំនួននិស្សិតប្រមាណ ២០០នាក់ ក្នុងឆ្នាំ ១៩៥៣ ដល់ ៥,៧៥៣នាក់ ក្នុងឆ្នាំ ១៩៧០ ដែលជាសមិទ្ធិផលដ៏អស្ចារ្យមួយក្នុងប្រវត្តិសាស្ត្រឧត្តមសិក្សានៅកម្ពុជា។ សរុបមក វាគឺជារយៈពេលដ៏សំខាន់មួយនៃការអភិវឌ្ឍយ៉ាងឆាប់រហ័សនៃប្រព័ន្ធអប់រំទំនើបរបស់កម្ពុជាក្នុងអំឡុងពេលនៃរបបសង្គមនិយមមួយនេះ។[13]

**១.២.៣. ការអប់រំនៅសម័យសាធារណៈរដ្ឋខ្មែរ** (**១៩៧០ ដល់ ១៩៧៥**)

ទោះបីមានការអះអាងពីអង្គការយូណេស្កូថា រដ្ឋាភិបាល លន់ នល់ នៅតែមានឆន្ទៈក្នុងការពង្រីកវិស័យអប់រំក៏ដោយ ក៏ថវិកាជាតិទាំងអស់បានយកទៅប្រើប្រាស់ក្នុងសង្គ្រាម។ សាលារៀននៅភូមិភាគបូព៌ាត្រូវបានខូចខាតយ៉ាងធ្ងន់ធ្ងរ ខណៈពេលដែលការបណ្តុះបណ្តាលគ្រូ និងការអភិវឌ្ឍកម្មវិធីសិក្សាគឺមិនមានទេនៅក្នុងអំឡុងពេលនោះ។ ការទម្លាក់គ្រាប់បែកដោយសហរដ្ឋអាមេរិក បានបំផ្លាញសាកលវិទ្យាល័យមួយចំនួនដូចជាសាកលវិទ្យាល័យតាកែវ - កែប និងសាកលវិទ្យាល័យកំពង់ចាមជាដើម។ តំបន់ជនបទមួយភាគធំនៃប្រទេសកម្ពុជាបានក្លាយជាកន្លែងធ្វើយុទ្ធនាការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកក្នុងអំឡុងពេលសង្គ្រាមនៅពាក់កណ្តាលឆ្នាំ ១៩៧៣ មុនពេលដែលសភាសហរដ្ឋអាមេរិក បានហាមឃាត់ការទម្លាក់គ្រាប់បែកបន្ថែមទៀត។ ប្រសិនបើយើងក្រឡេកមើលស្ថានការណ៍នៅក្នុងប្រទេសវិញ ការប៉ះទង្គិចជាបន្តបន្ទាប់រវាងសិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ និងមនុស្សមួយចំនួនដែលបានប្រយុទ្ធប្រឆាំងនឹងខ្មែរក្រហម បានរីករាលដាលយ៉ាងខ្លាំង ហើយចំនួនអ្នកចុះឈ្មោះចូលរៀន បានធ្លាក់ចុះយ៉ាងឆាប់រហ័សដោយសារតែការបោះបង់ការសិក្សាកើនឡើង។ សរុបសេចក្តីមក ការអប់រំនៅសម័យនោះមិនមានស្ថេរភាពនោះទេ ដោយសារតែអស្ថេរភាពផ្នែកនយោបាយ ទំនាស់ស៊ីវិល និងការចូលរួមក្នុងសង្គ្រាមវៀតណាម ដែលបង្កការខូចខាតយ៉ាងធ្ងន់ធ្ងរដល់

---

[12] បណ្ឌិតឈុន ពហុ និង ងួន ហេង, *ប្រវត្តិសេដ្ឋកិច្ចនៃប្រទេសកម្ពុជា* បោះពុម្ពលើកទី២ ឆ្នាំ២០១៦

[13] Sam Rany, Ahmad Nurulazam, Hazri Jamil (May 2012) *Cambodia's Higher Education Development in Historical Perspectives (1863-2012)* https://www.researchgate.net/publication/224777173_Cambodia's_Higher_Education_Development_in_Historical_Perspectives_1863-2012 (ចូលទស្សនាថ្ងៃទី ០៤ មិថុនា ២០២០)

ផ្នែកខ្លះនៃប្រទេសកម្ពុជា ជាពិសេសតំបន់ជនបទ។ សិស្ស និងគ្រូមួយចំនួនបានចូលរួមប្រឆាំងនឹងរដ្ឋាភិបាលខ្មែរក្រហម រីឯអ្នកខ្លះទៀតបានចូលរួមធ្វើបដិវត្ត។ ដូច្នេះសាលារៀនភាគច្រើនត្រូវបានបិទ ហើយអត្រាចុះឈ្មោះចូលរៀនបានធ្លាក់ចុះយ៉ាងខ្លាំង ក្នុងរបបមួយឆ្នាំរបស់ខ្មែរក្រហមមុនការចូលដល់នៃរបបកម្ពុជាប្រជាធិបតេយ្យក្នុងឆ្នាំ ១៩៧៥ ដោយមិនមានទម្រង់ថ្មីនៃយុទ្ធសាស្ត្រក្នុងការលើកកម្ពស់ការអប់រំ ឬគោលនយោបាយនៃរបបនេះសម្រាប់ការពង្រីកវិស័យអប់រំនោះទេ។[14]

### ១.២.៤. ការអប់រំនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ ដល់ ១៩៧៩)

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រទេសកម្ពុជាបានធ្លាក់ក្នុងរបបដ៏ឃោឃៅមួយដែលកាន់កាប់ដោយខ្មែរក្រហម។ ប្រជាជនក្នុងក្រុងត្រូវបានជម្លៀសទាំងបង្ខំឲ្យទៅនៅជនបទ ហើយមន្ទីរពេទ្យ សាលារៀន សាកលវិទ្យាល័យ វត្តអារាម ត្រូវបានបិទទ្វារ ដោយពួកខ្មែរក្រហមបានយកលេសថាដើម្បីការពារសុវត្ថិភាព និងអាយុជីវិតរបស់ប្រជាជនកម្ពុជាពីការទម្លាក់គ្រាប់បែកពីអាមេរិក។ ដូច្នេះការអប់រំនៅសម័យនោះបានធ្លាក់ដល់កម្រិតសូន្យ។ គ្រឹះស្ថានដែលធ្លាប់តែប្រើប្រាស់ដើម្បីបម្រើដល់វិស័យអប់រំ ត្រូវបានគេកែប្រែឲ្យទៅជាគុកឃុំឃាំងដាក់សម្ភារៈមន្ទីរសន្តិសុខ និងជាកន្លែងសួរចម្លើយជាដើម។ ការដែលខ្មែរក្រហម ជាពិសេសមេដឹកនាំរបបខ្មែរក្រហមនេះផ្ទាល់គឺលោក ប៉ុល ពត កម្ទេចគ្រឹះស្ថានដែលអាចឲ្យកុមារកម្ពុជាទទួលបានចំណេះវិជ្ជាដូចជាសាលារៀន និងវត្តអារាមទាំងអស់ចោលបែបនេះ គឺដោយសារពួកគាត់យល់ថានៅមុនសម័យបដិវត្តន៍ ពួកសក្តិភូមិ អ្នកមានការអប់រំខ្ពង់ខ្ពស់ ឬបញ្ញាជនបានមើលងាយមើលថោកចំពោះកម្មករ កសិករ នៅជនបទចុងកាត់មាត់ញក ព្រោះពួកគាត់ត្រូវបានពង្វក់ដោយទស្សនៈបែបបស្ចឹមប្រទេស។ ដូច្នេះហើយទើប លោក ប៉ុល ពត បានយកបញ្ហាគម្លាតសង្គម និងការបែងចែកវណ្ណៈមនុស្សនេះ ជាមូលដ្ឋានក្នុងការកសាងបដិវត្តន៍មួយនៅកម្ពុជា។ [15] គាត់បានដឹកនាំប្រជាជនទាំងអស់ឲ្យនាំគ្នាធ្វើស្រែជាជាងចូលសាលារៀន ដែលមានត្រឹមតែទ្រឹស្តីមិនមានការអនុវត្តជាក់ស្តែង ព្រោះការអនុវត្តនិងការរៀនសូត្រជាក់ស្តែងនៅលើការងារ គឺជាការអប់រំដ៏សំខាន់និងចាំបាច់ជាងទ្រឹស្តីនៅក្នុងសៀវភៅទៅទៀត។ ម៉្យាងវិញទៀត ការធ្វើបែបនេះអាចឲ្យកសិករ អ្នកមានចំណេះដឹងតិចតួច និងអ្នកមានចំណេះដឹងខ្ពស់ រស់នៅដោយស្មើភាពគ្នា និងមិនមានការរើសអើងគ្នាទៀត នោះទើបធ្វើឲ្យសង្គមមានសន្តិភាពពេញលេញ។ យ៉ាងណាមិញ យើងឃើញមានសាលារៀនតូចៗដែលមិនផ្លូវការមួយចំនួននៅតាមសហគមន៍របស់ខ្មែរក្រហមផងដែរ ប៉ុន្តែសាលាទាំងនោះភាគច្រើនបង្រៀនពីអក្សរ លេខ មនោ-

---

[14] *Review of Changes of Education Policy for Development in Cambodia from the 1860s to the 1960s*, https://www.researchgate.net/publication/331588169_Review_of_Changes_of_Education_Policy_for_Development_in_Cambodia_from_the_1860s_to_the_1980s (ចូលទស្សនាថ្ងៃទី ០៦ មេសា ២០២០)

[15] វិទ្យុអាស៊ីសេរី, *ការអប់រំ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (៧១)* (ចូលទស្សនាថ្ងៃទី ២៦ មេសា ២០០៨)

គមន៍វិជ្ជា និងទ្រឹស្តីមហាអស្ចារ្យរបស់ចលនាតស៊ូបដិវត្តន៍របស់ទ័ពខ្មែរក្រហម។[16] គោលបំណងក្នុងការបង្ហាត់បង្រៀនកុមារពីវិជ្ជាទាំងនេះ គឺដើម្បីបង្កើតមនសិការនយោបាយរបស់កុមារ ដោយពួកខ្មែរក្រហមព្យាយាមពន្យល់អំពីកម្មវិធីសិក្សាស្តីពីសេដ្ឋកិច្ច និងនយោបាយតាមរយៈការអប់រំនេះឯង។ ក្មេងៗជាច្រើន ត្រូវបានទៅចូលរួមវគ្គហ្វឹកហ្វឺនមនោគមន៍វិជ្ជាដើម្បីអាចបម្រើក្នុងជួរកងទ័ព កងការពារ ឬកងនិរសាជាដើម។ វិស័យអប់រំរបស់បដិវត្តន៍បានបង្រៀនក្មេងៗឲ្យស្អប់មនុស្សទាំងឡាយ ដែលជាពួកសក្តិភូមិ រួមមានបញ្ញាវន្ត មន្ត្រីរាជការ យោធាជាដើម ដោយកំណត់ថាពួកគាត់ជាខ្មាំងរបស់អង្គការ ដូច្នេះហើយត្រូវតែយកទៅកម្ទេចឲ្យអស់ យោងតាមទ្រឹស្តី "**ទុកនៅមិនចំណេញ ដកចេញក៏មិនខាត**"។[17]

### ១.២.៥. ការអប់រំនៅក្នុងសម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩ ដល់ ១៩៨៩)

ដោយសារមានមាគ៌ានយោបាយដ៏ភ្លឺស្វាងរបស់បក្ស និងដោយសារមានសាមគ្គីភាពយ៉ាងជិតស្និទ្ធក្នុងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ព្រមទាំងមានការឧបត្ថម្ភពីប្រជាជន និងកងទ័ពវៀតណាម ការគាំទ្រពីប្រទេសសង្គមនិយមជាបងប្អូន និងប្រជាជនស្នេហាសន្តិភាពលើសកលលោក ប្រជាជនកម្ពុជាបានវាយរំលំរបបប្រល័យពូជសាសន៍ប៉ុល ពត ជាស្ថាពរនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។[18] ការរៀបចំហេដ្ឋារចនាសម្ព័ន្ធនៃការអប់រំក៏កើតមានជាថ្មីម្តងទៀត។ គ្រូបង្រៀន និងសិស្សានុសិស្សដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហមត្រូវបានប្រមូលផ្តុំពីគ្រប់ទិសទី ដោយរដ្ឋាភិបាលបានប្រើគោលនយោបាយមួយគឺ "អ្នកចេះច្រើនបង្រៀនអ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នកមិនចេះ"។[19] យើងឃើញថា វិស័យអប់រំនៅសម័យនោះមានសន្ទុះរីកចម្រើនគួរឲ្យកត់សម្គាល់ ដោយចំនួនសិស្សនៅថ្នាក់មត្តេយ្យសិក្សាកើនឡើងដល់ ១,៥០០,០០០នាក់ សិស្សនៅថ្នាក់អនុវិទ្យាល័យមានប្រមាណ ៥០,០០០នាក់ សិស្សវិទ្យាល័យមានប្រមាណ ២,០០០នាក់ និង គ្រូបង្រៀនមានប្រមាណ ៤០,០០០ នាក់។ ចំណែកថ្នាក់ឧត្តមសិក្សានិងមធ្យមសិក្សាបច្ចេកទេស ដូចជាសាលាគរុវិជ្ជាជាន់ខ្ពស់ វិទ្យាស្ថានបច្ចេកទេសជាន់ខ្ពស់ មហាវិទ្យាល័យវេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្តសាស្ត្រ និងសាលាដទៃទៀតក៏បានបើកឲ្យដំណើរការឡើងវិញដែរ។[20] រហូតមកដល់បច្ចុប្បន្ន ប្រព័ន្ធអប់រំចំណេះទូទៅនៅក្នុងប្រទេស

[16] សួស សាកល, *វិស័យអប់រំ សម័យកម្ពុជាប្រជាធិបតេយ្យ* (១៥ កញ្ញា ២០១៦)

[17] ឌី ខាំបូលី, *ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ* (១៩៧៥-១៩៧៩) របស់មជ្ឈមណ្ឌលឯកសារកម្ពុជា

[18] រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា

[19] សារឌី, *សាធារណរដ្ឋប្រជាមានិតកម្ពុជា និង រដ្ឋកម្ពុជា (១៩៧៩-១៩៩៣)* ដោយខ្មែរដឹង, ដកស្រង់ចេញពីគេហទំព័រ https://khmerdeng.com/khmer-public/

[20] លីម រិនជើ និង រឿន សុភា សារណាបញ្ចប់ការសិក្សាស្តីពី *ប្រសិទ្ធិភាពនៃការអប់រំករណីអង្គការដើម្បីភាពញញឹមនៃកុមារ (២០១៧)*

កម្ពុជាបានអនុវត្តតាមប្រព័ន្ធ ៦-៣-៣ ពោលគឺ កម្រិតបឋមសិក្សាមានរយៈពេល៦ឆ្នាំ កម្រិតអនុវិទ្យាល័យមានរយៈពេល៣ឆ្នាំ និងកម្រិតវិទ្យាល័យមានរយៈពេល៣ឆ្នាំ។ សម្រាប់ថ្នាក់ឧត្តមសិក្សា និស្សិតត្រូវសិក្សារយៈពេល៤ឆ្នាំ ឬលើសពីនេះ អាស្រ័យទៅលើមុខវិជ្ជាដែលពួកគាត់ជ្រើសរើស។[21] យ៉ាងណាមិញ ទោះជាការអប់រំនៅសម័យនោះមានការរីកចម្រើនក្តី ក៏មិនមែនក្មេងទាំងអស់បានចូលសាលារៀនដែរ ពីព្រោះសាលាទាំងក្នុងក្រុង និងតាមជនបទតម្រូវឲ្យឪពុកម្តាយបង់ថ្លៃសិក្សាឲ្យកូនរបស់គាត់។ ចំពោះមន្ត្រីរាជការ ពួកគាត់ចំណាយត្រឹមតែ ២៥រៀល ប៉ុណ្ណោះដើម្បីបញ្ជូនកូនទៅរៀន ចំណែកឯប្រជាពលរដ្ឋដទៃទៀតត្រូវចំណាយចាប់ពី ១៥០ រៀលឡើងទៅ ក្នុងមួយខែដើម្បីបង់ជូនសាលា។ ម្យ៉ាងវិញទៀត សាលាមួយចំនួនផ្តល់អាទិភាពឲ្យកុមារដែលមានឪពុកម្តាយជាអ្នកធ្វើការឲ្យរបបនោះ និងបានបង្ហាញពីភាពស្មោះត្រង់ចំពោះរបបនោះផងដែរ។ ជាមួយគ្នានេះដែរ ដោយសារនៅសម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ប្រទេសយើងទទួលឥទ្ធិពលយ៉ាងខ្លាំងពីប្រទេសវៀតណាម ដូច្នេះហើយទើបកម្មវិធីសិក្សានៅសម័យនោះ ចាប់ពីកម្រិតបឋមសិក្សាទៅ ក្រៅពីសៀវភៅដែលបង្រៀនពីតួអក្សរនីមួយៗរបស់ខ្មែរហើយ សៀវភៅដទៃទៀត ត្រូវបានសរសេរទាក់ទងទៅនឹងប្រទេសវៀតណាម។ ចំណែកឯការសិក្សានៅក្នុងកម្រិតអនុវិទ្យាល័យវិញ កម្មវិធីសិក្សាទាំងអស់ត្រូវបានសរសេរ និងបង្រៀនជាភាសាវៀតណាម។[22]

### ១.២.៦. ការអប់រំនៅក្នុងសម័យរដ្ឋកម្ពុជា (១៩៨៩ ដល់ ១៩៩៣)

នៅក្នុងឆ្នាំ ១៩៨៩ ប្រទេសកម្ពុជាបានផ្លាស់ប្តូររបបនៃការគ្រប់គ្រងទៅជាសម័យរដ្ឋកម្ពុជាវិញ ដោយមានការគាំទ្រពីអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ហៅកាត់ថា អ៊ុនតាក់ នៅឆ្នាំ ១៩៩២។ ការអប់រំសាធារណៈត្រូវបានដាក់ឲ្យប្រើប្រាស់ជាសេរីឡើងវិញសម្រាប់ប្រជាជនទាំងអស់នៅក្នុងប្រទេស ហើយរដ្ឋាភិបាលចម្រុះដែលបានកាន់អំណាចតាំងពីឆ្នាំ ១៩៩៣ មកក៏បានចូលរួមចំណែកក្នុងការគាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីលើកកម្ពស់អត្រាអក្ខរកម្មរបស់ប្រជាជនកម្ពុជាដែលមានរហូតទៅដល់ ៨១,៨% សម្រាប់បុរស និង ៥៨,១% សម្រាប់ស្ត្រី និងលើកកម្ពស់ការទទួលបានការអប់រំ ជាពិសេសនៅតាមសហគមន៍ជនបទ។[23] ការចុះឈ្មោះចូលរៀននៅតាមបឋមសិក្សានៅឆ្នាំ ១៩៨៩ មានការកើនឡើងទៅដល់ ១,៣ លាននាក់ ហើយនៅអនុវិទ្យាល័យដល់ ០,២៤ លាននាក់ បើប្រៀបធៀបជាមួយ

---

[21] គីម សេរី. ២០១៧. សារណាបញ្ចប់ការសិក្សាស្តីពី *ការបង្កើនប្រាក់ចំណូលបុគ្គលតាមរយៈការអប់រំ (២០១៧)*

[22] Jeffrey Hays, *FACTS AND DETAILS: EDUCATION AND SCHOOLS IN CAMBODIA* (May 2014) http://factsanddetails.com/southeast-asia/Cambodia/sub5_2d/entry-2916.html (ចូលទស្សនាថ្ងៃទី ០៥ ឧសភា ២០២០)

[23] AnnaMarie L. Sheldon, *Cambodia* https://education.stateuniversity.com/pages/225/Cambodia.html (ចូលទស្សនាថ្ងៃទី ០៧ ឧសភា ២០២០)

តែ ០,៩ លាននិង ៤,៨០០នាក់ នៅឆ្នាំ ១៩៨០។ គួរឲ្យកត់សម្គាល់ផងដែរថា កុមារដែលចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សាប្រហែល ៣០% គ្មានឪពុក ១០% គ្មានម្តាយ ហើយចន្លោះពី ៥% ទៅ ១០% ជាក្មេងកំព្រា។ ការប្រែប្រួលនៃនយោបាយនិងសេដ្ឋកិច្ច បានធ្វើឲ្យប្រទេសកម្ពុជាកំពុងរង់ចាំអាណត្តិទី ២ នៃរាជរដ្ឋាភិបាលបច្ចុប្បន្ន និងការលុបបំបាត់ទាំងស្រុងនូវឥទ្ធិពលរបស់អង្គការខ្មែរក្រហមនៅឆ្នាំ ១៩៩៨។ ទោះជាយ៉ាងណាក៏ដោយ ប្រជាជនកម្ពុជានៅតែមានមោទនភាព និងទន្ទឹងរងចាំយុគសម័យមាសនៅពេលដែលប្រជាជាតិរបស់ពួកយើងបានរុងរឿងឡើងវិញ។[24]

### ១.២.៧. ការអប់រំនៅក្នុងបច្ចុប្បន្ន (១៩៩៣ ដល់ បច្ចុប្បន្ន)

ក្រសួងអប់រំយុវជន និងកីឡា បានយកចិត្តទុកដាក់យ៉ាងខ្លាំង នៅក្នុងវិស័យអប់រំនៅប្រទេសកម្ពុជាដើម្បីធានាថាកុមារ និងយុវជនកម្ពុជាទាំងអស់ មានឱកាសស្មើគ្នាក្នុងការទទួលបានការអប់រំប្រកបដោយគុណភាព ដោយពុំមានការរើសអើងឋានៈ សង្គម ភូមិសាស្ត្រ ជនជាតិភាគតិច សាសនា ភាសា យេនឌ័រឡើយ។ ម្យ៉ាងវិញទៀត ក្រសួងរំពឹងយ៉ាងមុតមាំថា ក្រោយពីទទួលបានការអប់រំជ្រៅជ្រះហើយសិស្សានុសិស្សទាំងអស់នឹងអាចយកចំណេះដឹងទាំងនោះ ទៅប្រកួតប្រជែងនៅក្នុងទីផ្សារការងារពិភពលោក ដើម្បីអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចនៅក្នុងប្រទេសរបស់យើង។ ក្រសួងមានគោលបំណងពង្រីកការអប់រំរបស់កុមារតូចៗ ពង្រីកការអប់រំក្រៅប្រព័ន្ធ ការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងពង្រីកឱកាសក្នុងការទទួលបានការអប់រំកម្រិតមធ្យមសិក្សា និងឧត្តមសិក្សា តាមរយៈការធ្វើឲ្យប្រសើរឡើងនៃការសហការជាមួយដៃគូអភិវឌ្ឍវិស័យឯកជន អង្គការក្រៅរដ្ឋាភិបាល សហគមន៍ និងឪពុកម្តាយរបស់សិស្សានុសិស្សជាដើម។

យើងក៏សង្កេតឃើញផងដែរថា ក្នុងអំឡុងពេលពីរបីឆ្នាំកន្លងមកនេះ វិស័យអប់រំក្នុងប្រទេសកម្ពុជាមានភាពប្រសើរឡើងគួរឲ្យកត់សម្គាល់ ដោយក្រសួងអប់រំយុវជន និងកីឡា កាន់តែឈានខិតជិតដល់ការសម្រេចបាននូវការផ្តល់សេវាសកលនៃការអប់រំថ្នាក់បឋមសិក្សា តាមរយៈការទទួលបាននូវអត្រាសិស្សចុះឈ្មោះចូលរៀនចំនួន ៩៧.៧% ក្នុងឆ្នាំ២០១៦។ ប្រទេសកម្ពុជាក៏បានពង្រឹងសមភាពផ្នែកយេនឌ័រក្នុងវិស័យអប់រំផងដែរ ដោយក្នុងនោះមានកុមារីចំនួន ៤៨.២% បានចុះឈ្មោះចូលរៀននៅថ្នាក់បឋមសិក្សា។ ជាមួយគ្នានេះដែរ ប្រទេសកម្ពុជាបានកសាងនូវសាលារៀនថ្មីៗចំនួនជិត១០០០ខ្នង ក្នុងអំឡុងពេលដប់ឆ្នាំចុងក្រោយនេះ ហើយបានវិនិយោគធនធានដ៏មានសារៈសំខាន់ជាច្រើន ដើម្បីពង្រីកការទទួលបាននូវសេវាអប់រំប្រកបដោយគុណភាព។ ក្នុងឆ្នាំ ២០១៦ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តថវិកាជាតិចំនួន ១៨.៣១% សម្រាប់

[24] Sideth S. Dy, *Strategies and Policies for Basic Education in Cambodia: Historical Perspectives* https://files.eric.ed.gov/fulltext/EJ903840.pdf (ចូលទស្សនាថ្ងៃទី១០ ឧសភា ២០២០)

វិស័យអប់រំ។ រាជរដ្ឋាភិបាលកម្ពុជា ក៏បាននឹងកំពុងអនុវត្តនូវកំណែទម្រង់វិស័យអប់រំ ដោយផ្តោតលើសសរស្តម្ភចំនួនប្រាំគឺ៖

ទី១៖ ការអនុវត្តផែនការសកម្មភាពនៃគោលនយោបាយគ្រូបង្រៀន

ទី២៖ ការពិនិត្យឡើងវិញនូវកម្មវិធីសិក្សា និងសៀវភៅសិក្សាព្រមទាំងការធ្វើឲ្យប្រសើរឡើងនូវបរិស្ថានសាលារៀន

ទី៣៖ ការធ្វើអធិការកិច្ចគ្រប់ជ្រុងជ្រោយលើការគ្រប់គ្រងសាលារៀន

ទី៤៖ ការពង្រឹងការវាយតម្លៃការសិក្សាទាំងក្នុងថ្នាក់ ការប្រឡង ការធ្វើតេស្តវង្វាយតម្លៃថ្នាក់ជាតិ តំបន់ និងអន្តរជាតិ

ទី៥៖ ការធ្វើកំណែទម្រង់ការសិក្សាថ្នាក់ឧត្តមសិក្សា។

បើទោះបីជាទទួលបាននូវសមិទ្ធិផលទាំងនេះក៏ដោយ ក៏ប្រទេសកម្ពុជានៅតែមានអត្រាចំនួនសិស្សក្នុងថ្នាក់រៀនច្រើនជាងគេក្នុងតំបន់ ហើយមានតែ ៣២% នៃសិស្សស្រីប៉ុណ្ណោះ (៣៨%នៃសិស្សប្រុស) ដែលអាចអាន និងសរសេរភាសាខ្មែរបាន។[25]

អត្រាចុះឈ្មោះចូលរៀនក្នុងចំណោមកុមារអាយុពី ៣ ទៅ ៥ ឆ្នាំបានកើនឡើងពី ១៣,៦% ក្នុងឆ្នាំសិក្សា ២០០៥-២០០៦ ដល់ ៣២,៧% ក្នុងឆ្នាំសិក្សា ២០១២-២០១៣ និងពី ២៧,៣% ដល់ ៥៦.៥% ក្នុងចំណោមក្មេងដែលមានអាយុ៥ឆ្នាំ។ ការចុះឈ្មោះចូលរៀននៅកម្រិតបឋមសិក្សាបានកើនឡើងដល់ ៩៨,២% ក្នុងឆ្នាំ២០១៣។ អត្រានៃការបញ្ចប់កម្រិតបឋមសិក្សាក្នុងឆ្នាំ ២០១២-២០១៣ មានរហូតដល់ ៨៨,៩៩%។ អត្រាបោះបង់ការសិក្សាបានថយចុះពី ១០.៥% ក្នុងឆ្នាំសិក្សា ២០១៣-២០១៤ មក ៤,១% ក្នុងឆ្នាំសិក្សា ២០១៧-២០១៨ និងអត្រាឆ្លងភូមិសិក្សាពីបឋមសិក្សាទៅមធ្យមសិក្សាបឋមភូមិកើនពី ៧៦,៨% ក្នុងឆ្នាំសិក្សា ២០១៣-២០១៤ ដល់ ៨៦% ក្នុងឆ្នាំសិក្សា ២០១៧-២០១៨។[26]

ទន្ទឹមនឹងនោះដែរ ធនាគារពិភពលោកក៏បាននឹងកំពុងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសកម្ពុជាក្នុងការលើកកម្ពស់គុណភាពនៃការអប់រំកម្រិតឧត្តមសិក្សា និងការស្រាវជ្រាវនៅក្នុងប្រទេស និងពង្រីកការទទួលបានការអប់រំខ្ពស់សម្រាប់សិស្សដែលជួបការលំបាកផងដែរ។ គម្រោងពង្រឹងសមត្ថភាពស្ថាប័ន

---

[25] ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ USAID *វិស័យអប់រំ និងការគាំពារកុមារ* របស់ (23 សីហា 2019)

[25] ក្រសួងអប់រំ យុវជន និងកីឡា *NATIONAL ACTION PLAN ON EARLY CHILDHOOD CARE AND DEVELOPMENT 2014-2018* https://drive.google.com/file/d/0B1ash2991v8FOXRUYkNLV0FDMGc/view (ចូលទស្សនាថ្ងៃទី ៣ មិថុនា ២០២០)https://www.usaid.gov/km/cambodia/education (ចូលទស្សនាថ្ងៃទី ៥ មិថុនា ២០២០)

ឧត្តមសិក្សា នេះត្រូវបានអនុម័តដោយ ក្រុមប្រឹក្សាប្រតិបត្តិរបស់ធនាគារពិភពលោកនៅថ្ងៃទី២៨ ខែមេសា ឆ្នាំ ២០១៨។ គម្រោងដែលមានមូលនិធិចំនួន ៩០ លានដុល្លារនេះ នឹងផ្តោតលើការកែលម្អផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម គណិតវិទ្យា ក៏ដូចជាកម្មវិធីកសិកម្ម ដោយមានគោលដៅផ្តល់ជូននិស្សិតបញ្ចប់ការសិក្សានៅកម្ពុជាឲ្យទទួលបាននូវជំនាញដែលពាក់ព័ន្ធ និងអាចផ្ទេរទៅឲ្យមនុស្សជំនាន់ក្រោយបានកាន់តែច្រើន ព្រមទាំងអាចគាំទ្រដល់ការផ្លាស់ប្តូរប្រទេសពីការពឹងផ្អែកលើកម្លាំងពលកម្មឲ្យទៅជាប្រទេសដែលពោរពេញដោយមនុស្សមានចំណេះដឹងជ្រៅជ្រះ។

សកម្មភាពសំខាន់ៗទាំង ៥ របស់គម្រោងរួមមាន៖

- ផ្តល់ថវិកាស្រាវជ្រាវនៅក្នុងមុខវិជ្ជាអាទិភាព
- ពង្រីកបន្ទប់រៀននិងមន្ទីរពិសោធន៍
- កសាងអន្តេវាសិកដ្ឋានសម្រាប់និស្សិតដែលជួបការលំបាក ដូចជាសិស្សមកពីគ្រួសារក្រីក្រ និងតំបន់ដាច់ស្រយាល ក៏ដូចជានិស្សិតស្រីជាដើម
- ពង្រឹងការធានាគុណភាពនិងប្រព័ន្ធព័ត៌មាន
- និងធ្វើការជាមួយដៃគូអន្តរជាតិ ដើម្បីកែលំអកម្មវិធីសិក្សា និងវិធីសាស្ត្រនៃមុខវិជ្ជាអាទិភាព។[27]

## ១.៣. រចនាសម្ព័ន្ធនៃប្រព័ន្ធអប់រំរបស់ប្រទេសកម្ពុជា

ចាប់តាំងពីឆ្នាំ ១៩៩៦ មក រចនាសម្ព័ន្ធអប់រំផ្លូវការរបស់ប្រទេសកម្ពុជាត្រូវបានបង្កើតឡើងក្នុងទម្រង់ ៦+៣+៣ ដែលមានន័យថា ការបញ្ចប់ការអប់រំទូទៅមានរយៈពេល ១២ឆ្នាំ ដែលបែងចែកជា ៦ឆ្នាំសម្រាប់ការអប់រំកម្រិតបឋម (ពីថ្នាក់ទី១ ដល់ថ្នាក់ទី៦) និង ៦ឆ្នាំសម្រាប់ការអប់រំកម្រិតមធ្យមសិក្សា (ពីថ្នាក់ទី៧ ដល់ថ្នាក់ទី១២) ដែលក្នុងនោះមានរយៈពេល ៣ឆ្នាំសម្រាប់ការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ (ពីថ្នាក់ទី៧ ដល់ថ្នាក់ទី៩) និងរយៈពេល ៣ឆ្នាំទៀតសម្រាប់ការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ (ពីថ្នាក់ទី១០ ដល់ថ្នាក់ទី១២)។ ការរៀបចំនេះមិនរាប់បញ្ចូលយ៉ាងហោចណាស់មួយឆ្នាំ សម្រាប់ការអប់រំមុនចូលសាលាមត្តេយ្យសម្រាប់កុមារអាយុពី ៣ ទៅ ៦ ឆ្នាំ និងការអប់រំជាសកលពី ៤ ទៅ ៥ ឆ្នាំនោះទេ។

### ១.៣.១. ការអប់រំកម្រិតមត្តេយ្យសិក្សា

ការអប់រំកម្រិតមត្តេយ្យសិក្សាមានរយៈពេលបីឆ្នាំ និងធ្វើឡើងចំពោះកុមារដែលមានអាយុចាប់ពី ៣

[27] ធនាគារពិភពលោក *Cambodia and World Bank Join Forces to Improve Higher Education and Connectivity (១២ កក្កដា ២០១៨)* https://www.worldbank.org/en/news/press-release/2018/07/12/cambodia-and-world-bank-join-forces-to-improve-higher-education-and-connectivity (ចូលទស្សនាថ្ងៃទី ០៥ មិថុនា ២០២០)

ទៅ ៥ឆ្នាំ។ កុមារតូចៗគួរតែទទួលបានការបង្រៀនចំនួន ៦ម៉ោងក្នុងមួយថ្ងៃ និង ៥ថ្ងៃក្នុងមួយសប្តាហ៍ ហើយការបង្រៀននីមួយៗមានរយៈពេល ៣០នាទី។ ចំពោះមុខវិជ្ជាដែលត្រូវសិក្សារួមមាន ចិត្តចលភាព បុរេគណិត ភាសាខ្មែរ វិទ្យាសាស្ត្រ (ទស្សនា សង្កេត ពិសោធ) និង សិក្សាសង្គម (ចម្រៀង គំនូរ សកម្មភាពកសាង សកម្មភាពប្រចាំថ្ងៃ ល្បែង និងអនាម័យនៅផ្ទះ)។[28]

- **សមត្ថភាពរំពឹងទុក**

ក្រោយពេលបញ្ចប់ការសិក្សានៅមត្តេយ្យសិក្សា កុមារតូចនឹងទទួលបាន៖

- **វិជ្ជាសម្បទា**
  - ស្គាល់និងចេះអាន ព្យញ្ជនៈ ស្រៈ ព្យាង្គ ពាក្យ ឃ្លា និងល្បះ
  - រាប់ចំនួន លេខ គូសតាមលេខពីខ្ទង់ ស្គាល់រូបរាងវត្ថុផ្សេងៗ ទំហំ និងរង្វាស់។
- **បំណិនសម្បទា**
  - ចេះប្រើភាសាខ្មែរសម្រាប់និយាយ ស្តាប់ និងទំនាក់ទំនង
  - ចេះប្រើប្រាស់គណិតវិទ្យា (រាប់ គូសតាម និងប្រៀបធៀប)
  - ចេះអនាម័យខ្លួនប្រាណ
  - ចេះប្រើប្រាស់ចលករតូច (ចលនាម្រាមដៃ) និងចលករធំ (រាងកាយ)
  - ចេះផ្តល់ហេតុផលចំពោះទង្វើរបស់ខ្លួន
  - ចេះប្រើប្រាស់ពាក្យសម្តីនិងកាយវិការសមរម្យជាមួយមិត្តភក្តិ គ្រួសារ និងអ្នកដទៃ
  - ស្គាល់ខុស ស្គាល់ត្រូវ។
- **ចរិយាសម្បទា**
  - ចូលចិត្តការសិក្សា ចេះឆ្ងល់ និងចង់ស្វែងយល់ពីអ្វីដែលថ្មីនិងប្លែក
  - ចេះជួយចែករំលែកនិងសហការគ្នា
  - ចូលចិត្តចម្រៀង របាំ និងតន្ត្រីប្រពៃណីខ្មែរ
  - ស្រឡាញ់បរិស្ថានស្អាត
  - ស្រឡាញ់ខ្លួនឯង គ្រួសារ មិត្តភក្តិ គ្រូបង្រៀន និងអ្នកដទៃ។

---

[28] ក្រសួងអប់រំយុវជន និង កីឡា *ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ២០១៥* http://www.moeys.gov.kh/index.php/kh/dge/2328.html#.XtujHkUzY2w (ចូលទស្សនាថ្ងៃទី ០៣ មិថុនា ២០២០)

### ១.៣.២. ការអប់រំនៅកម្រិតបឋមសិក្សា

ជាគោលការណ៍ ការអប់រំនៅថ្នាក់បឋមសិក្សា គឺជាកាតព្វកិច្ចសម្រាប់កុមារដែលមានអាយុចាប់ពី ៦ ដល់ ១១ ឆ្នាំ។ កម្មវិធីអប់រំបឋមមានរយៈពេល ៦ឆ្នាំ ហើយវាជាដំណាក់កាលដំបូងនៃការអប់រំជាមូលដ្ឋាន។ នៅក្នុងកម្មវិធីសិក្សាថ្នាក់ជាតិថ្មីដែលបានដាក់ចេញនៅក្នុងខែធ្នូ ឆ្នាំ២០០៤ សិស្សនៅថ្នាក់បឋមសិក្សាគួរតែទទួលបានការបង្រៀនចំនួន ៥វគ្គក្នុងមួយថ្ងៃ និង ៥ថ្ងៃក្នុងមួយសប្តាហ៍ ហើយការបង្រៀននីមួយៗមានរយៈពេល ៤០នាទី រួមទាំងរយៈពេល ២ ទៅ ៥ នាទីបន្ថែមពីលើ ៤០នាទី ក្នុងមួយសប្តាហ៍ចំពោះការបង្រៀនកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន។

កម្មវិធីសិក្សាមូលដ្ឋានកម្រិតបឋមសិក្សាត្រូវបានបែងចែកជាពីរវដ្តគឺះ

- វដ្តទី ១ (ថ្នាក់ទី ១-៣) មានមេរៀន ២៧-៣០ ក្នុងមួយសប្តាហ៍មានរយៈពេល ៤០ នាទី ដែលត្រូវបានបែងចែកសម្រាប់មុខវិជ្ជាសំខាន់ៗចំនួន ៥ គឺះ
  - ភាសាខ្មែរ (១៣ មេរៀន)
  - គណិតវិទ្យា (៧ មេរៀន)
  - វិទ្យាសាស្ត្រ និងសិក្សាសង្គម រួមទាំងសិល្បៈ (៣ មេរៀន)
  - អប់រំកាយនិងកីឡា (២ មេរៀន)
  - កម្មវិធីបំណិនជីវិតតាមមូលដ្ឋាន (២-៥ មេរៀន)
- វដ្តទី ២ (ថ្នាក់ទី ៤-៦) មានចំនួនមេរៀនដូចគ្នា តែខុសគ្នាបន្តិចបន្តួចះ
  - ភាសាខ្មែរ (១០ មេរៀន សម្រាប់ថ្នាក់ទី ៤ និង ៨ មេរៀន សម្រាប់ថ្នាក់ទី ៥-៦)
  - គណិតវិទ្យា (៦ មេរៀន សម្រាប់ថ្នាក់ទី ៤-៦)
  - វិទ្យាសាស្ត្រ (៣ មេរៀន សម្រាប់ថ្នាក់ទី ៤ និង ៤ មេរៀន សម្រាប់ថ្នាក់ទី ៥-៦)
  - សិក្សាសង្គមរួមទាំងសិល្បៈ (៤ មេរៀន សម្រាប់ថ្នាក់ទី ៤ និង ៥ មេរៀន សម្រាប់ថ្នាក់ទី ៥-៦)
  - អប់រំកាយនិងកីឡា (២ មេរៀន សម្រាប់ថ្នាក់ទី ៤-៦)
  - កម្មវិធីបំណិនជីវិតតាមមូលដ្ឋាន (២-៥ មេរៀន សម្រាប់ថ្នាក់ទី ៤-៦)។

- **សមត្ថភាពរំពឹងទុក**

ក្រោយពេលបញ្ចប់ការសិក្សានៅបឋមសិក្សា សិស្សនឹងទទួលបានះ

- **វិជ្ជាសម្បទា**

- មានចំណេះដឹងមូលដ្ឋានគ្រឹះរឹងមាំផ្នែកភាសាខ្មែរ សិក្សាសង្គម គណិតវិទ្យា និងអភិវឌ្ឍសុខភាព

កាយសម្បទានិងសីលធម៌

- មានចំណេះដឹងមូលដ្ឋានគ្រឹះផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ និងភាសាបរទេស។

- **បំណិនសម្បទា**

- មានបំណិនមូលដ្ឋានផ្នែកភាសាខ្មែរ (ការអាន ការសរសេរ ការនិយាយ និងការស្តាប់)
- មានបំណិនមូលដ្ឋានផ្នែកគណិតវិទ្យា (គណនា ប្រៀបធៀប និងដោះស្រាយបញ្ហា)
- មានបំណិនប្រើប្រាស់ចំណេះដឹងវិទ្យាសាស្ត្រមូលដ្ឋាន
- មានបំណិនត្រិះរិះពិចារណាមូលដ្ឋានក្នុងការសិក្សា
- មានបំណិនប្រាស្រ័យទាក់ទងល្អក្នុងការសិក្សានិងក្នុងសង្គម
- មានបំណិនបង្ការនិងថែទាំសុខភាពបឋម
- មានសមត្ថភាពស្គាល់ខុស ស្គាល់ត្រូវ។

- **ចរិយាសម្បទា**

- ស្រឡាញ់និងផ្តល់តម្លៃដល់ការសិក្សាក្នុងសាលារៀន
- ស្គាល់និងឲ្យតម្លៃសន្តានចិត្តមេត្តានិងករុណាចំពោះគ្រួសារ មិត្តភក្តិ និងអ្នកដទៃ
- ស្គាល់ ស្រឡាញ់ ថែរក្សា និងការពារវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ និងសិល្បៈជាតិ តំបន់ និងអន្តរជាតិ
- ស្រឡាញ់និងឲ្យតម្លៃបរិស្ថាន វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- ស្រឡាញ់ភាពស្អាតបាត ទាំងខ្លួនប្រាណ សាលារៀន ផ្ទះសម្បែង និងទីសាធារណៈ
- មានទម្លាប់និងអនុវត្តការរស់នៅប្រកបដោយសុខភាពតាមរយៈការធ្វើពលកម្ម និងហាត់កីឡា
- ទទួលខុសត្រូវចំពោះទង្វើខ្លួនឯងទាំងក្នុងការសិក្សានិងការរស់នៅប្រចាំថ្ងៃ។

### ១.៣.៣. ការអប់រំនៅកម្រិតអនុវិទ្យាល័យ

ការអប់រំនៅកម្រិតមធ្យមសិក្សាកម្រិតទាប ឬ ជាដំណាក់កាលទី ២ នៃការអប់រំមូលដ្ឋាននេះ មានរយៈពេល ៣ ឆ្នាំ ហើយជាគោលការណ៍ វាជាកាតព្វកិច្ចសម្រាប់សិស្សដែលមានអាយុចាប់ពី ១២ ដល់ ១៤ ឆ្នាំ។ នៅក្នុងកម្មវិធីសិក្សាថ្នាក់ជាតិថ្មី សិស្សថ្នាក់ទី៧ ដល់ទី៩ គួរតែទទួលបានការបង្រៀនរយៈពេល ៣០ ដងក្នុងមួយសប្តាហ៍ និងពី៤ ទៅ ៧ ម៉ោងក្នុងមួយថ្ងៃ ហើយការបង្រៀននីមួយៗមានរយៈពេល ៥០ នាទី និង

បន្ថែមពីលើរយៈពេល ៥០នាទីពី ២ ទៅ ៥ ដងក្នុងមួយសប្តាហ៍ទៀត ដើម្បីសិក្សាអំពីកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន។

កម្មវិធីសិក្សាពីថ្នាក់ទី៧ ដល់ទី៩ នេះ មានមេរៀនចំនួន ៣២-៣៥ ដែលត្រូវបានបែងចែកសម្រាប់មុខវិជ្ជាធំៗចំនួន ៧ ដែលមានដូចជា៖

- ភាសាខ្មែរ (៧ មេរៀន)
- គណិតវិទ្យា (៧ មេរៀន)
- សិក្សាសង្គម និងវិទ្យាសាស្ត្រ (៦ មេរៀនរៀងៗខ្លួន)
- ភាសាបរទេស (៤ មេរៀន)
- អប់រំកាយ និងកីឡា (២ មេរៀន)
- កម្មវិធីបំណិនជីវិតតាមមូលដ្ឋាន (២-៥ មេរៀន) [29]

- **សមត្ថភាពរំពឹងទុក**

ក្រោយពេលបញ្ចប់ការសិក្សានៅអនុវិទ្យាល័យ សិស្សនឹងទទួលបាន៖

- **វិជ្ជាសម្បទា**

- មានចំណេះដឹងមូលដ្ឋានគ្រឹះរឹងមាំផ្នែកភាសាខ្មែរ វិទ្យាសាស្ត្រ វិទ្យាសាស្ត្រសង្គម គណិតវិទ្យា និងអភិវឌ្ឍសុខភាពកាយសម្បទា និងសីលធម៌
- មានចំណេះដឹងមូលដ្ឋានគ្រឹះផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ និងភាសាបរទេស។

- **បំណិនសម្បទា**

- មានបំណិនមូលដ្ឋានរឹងមាំនិងទូលំទូលាយផ្នែកភាសាខ្មែរ (ការអាន ការសរសេរ ការនិយាយ និងការស្តាប់)
- មានបំណិនមូលដ្ឋានរឹងមាំផ្នែកគណិតវិទ្យា (គណនា ប្រៀបធៀប ពន្យល់ បកស្រាយ និងដោះស្រាយបញ្ហា)
- មានបំណិនប្រើប្រាស់ចំណេះដឹងវិទ្យាសាស្ត្រ បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍មូលដ្ឋាន
- មានបំណិនត្រិះរិះពិចារណានិងដោះស្រាយបញ្ហាមូលដ្ឋានក្នុងការសិក្សានិងក្នុងសង្គម

[29] Sokhan Khut, *The Education System in Cambodia* (១៨ មិនា ២០១៩) https://www.bookbridge.org/post/the-education-system-in-cambodia (ចូលទស្សនាថ្ងៃទី០៤ មិថុនា ២០២០)

- មានបំណិនប្រាស្រ័យទាក់ទងទូលំទូលាយ សម្រាប់ការសិក្សានិងការរស់នៅប្រចាំថ្ងៃ
- មានបំណិនបង្ការនិងថែទាំសុខភាពបឋម
- មានសមត្ថភាពស្គាល់ខុស ស្គាល់ត្រូវ។

- **ចរិយាសម្បទា**

- ស្រឡាញ់និងផ្តល់តម្លៃដល់ការសិក្សាទាំងក្នុងនិងក្រៅប្រព័ន្ធ
- ស្គាល់និងឲ្យតម្លៃសន្តានចិត្តមេត្តានិងករុណាចំពោះគ្រួសារ មិត្តភក្តិ និងអ្នកដទៃ
- ស្គាល់ ស្រឡាញ់ ថែរក្សា និងការពារវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ និងសិល្បៈជាតិ តំបន់ និង អន្តរជាតិ
- ស្រឡាញ់និងឲ្យតម្លៃបរិស្ថាន វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- ស្រឡាញ់ភាពស្អាតបាត ទាំងខ្លួនប្រាណ សាលារៀន ផ្ទះសម្បែង និងទីសាធារណៈ
- មានទម្លាប់និងអនុវត្តការរស់នៅប្រកបដោយសុខភាពតាមរយៈការធ្វើពលកម្ម និងហាត់កីឡា
- ទទួលខុសត្រូវចំពោះទង្វើខ្លួនឯង និងរបស់ក្រុម ទាំងក្នុងការសិក្សា និងការរស់នៅប្រចាំថ្ងៃ។

### ១.៣.៤. ការអប់រំនៅកម្រិតវិទ្យាល័យ

ចំណែកការអប់រំនៅមធ្យមសិក្សាកម្រិតខ្ពស់ មានរយៈពេលបីឆ្នាំផងដែរ។ សិស្សានុសិស្សនៅថ្នាក់ទី១០ ដល់ទី១២ គួរតែទទួលបានការបង្រៀនចំនួន ៣២ ដងក្នុងមួយសប្តាហ៍ ហើយការបង្រៀនមួយៗមានរយៈពេល ៥០ នាទី។ រយៈពេលសរុបនៃឆ្នាំសិក្សាគួរតែមាន ៣៨ សប្តាហ៍។

កម្មវិធីសិក្សាកម្រិតវិទ្យាល័យ ឬមធ្យមសិក្សាទុតិយភូមិ ត្រូវបានបែកចែកជាពីរបណ្តុំផ្សេងគ្នាគឺ កម្មវិធីសិក្សាថ្នាក់វិទ្យាសាស្ត្រ និងថ្នាក់សង្គមដែលត្រូវបានបែងចែកជា ១៤ មុខវិជ្ជា និងសិក្សាតាមចំនួនម៉ោងផ្សេងគ្នាក្នុងមួយសប្តាហ៍គឺ៖

- អក្សរសាស្ត្រខ្មែរ (៥ ម៉ោងសម្រាប់ថ្នាក់វិទ្យាសាស្ត្រ និង ៦ ម៉ោងសម្រាប់ថ្នាក់សង្គម)
- គណិតវិទ្យា (៥ ម៉ោងសម្រាប់ថ្នាក់វិទ្យាសាស្ត្រ និង ៥ ម៉ោងសម្រាប់ថ្នាក់សង្គម)
- ភាសាបរទេស (៦ ម៉ោងសម្រាប់ថ្នាក់វិទ្យាសាស្ត្រ និង ៦ ម៉ោងសម្រាប់ថ្នាក់សង្គម)
- អប់រំកាយនិងកីឡា (២ ម៉ោងសម្រាប់ថ្នាក់វិទ្យាសាស្ត្រ និង ២ ម៉ោងសម្រាប់ថ្នាក់សង្គម)
- គេហសេដ្ឋកិច្ចវិទ្យា (១ ម៉ោងសម្រាប់ថ្នាក់វិទ្យាសាស្ត្រ និង ១ ម៉ោងសម្រាប់ថ្នាក់សង្គម)
- រូបវិទ្យា (៤ ម៉ោងសម្រាប់ថ្នាក់វិទ្យាសាស្ត្រ និង ២ ម៉ោងសម្រាប់ថ្នាក់សង្គម)
- ផែនដីបរិស្ថានវិទ្យា (២ ម៉ោងសម្រាប់ថ្នាក់វិទ្យាសាស្ត្រ និង ២ ម៉ោងសម្រាប់ថ្នាក់សង្គម)

- គីមីវិទ្យា (៣ ម៉ោងសម្រាប់ថ្នាក់វិទ្យាសាស្ត្រ និង ២ ម៉ោងសម្រាប់ថ្នាក់សង្គម)
- ជីវវិទ្យា (៣ ម៉ោងសម្រាប់ថ្នាក់វិទ្យាសាស្ត្រ និង ២ ម៉ោងសម្រាប់ថ្នាក់សង្គម)
- ប្រវត្តិវិទ្យា (២ ម៉ោងសម្រាប់ថ្នាក់វិទ្យាសាស្ត្រ និង ៤ ម៉ោងសម្រាប់ថ្នាក់សង្គម)
- ភូមិវិទ្យា (២ ម៉ោងសម្រាប់ថ្នាក់វិទ្យាសាស្ត្រ និង ៣ ម៉ោងសម្រាប់ថ្នាក់សង្គម)
- សីលធម៌ពលរដ្ឋវិជ្ជា (២ ម៉ោងសម្រាប់ថ្នាក់វិទ្យាសាស្ត្រ និង ៣ ម៉ោងសម្រាប់ថ្នាក់សង្គម)
- បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ (១ ម៉ោងសម្រាប់ថ្នាក់វិទ្យាសាស្ត្រ និង ១ ម៉ោងសម្រាប់ថ្នាក់សង្គម)
- អប់រំសុខភាព (១ ម៉ោងសម្រាប់ថ្នាក់វិទ្យាសាស្ត្រ និង ១ ម៉ោងសម្រាប់ថ្នាក់សង្គម)។

- **សមត្ថភាពរំពឹងទុក**

ក្រោយពេលបញ្ចប់ការសិក្សានៅវិទ្យាល័យ សិស្សនឹងទទួលបានៈ

- **វិជ្ជាសម្បទា**

- មានចំណេះដឹងមូលដ្ឋានគ្រឹះរឹងមាំផ្នែកភាសាខ្មែរ វិទ្យាសាស្ត្រសង្គម គណិតវិទ្យា និងអភិវឌ្ឍសុខភាពកាយសម្បទា និងសីលធម៌
- មានចំណេះដឹងមូលដ្ឋានគ្រឹះរឹងមាំផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ និងភាសាបរទេស។

- **បំណិនសម្បទា**

- មានបំណិនមូលដ្ឋានរឹងមាំ ច្បាស់លាស់ និងទូលំទូលាយផ្នែកអក្សរសាស្ត្រខ្មែរ (ប្រៀបធៀប ពន្យល់ វិភាគ បកស្រាយ និងដោះស្រាយបញ្ហា)
- មានបំណិនមូលដ្ឋានរឹងមាំ និងច្បាស់លាស់ផ្នែកគណិតវិទ្យា (គណនា ប្រៀបធៀប ពន្យល់ រិះគន់ បកស្រាយ និងដោះស្រាយបញ្ហា)
- មានបំណិនអនុវត្តចំណេះដឹងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍មូលដ្ឋាន
- មានបំណិនត្រិះរិះពិចារណានិងដោះស្រាយបញ្ហារឹងមាំនិងទូលំទូលាយទាំងក្នុងការសិក្សា និងក្នុងសង្គម
- មានបំណិនប្រាស្រ័យទាក់ទងទូលំទូលាយនិងមានប្រសិទ្ធភាព ក្នុងការសិក្សានិងក្នុងសង្គម
- មានបំណិនបង្ការនិងថែទាំសុខភាពបឋម
- មានសមត្ថភាពនិងសីលធម៌ ការការពារ និងពង្រីកភាពត្រឹមត្រូវ។

- **ចរិយាសម្បទា**

- ស្រឡាញ់និងផ្តល់តម្លៃដល់ការសិក្សាពេញមួយជីវិត
- ស្គាល់និងឲ្យតម្លៃសន្តានចិត្តមេត្តានិងករុណាចំពោះគ្រួសារ មិត្តភក្តិ និងអ្នកដទៃ
- អភិរក្សនិងអភិវឌ្ឍវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ និងសិល្បៈជាតិ តំបន់ និងអន្តរជាតិ
- ស្រឡាញ់និងឲ្យតម្លៃខ្ពស់ដល់បរិស្ថាន វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- ស្រឡាញ់ភាពស្អាតបាត ទាំងខ្លួនប្រាណ សាលារៀន ផ្ទះសម្បែង និងទីសាធារណៈ
- មានទម្លាប់ និងអនុវត្តការរស់នៅប្រកបដោយសុខភាព តាមរយៈការធ្វើពលកម្ម និងហាត់កីឡា
- ទទួលខុសត្រូវចំពោះទង្វើខ្លួនឯង និងរបស់ក្រុម ទាំងក្នុងការសិក្សា និងការរស់នៅប្រចាំថ្ងៃ។

### ១.៣.៥. ការអប់រំកម្រិតឧត្តមសិក្សា

ការអប់រំកម្រិតឧត្តមសិក្សាត្រូវបានផ្តល់ជូននៅតាមសាកលវិទ្យាល័យនិងតាមស្ថាប័នបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈនានា។ វគ្គសិក្សាកម្រិតឧត្តម មានរយៈពេលពី២ ទៅ ៣ឆ្នាំ។ នៅកម្រិតសាកលវិទ្យា-ល័យ កម្មវិធីដែលឈានដល់កម្រិតបរិញ្ញាបត្រ ឬសមមូល ជាធម្មតាមានរយៈពេល ៤ ឆ្នាំ។ កម្មវិធីសិក្សានៅមហាវិទ្យាល័យគរុកោសល្យ បណ្តុះបណ្តាលគ្រូអនុវិទ្យាល័យមានរយៈពេលមួយឆ្នាំ។ ការសិក្សាលើវិស័យវេជ្ជ-សាស្ត្រ និងទន្តវិទ្យាមានរយៈពេល ៧ឆ្នាំ (៦ ឆ្នាំក្នុងករណីសិក្សាផ្នែកឱសថ និងស្ថាបត្យកម្ម)។[30]

- **សមត្ថភាពរំពឹងទុក**

ក្រោយពេលបញ្ចប់ការសិក្សានៅថ្នាក់ឧត្តមសិក្សា សិស្សនឹងទទួលបាន៖

- **វិជ្ជាសម្បទា**

- ទទួលបានចំណេះដឹងមូលដ្ឋានវិទ្យាសាស្ត្រដែលទាក់ទងនឹងមុខវិជ្ជាជំនាញ
- បកស្រាយបញ្ញត្តិមូលដ្ឋានគ្រឹះនៃមុខជំនាញឯកទេសនីមួយៗ

- **បំណិនសម្បទា**

- អនុវត្តជំនាញឯកទេសដែលទទួលបានពីការបណ្តុះបណ្តាលប្រកបដោយប្រសិទ្ធភាព
- ប្រតិបត្តិគ្រឿងម៉ាស៊ីននិងឧបករណ៍ពាក់ព័ន្ធផ្សេងៗបាន

---

[30] UNESCO *Institute for Statistics* (ខែសីហា ឆ្នាំ២០១៦)
http://www.ibe.unesco.org/fileadmin/user_upload/archive/Countries/WDE/2006/ASIA_and_the_PACIFIC/Cambodia/Cambodia.htm (ចូលទស្សនាថ្ងៃទី ០៤ មិថុនា ២០២០)

- **ចរិយាសម្បទា**
  - មានស្មារតីទទួលខុសត្រូវនិងម្ចាស់ការលើការងាររបស់ខ្លួន
  - មានគំនិតច្នៃប្រឌិតថ្មីដើម្បីអាចដោះស្រាយបញ្ហាបាន
  - ស្រឡាញ់ការងារប្រតិបត្តិនិងធ្វើការជាក្រុមប្រកបដោយប្រសិទ្ធភាព
  - អភិវឌ្ឍបុគ្គលិកលក្ខណៈនិងមុខរបរ
  - មានស្មារតីអភិវឌ្ឍសង្គមជាតិប្រកបដោយចីរភាព។[31]

## ១.៤. ស្ថានភាពទូទៅនៃស្ត្រីក្នុងសង្គមខ្មែរ

### ១.៤.១. ស្ត្រី និងការអប់រំ

ប្រទេសកម្ពុជានាសម័យបុរាណ គឺជាប្រទេសមួយដែលមានវប្បធម៌ដ៏ល្អត្រចះត្រចង់គួរជាទីគោរព ប៉ុន្តែថ្វីត្បិតតែប្រទេសនេះមានវប្បធម៌ដ៏ល្អត្រចះត្រចង់ក៏ពិតមែន ក៏នៅសម័យនោះស្ត្រីពុំសូវទទួលបានការអប់រំដូចបុរសឡើយ ដោយសារតែគ្រួសារភាគច្រើនមានជីវភាពក្រីក្រ សាលារៀនឆ្ងាយពីផ្ទះ ព្រមទាំងការអប់រំរបស់ស្ត្រីមិនត្រូវបានគេឲ្យតម្លៃ ទើបឪពុកម្ដាយសម្រេចចិត្តឲ្យកុមារីបញ្ឈប់ពីការសិក្សា ដើម្បីជួយរកស៊ីចិញ្ចឹមគ្រួសារ នៅមើលថែផ្ទះសម្បែង និងមើលការខុសត្រូវក្នុងផ្ទះវិញ។ ដោយសារតែបញ្ហានេះហើយ ទើបការអប់រំរបស់ក្មេងស្រីនៅក្នុងប្រទេសកម្ពុជាមានភាពខ្វះខាត និងមានភាពអយុត្តិធម៌។ ប្រសិនបើក្មេងស្រីកម្ពុជាមានបំណងចង់ទទួលបានការអប់រំខ្ពស់ ឬចង់បានការងារល្អធ្វើដើម្បីជួយផ្គត់ផ្គង់ជីវភាពគ្រួសារនោះ ក្ដីសុបិន្តរបស់ពួកគាត់នឹងត្រូវបានបំផ្លាញ ដោយសារតែភាពក្រីក្រ ទំនៀមទម្លាប់ប្រពៃណី និងកង្វះសាលារៀននៅតំបន់ជនបទក្នុងប្រទេសកម្ពុជានេះឯង។ ម្យ៉ាងវិញទៀត ទោះបីជាស្ត្រីពុំទទួលបានការសិក្សារៀនសូត្រនៅសាលារៀនក្ដី ក៏ពួកគាត់ត្រូវបានបង្ហាត់បង្រៀនពីវិជ្ជាមេផ្ទះមួយចំនួនផងដែរដោយប្រទេសយើងប្រកាន់ខ្ជាប់នូវទំនៀមទម្លាប់ប្រពៃណីមួយ ដែលនារីក្រមុំទើបនឹងគ្រប់ការគ្រប់រូបត្រូវអនុវត្តនោះគឺ ការចូលម្លប់។ ការប្រតិបត្តិទំនៀមទម្លាប់ចូលម្លប់នេះ គឺក្នុងគោលបំណងហាត់ពត់លុតដំអាកប្បកិរិយា មាយាទ ចរិកលក្ខណៈ ការនិយាយស្ដី ការថែរក្សាសម្រស់ វិជ្ជាមេផ្ទះរបស់ស្ត្រី ដើម្បីត្រៀមខ្លួនធ្វើជាភរិយាដែលចេះគ្រប់សព្វ និងការពារកុំឲ្យសាច់ញាតិខាងប្ដីមើលងាយថាស្ត្រីបង្ខិលចង្រ្កានមិនជុំ។ ក្រោយពេលចេញពីម្លប់វិញ ស្ត្រីភាគច្រើនត្រូវបានចាត់ទុកថាមានសមត្ថភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងគ្រួសារ ទើបឪពុកម្ដាយរបស់ពួកគាត់អនុញ្ញាតឲ្យរៀបអាពាហ៍ពិពាហ៍ និងយកវិជ្ជាដែលបានរៀនសូត្រទាំងនោះទៅបម្រើប្ដីរៀងៗខ្លួន ចំណែកឯបុរសវិញត្រូវបានឪពុកម្ដាយ

[31] ក្រសួងអប់រំយុវជន និង កីឡា *ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ២០១៥* http://www.moeys.gov.kh/index.php/kh/dge/2328.html#.XtujHkUzY2w (ចូលទស្សនាថ្ងៃទី ០៣ មិថុនា ២០២០)

អនុញ្ញាតឲ្យទៅរៀនឲ្យបានខ្ពង់ខ្ពស់ និងខិតខំធ្វើការរកស៊ីដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ និងក្លាយជាមេគ្រួសារដ៏ល្អ។ ផ្ទុយទៅវិញ នាពេលបច្ចុប្បន្ននេះយើងសង្កេតឃើញថា សង្គមបានផ្ដល់ការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការអប់រំរបស់ស្ត្រី ដោយស្ត្រីភាគច្រើនត្រូវបានគេផ្ដល់ឱកាសឲ្យទទួលបានការអប់រំដូចបុរសដែរ ដោយមិនចាំបាច់ពឹងពាក់ទាំងស្រុងទៅលើស្វាមីរបស់ខ្លួនដូចកាលពីសម័យមុនទៀតឡើយ។

### ១.៤.២. ស្ត្រី និងសេដ្ឋកិច្ចគ្រួសារ

ដោយនៅសម័យបុរាណ ប្រទេសកម្ពុជាយើងប្រកាន់ខ្ជាប់នូវទំនៀមទម្លាប់ប្រពៃណីចូលម្លប់ និងមិនសូវឲ្យតម្លៃទៅលើការអប់រំរបស់ស្ត្រី ទើបធ្វើឲ្យស្ត្រីភាគច្រើនពុំមានឱកាសទទួលបានការអប់រំដូចបុរស និងពុំមានលទ្ធភាពរកប្រាក់ចំណូលដើម្បីចូលរួមចំណែកលើកកម្ពស់ដល់សេដ្ឋកិច្ចគ្រួសារ ព្រមទាំងត្រូវរស់នៅដោយពឹងពាក់ទាំងស្រុងទៅលើស្វាមីរបស់ខ្លួន។ ដោយឡែកនាពេលបច្ចុប្បន្ននេះវិញ ស្ត្រីសឹងតែគ្រប់រូបត្រូវបានផ្ដល់ឱកាសឲ្យទទួលបានការអប់រំ ដែលអាចឲ្យពួកគាត់រកប្រាក់ចំណូលសម្រាប់ចូលរួមចំណែកលើកកម្ពស់សេដ្ឋកិច្ចគ្រួសាររបស់ពួកគាត់ឲ្យកាន់តែល្អប្រសើរជាងមុន ដោយមិនចាំបាច់ពឹងពាក់ទាំងស្រុងទៅលើស្វាមីរបស់ខ្លួនទៀតឡើយ។ យើងសង្កេតឃើញថា ស្ត្រីក្នុងពេលបច្ចុប្បន្ន បំពេញកាតព្វកិច្ចទ្វេដងបើប្រៀបធៀបទៅនឹងសម័យមុន ដោយចូលរួមក្នុងការងារកសិកម្ម ឬការងាររកប្រាក់ចំណូលដើម្បីផ្គត់ផ្គង់គ្រួសារផង និងបំពេញកិច្ចការងារក្នុងផ្ទះផង។

ស្ត្រីខ្មែរភាគច្រើនដែលរស់នៅតាមជនបទ បានចូលរួមចំណែកយ៉ាងសកម្ម ក្នុងការងារធ្វើស្រែចម្ការជាមួយបុរស។ ដោយសារតែការងាររបស់ពួកគាត់ពោរពេញទៅដោយការប្រើកម្លាំងពលកម្ម ស្ត្រីតែងតែក្រោកពីព្រលឹមដើម្បីបំពេញកិច្ចការងារក្នុងផ្ទះមុនពេលពួកគាត់ចេញទៅធ្វើស្រែចម្ការ។ ស្ត្រីរស់នៅជនបទដែលរកស៊ីចិញ្ចឹមជីវិតដោយការធ្វើស្រែចម្ការ ត្រូវក្រោកពីម៉ោង ៣ ឬ ៤ ព្រឹក ដើម្បីសម្អាតផ្ទះមុនពេលចាប់ផ្ដើមដឹកទឹកទៅចម្ការរបស់ពួកគាត់ ដោយត្រូវប្រើអស់រយៈពេលជាច្រើនម៉ោងរហូតដល់ពេលថ្ងៃត្រង់។ ចំណែកស្ត្រីដែលរស់នៅក្នុងទីក្រុង ក៏មិនខុសគ្នាប៉ុន្មានដែរ ដោយពួកគាត់ត្រូវក្រោកពីម៉ោង ៥ ឬ ៥:៣០ ដើម្បីបោកគក់សម្លៀកបំពាក់ សំអាតផ្ទះ និងធ្វើការងារផ្ទះផ្សេងទៀត មុននឹងចេញទៅកន្លែងធ្វើការរបស់ពួកគាត់។ នៅពេលចេញពីធ្វើការ ពួកគាត់ត្រូវដើរទិញម្ហូបមុននឹងត្រឡប់មកផ្ទះវិញ បន្ទាប់មកត្រូវចម្អិនអាហារពេលថ្ងៃត្រង់ មុនពេលចូលធ្វើការពេលរសៀលម្ដងទៀត ហើយនៅពេលត្រឡប់មកពីធ្វើការវិញ ស្ត្រីត្រូវធ្វើអាហារពេលល្ងាច ព្រមទាំងធ្វើការងារផ្ទះម្ដងទៀតមុននឹងមានពេលសម្រាក។[32]

[32] Ebihara, May & Judy Ledgerwood, *Woman in Cambodia Society*
http://www.seasite.niu.edu/khmer/ledgerwood/women.htm (ចូលទស្សនាថ្ងៃទី១២ មិថុនា ២០២០)

ទោះជាយ៉ាងណាក៏ដោយ ភាពជោគជ័យគួរឲ្យកត់សម្គាល់របស់ស្ត្រីខ្មែរក្នុងពេលបច្ចុប្បន្ន គឺការចូលរួមចំណែកក្នុងការផ្គត់ផ្គង់ជីវភាពគ្រួសារឲ្យកាន់តែប្រសើរឡើង តាមរយៈការមានការងារល្អធ្វើ និងការធ្វើជំនួញផ្ទាល់ខ្លួនជាដើម ដែលបញ្ជាក់ឲ្យឃើញពីអត្ថប្រយោជន៍នៃការអប់រំរបស់ស្ត្រី។

### ១.៤.៣. ស្ត្រី និងសេដ្ឋកិច្ច

កាលពីសម័យមុន ស្ត្រីខ្មែរយើងមួយភាគធំពុំទទួលបានការអប់រំ គ្មានចំណេះដឹងជ្រៅជ្រះ ហើយថែមទាំងមិនមានប្រាក់ចំណូល ទើបធ្វើឲ្យពួកគាត់មិនមានសកម្មភាពសេដ្ឋកិច្ចអ្វីនោះឡើយ ពោលគឺស្ត្រីនាសម័យនោះ គឺមានតួនាទីត្រឹមតែនៅចាំថែរក្សាផ្ទះសម្បែង ចិញ្ចឹមបីបាច់ និងថែរក្សាកូនៗឲ្យបានល្អ ចំណែកឯបុរសជាប្តី ទើបជាអ្នករកស៊ីចិញ្ចឹមគ្រួសារទាំងមូល។ យ៉ាងណាមិញ ស្ត្រីនាពេលបច្ចុប្បន្ននេះ ភាគច្រើនទទួលបានការអប់រំស្មើរតែគ្រប់ៗគ្នា។ ពួកគាត់មានចំណេះដឹងទូលំទូលាយ មានសមត្ថភាព មានឱកាសការងារ និងមានប្រាក់ចំណូលផងដែរ។ ម្យ៉ាងវិញទៀត ស្ត្រីដែលមានទទួលបានការអប់រំខ្ពង់ខ្ពស់ អាចយល់ដឹងច្រើនទាក់ទងនឹងបញ្ហាមួយចំនួនដូចជាសុខភាព និងសិទ្ធិរបស់ខ្លួន ដោយពួកគាត់បានចូលរួមចំណែកយ៉ាងខ្លាំងក្នុងការកាត់បន្ថយអត្រាមរណភាពរបស់ទារក និងមាតា ការរៀបអាពាហ៍ពិពាហ៍ក្នុងវ័យក្មេងពេករបស់កុមារកំណើនប្រជាជន កង្វះអាហារូបត្ថម្ភ និងបង្កើនការចូលរួមក្នុងដំណើរការនយោបាយ បង្កើនចំនួនកុមារដែលទទួលបានការសិក្សារៀនសូត្រ ធ្វើឲ្យការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមមានភាពប្រសើរឡើង។ សកម្មភាពទាំងអស់នេះហើយដែលបង្ហាញឲ្យឃើញថា ស្ត្រីដែលទទួលបានការអប់រំខ្ពង់ខ្ពស់ចូលរួមដោយផ្ទាល់ និងដោយប្រយោលក្នុងការលើកស្ទួយដល់សេដ្ឋកិច្ចជាតិទាំងមូល។[33]

### ១.៤.៤. ស្ត្រី និងការចូលរួមក្នុងសង្គម

ចំនួនស្ត្រីដែលចូលរួមក្នុងឆាកនយោបាយ និងជាពិសេសនៅក្នុងមុខតំណែងខ្ពស់ៗ នៅមានកម្រិតទាបនៅឡើយ បើប្រៀបធៀបទៅនឹងបុរស ប៉ុន្តែបើប្រៀបធៀបទៅនឹងសម័យមុនវិញ ចំនួននេះមានការកើនឡើងគួរឲ្យកត់សម្គាល់ ទោះជាវានៅមានកម្រិតទាបក្តី។ នៅទសវត្សឆ្នាំ ១៩៨០ យើងបានកត់សម្គាល់ពីការផ្លាស់ប្តូររបស់ស្ត្រីខ្មែរដែលធ្លាប់តែមានភាពអវិជ្ជាទៅជាមានចំណេះវិជ្ជា និងចាប់ផ្តើមមានការចូលរួមក្នុងសង្គមខ្លះៗផងដែរ។ នៅក្នុងឆ្នាំទាំងនោះបន្ទាប់ពីសង្គ្រាម ស្ត្រីត្រូវបានស្នើសុំឲ្យចូលរួមក្នុងការកសាងសង្គមឡើងវិញ។ ស្ត្រីបានចូលរួមបម្រើការងារក្នុងជួររដ្ឋាភិបាល ហើយសមាគមស្ត្រីក៏ត្រូវបានបង្កើតឡើងផងដែរ។ តាមរយៈឥទ្ធិពលរបស់អង្គការក្រៅរដ្ឋាភិបាល ដែលបានចាប់ផ្តើមធ្វើការនៅក្នុងប្រទេសកម្ពុជា និងជាពិសេសអង្គការដែលផ្តោតការយកចិត្តទុកដាក់ទៅលើបញ្ហាស្ត្រី ធ្វើឲ្យការយល់ដឹងពីបញ្ហានយោបាយរបស់ស្ត្រីកម្ពុជា

[33] Central Asia Institute (ស្ថាប័នអាស៊ីកណ្តាល) https://centralasiainstitute.org/ (ចូលទស្សនាថ្ងៃទី១២ មិថុនា ២០២០)

បានកើនឡើង។ នៅក្នុងការបោះឆ្នោតឆ្នាំ ១៩៩៣ ចំនួន ៥% នៃអ្នកដែលបានបោះឆ្នោតជ្រើសរើសឲ្យចូលបម្រើការងារក្នុងរដ្ឋសភាជាតិជាស្ត្រី។ ចំនួននេះបានកើនឡើងគួរឲ្យកត់សម្គាល់រហូតដល់ ១១% ក្នុងឆ្នាំ ១៩៩៨ និង ១៩% ក្នុងការបោះឆ្នោតឆ្នាំ ២០០៣ ។ នៅថ្នាក់ឃុំ ភាគរយនៃស្ត្រីដែលបានជាប់ឆ្នោតកើនឡើងជិតទ្វេដងពី ៨% នៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាថ្នាក់ឃុំសង្កាត់ដំបូងក្នុងឆ្នាំ ២០០២ ដល់ ១៥% ក្នុងឆ្នាំ ២០០៧។[34] លទ្ធផលនេះសបញ្ជាក់ឲ្យឃើញថា ស្ត្រីដែលទទួលបានការអប់រំ មានឱកាសកាន់តែច្រើនក្នុងការចូលរួមក្នុងសង្គម និងឆាកនយោបាយ ដែលអាចឲ្យស្ត្រីប្រាសចាកពីភាពក្រីក្រ ដឹកនាំជីវិតរបស់ពួកគាត់ទៅរកភាពរីកចម្រើន បង្កើនផលិតភាពកាន់តែច្រើន និងលើកកម្ពស់កម្រិតជីវភាពសម្រាប់កូនៗ ក្រុមគ្រួសារ និងសហគមន៍របស់ពួកគាត់ទាំងមូលផងដែរ។

## ១.៥. គោលនយោបាយក្នុងការអប់រំរបស់ស្ត្រី

### ១.៥.១. គោលនយោបាយក្នុងការអប់រំស្ត្រីរបស់ធនាគារពិភពលោក

ការធានាឲ្យក្មេងស្រីអាចទៅសាលារៀន និងបញ្ចប់ការសិក្សា ពិតជាមានសារៈសំខាន់ណាស់សម្រាប់ការកែលម្អជីវិតរបស់ពួកគាត់។ ក្មេងស្រីដែលទទួលបានអត្ថប្រយោជន៍ពីការអប់រំដែលមានគុណភាព អាចប្រែក្លាយជាមានសុខភាពល្អ និងបង្កើនផលិតភាពនៅពេលដែលពួកគាត់ពេញវ័យ។ ពួកគាត់នឹងមិនរៀបការនៅវ័យក្មេងទេ រហូតទាល់តែមានការងារល្អធ្វើ និងទទួលបានប្រាក់ចំណូលខ្ពស់។ ប៉ុន្តែភាពក្រីក្រនៅតែជាកត្តាសំខាន់ ដែលកំណត់ពីការសិក្សារបស់ក្មេងស្រី។ ការសិក្សាបានបង្ហាញថា ក្មេងស្រីដែលប្រឈមនឹងវិបត្តិច្រើនដូចជាមានកម្រិតប្រាក់ចំណូលក្នុងគ្រួសារទាប រស់នៅតាមតំបន់ដាច់ស្រយាល ឬកន្លែងដែលមិនមានការយកចិត្តទុកដាក់ មានពិការភាពឬជាក្រុមជនជាតិភាគតិច គឺមានលទ្ធភាពទាបបំផុតក្នុងការទទួលបានការអប់រំ។ ការអប់រំរបស់ក្មេងស្រី មិនត្រឹមតែផ្តល់ឲ្យពួកគាត់នូវមូលដ្ឋានដែលពួកគាត់ត្រូវការ ដើម្បីទទួលបានជោគជ័យប៉ុណ្ណោះទេ ប៉ុន្តែក៏ធ្វើឲ្យជីវភាពគ្រួសារ សហគមន៍ និងប្រជាជាតិដែលពួកគាត់រស់នៅមានភាពប្រសើរឡើងផងដែរ។

សមភាពយេនឌ័រ គឺជាចំនុចស្នូលដែលធនាគារពិភពលោកកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការបញ្ចប់ភាពក្រីក្រក្នុងសង្គម។ សង្គមមួយមិនអាចអភិវឌ្ឍទៅបានដោយស្ថេរភាព និងតម្លាភាព ដោយគ្មានការបែងចែកឱកាស ធនធាន និងជម្រើសរវាងបុរសនិងស្ត្រី ដើម្បីឲ្យពួកគាត់មានឱកាសដូចគ្នា មានឥទ្ធិពលលើជីវិតផ្ទាល់ខ្លួន និងចូលរួមចំណែកក្នុងគ្រួសារ សហគមន៍ និងប្រទេសនោះឡើយ។ ការលើកកម្ពស់ការអប់រំ

[34] URSULA WEKEMANN, *Women in Cambodia* https://core.ac.uk/download/pdf/154915211.pdf (ចូលទស្សនាថ្ងៃទី ១២ មិថុនា ២០២០)

របស់ក្មេងស្រី និងសមភាពយេនឌ័រ គឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរបស់ធនាគារពិភពលោក ដើម្បីធានាថាក្មេងស្រីមិនទទួលរងគ្រោះដោយសារភាពក្រីក្រ និងដើម្បីបង្កើនជំនាញនិងឱកាសការងារឲ្យស្ត្រី។

ដើម្បីលើកកម្ពស់ការអប់រំរបស់ស្ត្រីដែលជួបការលំបាក ធនាគារពិភពលោកបានផ្តោតការយកចិត្តទុកដាក់ទៅលើផ្នែកចំនួន ៥ ធំៗដែលមានដូចជា៖

**១. ការកសាងបរិស្ថានសិក្សាប្រកបដោយសុវត្ថិភាពសម្រាប់ក្មេងស្រី និងស្ត្រី**

បរិស្ថានសាលារៀនត្រូវតែឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ក្មេងស្រីនិងស្ត្រី ដោយរួមបញ្ចូលទាំងការអនុវត្តកម្មវិធីសិក្សា និងគរុកោសល្យ ការបណ្តុះបណ្តាលនិងគាំទ្រដល់គ្រូបង្រៀនជាស្ត្រី ដែលមានសមត្ថភាព និងធានានូវអនាម័យគ្រប់គ្រាន់នៅក្នុងបរិស្ថានសាលារៀន។

**២. ការផ្តល់ជំនួយជាសាច់ប្រាក់ដល់គ្រួសារក្រីក្រ ផ្តល់ប្រាក់ឈ្នួលសមរម្យដល់គ្រូបង្រៀន ឬផ្តល់អាហារូបករណ៍ដល់ស្ត្រី**

ការផ្តល់ជំនួយជាសាច់ប្រាក់ត្រូវបានប្រើប្រាស់ដោយជោគជ័យ ដើម្បីលើកទឹកចិត្តឪពុកម្តាយឲ្យបញ្ជូនកូនស្រីរបស់ពួកគាត់ទៅសាលារៀន ខណៈពេលដែលការផ្តល់ប្រាក់ខែសមរម្យ និងផ្តល់អាហារូបករណ៍ដល់ស្ត្រី អាចធ្វើឲ្យការចុះឈ្មោះចូលរៀន និងការបញ្ចប់ការសិក្សារបស់ស្ត្រីមានការកើនឡើង។

**៣. ការបញ្ចប់ការរារាំងក្មេងស្រីមិនឲ្យចូលសាលារៀន**

អំពើហិង្សាប្រឆាំងនឹងក្មេងស្រី និងស្ត្រី គឺជាឧបសគ្គដ៏ធំមួយចំពោះស្ត្រីក្នុងការទទួលបានការអប់រំ ដោយរួមមានអំពើហិង្សាផ្នែកអារម្មណ៍ រាងកាយ និងការរំលោភបំពានផ្លូវភេទ ដែលបង្ហាញពីការទទួលបានអំណាចមិនស្មើភាពគ្នារវាងស្ត្រី និង បុរស និងបទដ្ឋានវប្បធម៌។ លើសពីនេះទៀត ការរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេងពេករបស់ក្មេងស្រីអាចជាមូលហេតុក្នុងការបញ្ចប់ការអប់រំរបស់ក្មេងស្រីផងដែរ។ ដូច្នេះហើយ ធនាគារពិភពលោកបាននឹងកំពុងធ្វើការអប់រំសហគមន៍ គ្រួសាររបស់ក្មេងស្រី និងក្មេងប្រុសលើបញ្ហាទាំងនេះ និងដើម្បីលើកទឹកចិត្តដល់រដ្ឋាភិបាល និងមេភូមិ មេឃុំតាមមូលដ្ឋាន ដើម្បីប្រកាន់ជំហរប្រឆាំងនឹងទម្រង់នៃអំពើហិង្សាផ្នែកយេនឌ័រទាំងនេះ។

**៤. កាត់បន្ថយចម្ងាយទៅសាលារៀន**

នៅកន្លែងខ្លះវាអាចនឹងមិនមានសុវត្ថិភាពសម្រាប់ក្មេងស្រីក្នុងការធ្វើដំណើរទៅសាលារៀន។ ដូច្នេះហើយរាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធនានាត្រូវគិតគូរអំពីបញ្ហានេះ មុននឹងស្វែងរកទីតាំងដើម្បីបង្កើតសាលារៀន។ វាក៏ជាការចាំបាច់ផងដែរ ដើម្បីពិចារណាអំពីការផ្តល់មធ្យោបាយធ្វើដំណើរ ដើម្បីទៅដល់សាលារៀនរបស់ក្មេងស្រីដោយសុវត្ថិភាព។

**៥. ការបញ្ចប់អំពើហឹង្សាប្រឆាំងនឹងភេទនៅក្នុងសាលារៀន**

ភាពមិនស្មើភាពគ្នានៃអំណាច និងការរើសអើងយេនឌ័រនៅក្នុងសាលារៀន អាចលើកទឹកចិត្តឲ្យសិស្សមានឥរិយាបថមិនសមរម្យ និងលើកកម្ពស់អំពើហឹង្សាប្រឆាំងនឹងភេទ។ ដូច្នេះ យើងត្រូវផ្លាស់ប្តូរសាលារៀនឲ្យទៅជាកន្លែងដែលមានសុវត្ថិភាពសម្រាប់ក្មេងស្រី។ នេះអាចមានន័យថា លោកគ្រូ អ្នកគ្រូគួរតែបង្រៀនក្មេងស្រីឲ្យចេះឆ្លើយតបនឹងអំពើហិង្សាប្រឆាំងនឹងភេទ បង្កើតសាលារៀនដែលមានភេទតែមួយ ជួលគ្រូបង្រៀនជាស្ត្រីគំរូ មានបន្ទប់ទឹកដាច់ដោយឡែក និងផ្តល់ឧបករណ៍អនាម័យជាដើម។ វាក៏ទាមទារឲ្យមានការបង្កើនការយល់ដឹងអំពីបញ្ហា និងការផ្លាស់ប្តូរទស្សនៈនិងជំនឿរបស់សាលារៀន ឪពុកម្តាយ និងកុមារីខ្លួនឯងផងដែរ។ កម្មវិធីសិក្សា និងការអនុវត្តការបង្រៀន គួរតែជួយកុមារឲ្យរៀនពីអ្វីដែលត្រឹមត្រូវខណៈពេលដែលអ្នកដែលបានឆ្លងកាត់ការប៉ះទង្គិចផ្លូវចិត្ត គួរតែទទួលបានការគាំទ្រ និងជំនួយយ៉ាងត្រឹមត្រូវផងដែរ។[35]

**១.៥.២. គោលនយោបាយពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គម**

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺការពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គម ដើម្បីលើកស្ទួយស្ថានភាពសង្គម សេដ្ឋកិច្ច និងពង្រឹងតួនាទីស្ត្រី ដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ។ រាជរដ្ឋាភិបាលសម្រេចបាននូវសមិទ្ធិផលគួរឲ្យកត់សម្គាល់ ដោយបានបញ្ជ្រាបយេនឌ័រទៅក្នុងក្របខ័ណ្ឌគោលនយោបាយ និង ផែនការអភិវឌ្ឍជាតិ បានកាត់បន្ថយគម្រាតយេនឌ័រក្នុងវិស័យអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈមុខងារសាធារណៈ បានពង្រីកសហគ្រិនភាពរបស់ស្ត្រី បានកាត់បន្ថយអំពើហិង្សា និងការរំលោភបំពានផ្លូវភេទលើស្ត្រី និង កុមារី បានលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និង គ្រួសារខ្មែរ និង បានពង្រឹងកិច្ចការពារផ្លូវច្បាប់ដល់ស្ត្រី និងកុមារផងដែរ។

ដូច្នេះហើយ រាជរដ្ឋាភិបាលកម្ពុជាមានគោលដៅយុទ្ធសាស្ត្រច្បាស់លាស់ ក្នុងការពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គមនេះដោយបន្តលើកកម្ពស់តួនាទីស្ត្រី តាមរយៈការបង្កើនសមាមាត្រនិងពង្រឹងសមត្ថភាពស្ត្រីក្នុងជួរថ្នាក់ដឹកនាំទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័ន ទាំងកម្រិតនយោបាយ និងកម្រិតជំនាញ ព្រមទាំងបន្តជំរុញការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ និងផែនការអភិវឌ្ឍគ្រប់ផ្នែកគ្រប់វិស័យនិងគ្រប់កម្រិត បន្តលើកកម្ពស់សហគ្រិនភាពរបស់ស្ត្រី តាមរយៈការពង្រីកកម្មវិធីអប់រំ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់ស្ត្រី ព្រមទាំងបន្តលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ តាមរយៈ

[35] World Bank, *Girls' Education*
http://documents.worldbank.org/curated/en/924471541079772899/pdf/131634-BRI-girls-PUBLIC-Series-World-Bank-Education-Overview.pdf (ចូលទស្សនាថ្ងៃទី ១៤ មិថុនា ២០២០)

ការបង្កើនការវិនិយោគលើសមភាពយេនឌ័រ និងការពង្រឹងភាពជាដៃគូរវាងស្ថាប័នពាក់ព័ន្ធក្នុងការទប់ស្កាត់ការជួញដូរ និងអំពើហិង្សាលើស្ត្រី និងកុមារ។

ជាមួយគ្នានេះដែរ ក្រសួងកិច្ចការនារី ក៏បានចូលរួមបន្តការសម្របសម្រួលក្នុងការបញ្ជ្រាបយេនឌ័រក្នុងកម្មវិធី និងប្រព័ន្ធអប់រំ និងការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ព្រមទាំងលើកកម្ពស់ជីវភាពសេដ្ឋកិច្ចគ្រួសារនៅតាមសហគមន៍តាមរយៈ៖

- ការពង្រឹងសេវាអភិវឌ្ឍន៍សហគ្រិនភាព និងធុរកិច្ចរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី ប្រកបដោយភាពច្នៃប្រឌិត នវានុវត្តន៍ និងបរិយាប័ន្ន។
- ការបង្កើនកាលានុវត្តភាព បរិយាកាសមេត្រីភាព និងលទ្ធភាពឲ្យស្ត្រីទទួលបានការងារសមស្រប ការអភិវឌ្ឍជំនាញ បច្ចេកទេសនិងវិជ្ជាជីវៈ រួមទាំងបច្ចេកវិទ្យាឌីជីថល ទៅតាមតម្រូវការរបស់ស្ត្រី និងតម្រូវការទីផ្សារ ជាពិសេសបច្ចេកទេសកម្រិតស្តង់ដា។
- ការពង្រីកភាពជាដៃគូជាមួយវិស័យឯកជន និងដៃគូពាក់ព័ន្ធ ក្នុងការលើកកម្ពស់សហគ្រិនភាព និងអភិវឌ្ឍន៍សក្តានុពល បទពិសោធន៍ និងបច្ចេកទេសក្នុងការបង្កើនផលិតភាព គុណភាពផលិតផល និងអាចឈានចូលទៅកាន់ទីផ្សារជាតិ និងក្នុងតំបន់។
- ការបង្កើនការចូលរួមរបស់ស្ត្រី និងក្មេងស្រីក្នុងវិស័យអប់រំនៅកម្រិតខ្ពស់ ជាពិសេសពាក់ព័ន្ធនឹងការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈច្នៃប្រឌិត និងគណិតវិទ្យាស្តែមជាដើម។
- ការលើកកម្ពស់ការអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ គាំទ្រសហគ្រាសធុនតូច និងមធ្យម រួមទាំងមូលនិធិជាតិសហគ្រិនភាព និងមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនភាព ដែលឆ្លើយតបទៅនឹងសមភាពយេនឌ័រ។
- ការបន្តអនុវត្តយុទ្ធសាស្ត្រស្តីពីការចិញ្ចឹមកូនបែបវិជ្ជមាន ដែលឆ្លើយតបទៅនឹងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារ។[36]

[36] រាជរដ្ឋាភិបាលកម្ពុជា, *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣*, ទំព័រទី ២៥៧-២៥៩។

# ជំពូកទី ២

# ស្ថានភាពទូទៅរបស់ស្ត្រីបម្រើការងារនៅក្នុងរាជធានីភ្នំពេញ

# ជំពូកទី២

# ស្ថានភាពទូទៅរបស់ស្ត្រីបម្រើការងារនៅក្នុងរាជធានីភ្នំពេញ

## ២.១. ការអប់រំ និង មុខតំណែងរបស់ស្ត្រីបម្រើការងារនៅតាមស្ថាប័នក្នុងរាជធានីភ្នំពេញ

ក្នុងពេលបច្ចុប្បន្ននេះ យើងសង្កេតឃើញថាការចូលរួមចំណែករបស់ស្ត្រី នៅគ្រប់វិស័យទាំងអស់ដូចជាវិស័យការងារ វិស័យអប់រំ វិស័យសុខាភិបាល វិស័យឧស្សាហកម្ម វិស័យសេវាកម្ម វិស័យកសិកម្មជាដើម ជាផ្នែកមួយយ៉ាងសំខាន់ក្នុងការលើកកម្ពស់សេដ្ឋកិច្ចជាតិឲ្យមានការរីកចម្រើនគួរឲ្យកត់សម្គាល់បើប្រៀបធៀបទៅនឹងសម័យមុនៗដែលស្ត្រីពុំមានលទ្ធភាពក្នុងការចូលរួមចំណែកក្នុងវិស័យទាំងនេះឡើយ ដោយហេតុថាសង្គមខ្មែរពីមុនប្រកាន់យកប្រពៃណីទំនៀមទម្លាប់ ដែលឲ្យស្ត្រីនៅតែក្នុងផ្ទះ ចាំមើលថែរក្សាគ្រួសារ និងបម្រើប្តីរបស់ខ្លួន និងពឹងផ្អែកទាំងស្រុងទៅលើប្តីដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ។ ម្យ៉ាងវិញទៀត ការអប់រំរបស់ស្ត្រីក៏មិនត្រូវបានសង្គម ព្រមទាំងក្រុមគ្រួសារឲ្យតម្លៃ ទើបធ្វើឲ្យស្ត្រីមានភាពល្ងង់ខ្លៅ មិនយល់ដឹងពីសិទ្ធិរបស់ខ្លួន មិនអាចរកការងារបានសមរម្យធ្វើ មិនមានមុខតំណែងខ្ពស់ក្នុងវិស័យការងារ និងមិនមានលទ្ធភាពក្នុងការរើបម្រាស់ពីការគាបសង្កត់ពីភាគីទាំងនេះឡើយ។ យ៉ាងណាមិញ ក្នុងពេលបច្ចុប្បន្នការផ្តល់តម្លៃដល់ការអប់រំរបស់ស្ត្រីត្រូវបានរាជរដ្ឋាភិបាល ក្រសួងពាក់ព័ន្ធនានា ជាពិសេសអង្គការក្រៅរដ្ឋាភិបាលយកចិត្តទុកដាក់យ៉ាងខ្លាំង ដោយភាគីទាំងនេះព្យាយាមលើកទឹកចិត្តឲ្យស្ត្រីទទួលបានការអប់រំខ្ពស់ លុបបំបាត់ការរើសអើងស្ត្រី និងផ្តល់ឱកាសឲ្យស្ត្រីទទួលបានសិទ្ធិ និងការងារដែលស្មើភាពទៅនឹងបុរស។

បើតាមរបាយការណ៍នៃការអង្កេតអំពីសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា របស់វិទ្យាស្ថានជាតិស្ថិតិនៅកម្ពុជាក្នុងឆ្នាំ ២០១៧ បានឲ្យដឹងថា កុមារីដែលមានអាយុចាប់ពី ៦ ឆ្នាំឡើងទៅមានឱកាសទទួលបានការអប់រំ និងអាចអាននិងសរសេរបាន មានរហូតទៅដល់ ៩០,៩% ដែលរស់នៅក្នុងរាជធានីភ្នំពេញ ដែលចំនួននេះមានអត្រាខ្ពស់ជាងគេ បើប្រៀបធៀបទៅនឹងតំបន់ភូមិសាស្ត្រនានាក្នុងប្រទេសកម្ពុជា។ ចំណែកស្ត្រីវ័យជំទង់ដែលមានអាយុចាប់ពី ១៥ឆ្នាំឡើងទៅ ក៏មានអត្រារហូតដល់ ៩១,៩% ផងដែរ។[37] នេះសបញ្ជាក់ឲ្យឃើញថាការអប់រំរបស់ស្ត្រី និងកុមារីមានការកើនឡើងគួរឲ្យកត់សម្គាល់ បើប្រៀបធៀបទៅនឹងសម័យមុន។ ម្យ៉ាងវិញទៀត យើងក៏សង្កេតឃើញពីការកើនឡើងនៃចំនួនស្ត្រីបម្រើការងារនៅតាមស្ថាប័ននានា នៅក្នុងរាជធានីភ្នំពេញផងដែរ ពោលគឺស្ត្រីដែលទទួលបានការអប់រំខ្ពស់ មានមុខរបរនិងមុខតំណែង ដូចជាគណនេយ្យករ អ្នកបម្រើ

[37] វិទ្យាស្ថានជាតិស្ថិតិនៅកម្ពុជា, *ការអង្កេតអំពីសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ ២០១៧* https://www.nis.gov.kh/nis/CSES/Final%20Report%20CSES%202017.pdf (ចូលទស្សនាថ្ងៃទី០៧ មិថុនា ២០២០)

សេវាអតិថិជន គ្រូបង្រៀន វិស្វករ អ្នកធ្វើការក្នុងភោជនីយដ្ឋាន និងអ្នករចនាម៉ូតជាដើម ដែលអាចឲ្យពួកគាត់ចូលរួមលើកកម្ពស់សេដ្ឋកិច្ចគ្រួសាររបស់ពួកគាត់ឲ្យកាន់តែប្រសើរឡើងបាន។

### ២.១.១. ការអប់រំរបស់ស្ត្រីបម្រើការងារនៅតាមស្ថាប័នក្នុងរាជធានីភ្នំពេញ

យោងតាមការធ្វើជំរឿនឆ្នាំ ២០០៨ ពីប្រជាជនដែលអាចអាននិងសរសេរបាន បានរកឃើញថាស្ត្រីដែលរស់នៅក្នុងទីក្រុងដែលមានអាយុចន្លោះពី ១៥ ទៅ ២៤ ឆ្នាំដែលអាចអាននិងសរសេរបាន គឺមានរហូតដល់ ៩៤,៣% ចំណែកស្ត្រីដែលមានអាយុចន្លោះពី ២៥ ទៅ ៣៤ ឆ្នាំ មានចំនួន ៩០,៤% រីឯស្ត្រីដែលមានអាយុចាប់ពី ៣៥ ឆ្នាំឡើងទៅ គឺមានចំនួនជាង ៨០% ដែលចំនួនទាំងនេះមានការកើនឡើងគួរឲ្យកត់សម្គាល់បើប្រៀបធៀបទៅនឹងជំរឿនក្នុងឆ្នាំ១៩៩៨។[38]ម្យ៉ាងវិញទៀតបើយោងតាមស្ថិតិ និងសូចនាករអប់រំសាធារណៈឆ្នាំ ២០១៦-២០១៧ របស់ក្រសួងអប់រំ យុវជន និងកីឡាបានឲ្យដឹងថា ចំនួនសិស្សស្រីនៅក្នុងរាជធានីភ្នំពេញដែលបានបញ្ចប់ថ្នាក់បឋមសិក្សា (ថ្នាក់ទី១-៦) មានចំនួន ៩៥,៥% ឯសិស្សស្រីដែលបានបញ្ចប់ថ្នាក់មធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី៧-៩) មានចំនួន ៨៦,៥% និងចំនួនសិស្សស្រីដែលបានបញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១០-១២) មានចំនួន ៨៥,១% រីឯចំនួននិស្សិតស្រីដែលកំពុងសិក្សានៅកម្រិតឧត្តមសិក្សានៅតាមស្ថាប័ននានានៅក្នុងរាជធានីភ្នំពេញមានចំនួន ៤៨,៣៧% ដែលចំនួននេះមានការកើនឡើងខ្លាំងបើធៀបនឹងសម័យមុន។[39]

### ២.១.២. កត្តាដែលជំរុញឲ្យស្ត្រីទទួលបានមុខតំណែងនេះ

កត្តាដែលលើកទឹកចិត្តឲ្យស្ត្រីទទួលបានការងារនិងមុខតំណែងក្នុងទីផ្សារការងារបែបនេះគឺដោយសារតែពួកគាត់ចង់លើកស្ទួយគ្រួសារឲ្យចាកចេញពីភាពក្រីក្រ និងចង់បានជីវភាពប្រសើរជាងមុន ហើយពួកគាត់ចង់បានប្រាក់ចំណូលខ្ពស់ ដែលអាចផ្គត់ផ្គង់តម្រូវការចាំបាច់សម្រាប់ខ្លួនឯង និងក្រុមគ្រួសាររបស់ពួកគាត់បាន។ ម្យ៉ាងវិញទៀត ដោយឃើញថាតាំងពីសម័យបុរាណមក សង្គមខ្មែរមិនសូវឲ្យតម្លៃស្ត្រី និងទទួលស្គាល់ពីការខិតខំប្រឹងប្រែងរបស់ស្ត្រីទើបពួកគាត់ចង់លុបបំបាត់ទស្សនៈអវិជ្ជមានទាំងនោះចោល ព្រមទាំងបដិសេធនូវទស្សនៈដែលលើកឡើងថា "ស្ត្រីជាភេទទន់ខ្សោយ" មិនអាចធ្វើការងារដូចទៅនឹងបុរសបាន។ លើសពីនេះទៅទៀត ស្ត្រីក៏ចង់លើកស្ទួយឲ្យគ្រួសាររបស់ពួកគាត់មានកិត្តិយស និងមានភាពថ្លៃថ្នូរនៅក្នុងសង្គមផងដែរ។ ដោយសារតែស្ត្រីយល់ដឹងពីអត្ថប្រយោជន៍ដែលពួកគាត់អាចទទួលបាន ពីការដែលមានមុខតំណែងច្បាស់

[38] *Literacy and Education* ដកស្រង់ពី https://www.stat.go.jp/info/meetings/cambodia/pdf/rp13_ch50.pdf (ចូលទស្សនាថ្ងៃទី ១៥ ខែសីហា ឆ្នាំ២០២០)

[39] ក្រសួងអប់រំយុវជន និងកីឡា *ស្ថិតិ និងសូចនាករអប់រំសាធារណៈឆ្នាំ ២០១៦-២០១៧*

លាស់ក្នុងសង្គមទាំងនេះហើយ ទើបជំរុញឲ្យពួកគាត់ខិតខំប្រឹងប្រែងក្រេបជញ្ជក់យកចំណេះវិជ្ជាឲ្យបានខ្ពង់ខ្ពស់ និងស្វែងរកការងារល្អៗធ្វើបែបនេះ។

### ២.១.៣. បញ្ហាប្រឈមនៃការទទួលបានមុខតំណែងនេះ

ទន្ទឹមនឹងការទទួលបានអត្ថប្រយោជន៍ជាច្រើនពីមុខតំណែង និងការអប់រំរបស់គាត់ ស្ត្រីក៏បានជួបនូវបញ្ហាប្រឈមមួយចំនួននៅពេលប្រកបការងារទាំងនេះផងដែរ។ បញ្ហាប្រឈមចម្បងដែលពួកគាត់ជួបប្រទះគឺពួកគាត់មិនមានពេលវេលាសម្រាកគ្រប់គ្រាន់ ពីព្រោះពួកគាត់ត្រូវចេញទៅធ្វើការពេញម៉ោង តាំងពីព្រឹករហូតដល់ពេលសៀលទើបពួកគាត់បានត្រលប់មកផ្ទះវិញ ហើយនៅពេលមកដល់ផ្ទះ ស្ត្រីត្រូវរៀបចំផ្ទះសម្បែងព្រមទាំងអាហារពេលល្ងាចជូនក្រុមគ្រួសារ មុននឹងពួកគាត់អាចសម្រាកបាន ពោលគឺនៅពេលដែលស្ត្រីចូលរួមធ្វើការងារដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារឲ្យកាន់តែប្រសើរឡើង នោះបន្ទុករបស់ពួកគាត់ក៏កាន់តែធ្ងន់ជាងមុនផងដែរ ដោយសារពួកគាត់ត្រូវទទួលខុសត្រូវទាំងការរកចំណូល និងការងារក្នុងផ្ទះ។ ម្យ៉ាងវិញទៀត ការប្រកបការងារទាំងនេះធ្វើឲ្យស្ត្រីពុំសូវមានពេលវេលាជួបជុំគ្រួសារបានច្រើននោះទេ។ បញ្ហានេះបានធ្វើឲ្យស្ត្រីមិនសូវមានភាពជិតស្និទ្ធ និងមិនមានពេលវេលាផ្តល់ភាពកក់ក្តៅដល់ក្រុមគ្រួសារ ជាពិសេសកូនៗរបស់ពួកគាត់ ព្រមទាំងមិនសូវមានពេលយកចិត្តទុកដាក់នឹងការសិក្សារបស់កូនគាត់ផងដែរ។

### ២.១.៤. ជីវភាពគ្រួសាររបស់ស្ត្រីបម្រើការងារនៅតាមស្ថាប័នក្នុងរាជធានីភ្នំពេញ

បើទោះបីជាយើងសង្កេតឃើញថា ក្នុងពេលបច្ចុប្បន្ននេះ ស្ត្រីបានចូលរួមចំណែកច្រើនក្នុងការផ្គត់ផ្គង់ជីវភាពគ្រួសារក៏ដោយ ក៏ប្រាក់ចំណូលរបស់ពួកគាត់ភាគច្រើននៅតែមិនគ្រប់គ្រាន់ ដើម្បីរស់នៅក្នុងជីវភាពដ៏ប្រសើរមួយនៅឡើយទេ។ ម្យ៉ាងវិញទៀត ការសិក្សានាពេលថ្មីៗនេះបានរកឃើញថា ស្ត្រីវ័យក្មេងនៅក្នុងប្រទេសកម្ពុជារកចំណូលបានតិចជាងបុរស បើទោះបីជាស្ត្រីមានភាគរយខ្ពស់ក្នុងការប្រកបការងារក៏ដោយ។ នេះសបញ្ជាក់ឲ្យឃើញថាការរើសអើងស្ត្រីនៅតែមាននៅក្នុងសង្គមខ្មែរ ដោយភាគច្រើនគឺទាក់ទងនឹងកម្រិតនៃការអប់រំរបស់ស្ត្រី។ យោងតាមការស្រាវជ្រាវបានឲ្យដឹងថា សម្រាប់សិស្សនិស្សិតដែលបានបញ្ចប់ការសិក្សានៅបឋមសិក្សា អនុវិទ្យាល័យ និងឧត្តមសិក្សាដែលជាស្ត្រីនៅក្នុងប្រទេសកម្ពុជា អាចរកចំណូលបានប្រហែលពី ៣០% ទៅ ៥០% ប៉ុណ្ណោះ ដែលចំនួននេះតិចជាងបុរស ២០%។[40]

យោងតាមរបាយការណ៍នៃការអង្កេតអំពីសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា របស់វិទ្យាស្ថានជាតិស្ថិតិនៅកម្ពុជាក្នុងឆ្នាំ ២០១៧ បានរកឃើញថា នៅក្នុងរាជធានីភ្នំពេញប្រភពចំណូលសំខាន់របស់គ្រួសារនីមួយៗ គឺ

[40] ភ្នំពេញប៉ុស្តិ៍, *ការព្រួយបារម្ភអំពីគម្លាតនៃប្រាក់ចំណូលរវាងយេនឌ័រ*, ១២ កុម្ភៈ ២០១៦
https://www.phnompenhpost.com/national/gender-wage-gap-daunting (ចូលទស្សនាថ្ងៃទី១០ មិថុនា ២០២០)

បានមកពីប្រាក់ឈ្នួលនិងប្រាក់ខែ។ ស្ត្រីនៅក្នុងរាជធានីភ្នំពេញរកប្រាក់ចំណូលបានជាមធ្យមបន្ទាប់ពីកាត់ពន្ធផ្សេងៗហើយចំនួន ៦១២,០០០រៀល ដែលស្មើនឹង ១៥៣ដុល្លារ ក្នុងមួយខែ បើប្រៀបធៀបទៅនឹងបុរសដែលរកបានជាមធ្យម ៦៥៧,០០០រៀល ដែលស្មើនឹង ១៦៤.២៥ដុល្លារ ក្នុងមួយខែ ដែលគំលាតនៃប្រាក់ចំណូលទាំងនេះ គឺបណ្ដាលមកពីឧបសគ្គនៅក្នុងគ្រួសាររបស់ស្ត្រី ដូចជាការដែលពួកគាត់ត្រូវរៀបអាពាហ៍ពិពាហ៍នៅក្នុងវ័យក្មេង ការមានបន្ទុកធ្ងន់នៅក្នុងគ្រួសារ ឬការដែលពួកគាត់ត្រូវមានផ្ទៃពោះ និងការទទួលបានមុខតំណែងទាបនៅក្នុងវិស័យដែលមានប្រាក់ខែតិចតួចជាដើម។[41]

## ២.២. ការអប់រំ និងមុខដំណែងរបស់ស្ត្រីបម្រើការងារក្នុងរោងចក្រកាត់ដេរ

ប្រទេសកម្ពុជាបានចាប់ផ្ដើមចូលរួមចំណែកយ៉ាងសកម្មក្នុងវិស័យកាត់ដេរ ដែលជាវិស័យឧស្សាហកម្មធំបំផុតតែមួយគត់របស់ប្រទេសនេះក្រោយពីការដួលរលំនៃរបបខ្មែរក្រហម។ នៅឆ្នាំ២០១៤ វិស័យកាត់ដេរបានចូលរួមចំណែករហូតដល់ ៧៩% នៃកម្ពុជាប្រទេសរបស់សរុបផលិតផលនាំចេញ។ [42] សង្កេតឃើញថាឃើញមូលដ្ឋាននៃកំណើនសេដ្ឋកិច្ចនេះ គឺពឹងផ្អែកទៅលើស្ថេរភាពនយោបាយ ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ហេដ្ឋារចនាសម្ព័ន្ធ និងធនធានមនុស្ស។ ក្នុងនោះដែរស្ត្រីចំនួនជាងពាក់កណ្ដាលនៃចំនួនប្រជាជនសរុបជាធនធានមនុស្សដែលដើរតួនាទីយ៉ាងសំខាន់ ក្នុងការចូលរួមក្នុងកម្លាំងសេដ្ឋកិច្ច តាមរយៈបញ្ញា ជំនាញ និងសមត្ថភាព បើប្រៀបធៀបទៅនឹងបុរស ឬអាចមានចំនួនច្រើនជាងបុរសទៅទៀត នៅក្នុងវិស័យមួយចំនួនផងដែរ។ ប៉ុន្តែគួរឲ្យកត់សម្គាល់ដែរថា នៅប្រទេសកម្ពុជា ជម្រើសការងារសម្រាប់ស្ត្រីនៅមានចំនួនតិចតួចនៅឡើយ លើកលែងតែក្នុងវិស័យកាត់ដេរ។ ដូច្នេះហើយដើម្បីផ្គត់ផ្គង់ស្ថានភាពសេដ្ឋកិច្ចនៅក្នុងគ្រួសារ ស្ត្រីមួយចំនួនធំត្រូវបង្ខំចិត្តផ្លាស់ទីមកនៅទីក្រុង ដើម្បីធ្វើការក្នុងរោងចក្រ ដោយសារតែពួកគាត់ពុំសូវមានចំណេះដឹងជ្រៅជ្រះ។ ដូច្នេះហើយទើបវិស័យកាត់ដេរសម្លៀកបំពាក់នៅកម្ពុជា ជាវិស័យដ៏សំខាន់មួយដែលរួមចំណែកក្នុងការជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា តាមរយៈការនាំចេញ និងការផ្ដល់ឱកាសការងារដល់ប្រជាជន និងជាពិសេសស្ត្រីរាប់សែននាក់នៅក្នុងប្រទេសកម្ពុជា។[43]

### ២.២.១. ការអប់រំរបស់ស្ត្រីបម្រើការងារក្នុងរោងចក្រកាត់ដេរ

ស្ត្រីដែលបម្រើការងារនៅក្នុងរោងចក្រដែលយើងខ្ញុំបានចុះធ្វើសម្រង់មតិផ្ទាល់ បានឲ្យដឹងថា ក្នុង

[41] វិទ្យាស្ថានជាតិស្ថិតិនៅកម្ពុជា, *ការអង្កេតអំពីសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ ២០១៧* https://www.nis.gov.kh/nis/CSES/Final%20Report%20CSES%202017.pdf (ចូលទស្សនាថ្ងៃទី១៥ មិថុនា ២០២០)

[42] CNV internationaal, *Our work where we work*, https://www.cnvinternationaal.nl/en/our-work/where-we-work/asia/cambodja (ចូលទស្សនាថ្ងៃទី១៧ មិថុនា ២០២០)

[43] VOA, *Women's Garment Workers* https://www.voacambodia.com/ (ចូលទស្សនាថ្ងៃទី១៧ មិថុនា ២០២០)

ចំណោមស្ត្រី ៥០នាក់ដែលធ្វើការនៅក្នុងរោងចក្រនេះ មានចំនួនស្ត្រីប្រហែលជា ៤% បាននិយាយថាពួកគាត់មិនធ្លាប់ទទួលបានការអប់រំទាល់តែសោះ ដោយសារតែជីវភាពក្រីក្រ ឪពុកម្ដាយរបស់ពួកគាត់មិនមានលទ្ធភាពឲ្យពួកគាត់បានរៀនសូត្រ ទើបពួកគាត់ត្រូវបង្ខំចិត្តមកធ្វើជាកម្មការនីរោងចក្រដើម្បីរកចំណូលជួយផ្គត់ផ្គង់ជីវភាពគ្រួសារ។ ចំណែកឯស្ត្រីដែលទទួលបានការអប់រំត្រឹមកម្រិតបឋមសិក្សា (ថ្នាក់ទី១-៦) មានចំនួន ២៤% រីឯស្ត្រីដែលទទួលបានការអប់រំត្រឹមកម្រិតមធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី៧-៩) មានចំនួន ៤០% ដែលកម្រិតនេះជាកម្រិតនៃការអប់រំដែលស្ត្រីជាកម្មការនីរោងចក្រភាគច្រើនទទួលបាន។ យ៉ាងណាមិញ ចំនួនស្ត្រីដែលបានបញ្ចប់កម្រិតមធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១០-១២) មានការថយចុះវិញជិតពាក់កណ្ដាលនៃចំនួនស្ត្រីដែលបានបញ្ចប់កម្រិតមធ្យមសិក្សាបឋមភូមិដែលមានត្រឹមតែ ២៤% តែប៉ុណ្ណោះ។

### ២.២.២. កត្តាដែលជម្រុញឲ្យទទួលបានមុខតំណែងនេះរបស់ស្ត្រី

ស្ត្រីដែលបម្រើការងារនៅក្នុងរោងចក្រកាត់ដេរ ភាគច្រើនគឺពុំសូវទទួលបានការអប់រំ ដូចទៅនឹងស្ត្រីដែលបម្រើការងារនៅតាមបណ្ដាស្ថាប័ននានាឡើយ។ វាមានកត្តាជាច្រើនដែលជម្រុញឲ្យស្ត្រីបម្រើការងារនៅក្នុងវិស័យកាត់ដេរ ដែលក្នុងនោះគឺដោយសារតែស្ត្រីចង់បានជីវភាពមួយដ៏ល្អប្រសើរជាងមុន។ យ៉ាងហោចណាស់ពួកគាត់អាចចូលរួមចំណែកក្នុងការរកប្រាក់ចំណូលបន្ថែម ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារដោយមិនចាំបាច់ពឹងពាក់ទាំងស្រុងទៅលើស្វាមី ឬក៏បុគ្គលតែម្នាក់ដើម្បីរកចំណូលឡើយ។ បន្ថែមពីលើនេះទៀត ស្ត្រីចង់ជួយក្រុមគ្រួសាររបស់ពួកគាត់ក្នុងការកាត់បន្ថយការចំណាយតែមួយមុខ ពោលគឺស្វែងរកប្រាក់ចំណូលបន្ថែមសម្រាប់ក្រុមគ្រួសាររបស់ពួកគាត់ ដើម្បីឲ្យគ្រួសារគាត់មានលទ្ធភាពទិញរបស់របរប្រើប្រាស់ចាំបាច់សម្រាប់ការរស់នៅប្រចាំថ្ងៃផងដែរ។ ម្យ៉ាងវិញទៀត ស្ត្រីចង់ជួយសង្គម នៅពេលដែលពួកគាត់មានប្រាក់ចំណូលគ្រប់គ្រាន់ នោះពួកគាត់អាចចូលរួមកាត់បន្ថយភាពក្រីក្រដែលពួកគាត់បានជួបប្រទះនៅក្នុងសង្គមបាន ហើយស្ត្រីក៏ចង់ចូលរួមក្នុងឆាកនយោបាយផងដែរ ដើម្បីឲ្យពួកគាត់បានយល់ដឹងពីគោលការណ៍ និងច្បាប់នានានៅក្នុងអំឡុងពេលបម្រើការងារ។ ជាពិសេសទៅទៀតនោះ ស្ត្រីចង់ឲ្យសង្គមទទួលស្គាល់ពីតម្លៃរបស់ពួកគាត់ថាពួកគាត់ក៏អាចរកចំណូលបានដោយមិនពឹងផ្អែកទាំងស្រុងទៅលើស្វាមីរបស់ខ្លួនបានដែរ។

### ២.២.៣. បញ្ហាប្រឈមនៃការទទួលបានមុខតំណែងនេះ

ថ្វីត្បិតតែវិស័យកាត់ដេរនៅប្រទេសកម្ពុជា មានការរីកចម្រើនពីមួយឆ្នាំទៅមួយឆ្នាំក៏ពិតមែន ក៏ប៉ុន្តែស្ត្រីដែលជាកម្មការនីរោងចក្រ នៅតែជួបប្រទះនូវបញ្ហាប្រឈមនានា ដែលមានដូចជា ការទទួលបានប្រាក់បៀវត្សរ៍ទាប គម្លាតនៃប្រាក់ឈ្នួលនៅពេលបែងចែកពីម្ចាស់រោងចក្រមិនមានសមភាព សុខភាពចុះទ្រុឌទ្រោមដោយសារតែពួកគាត់ត្រូវចាយវាយមានកម្រិត ទើបបណ្ដាលឲ្យរបបអាហារដែលពួកគាត់បរិភោគពុំសូវ

គ្រប់គ្រាន់និងពុំសូវមានអនាម័យ មានពេលវេលាសម្រាកបានតិច មានពេលវេលាជួបជុំគ្រួសារបានតិច មធ្យោបាយធ្វើដំណើរពុំសូវមានសុវត្ថិភាព ដោយពួកគាត់ត្រូវឈរនៅលើរថយន្តដែលមានផ្ទុកកម្មករកម្មការនីរោងចក្រជាច្រើននាក់ បរិយាកាសនៅក្នុងរោងចក្រមានភាពអាប់អួរ មិនសូវមានខ្យល់ចេញចូលគ្រប់គ្រាន់ បញ្ហាសុវត្ថិភាពនៅពេលកំពុងបំពេញការងារ និងកិច្ចសន្យាការងារដែលបានផ្តល់អត្ថប្រយោជន៍ដល់ពួកគាត់មានភាពតិចតួចផងដែរ។[44]

### ២.២.៤. ជីវភាពគ្រួសាររបស់ស្ត្រីបម្រើការងារក្នុងរោងចក្រកាត់ដេរ

ស្ត្រីដែលកំពុងបម្រើការងារនៅក្នុងរោងចក្រកាត់ដេរភាគច្រើនមានវ័យក្មេង និងបានធ្វើចំណាកស្រុកមកធ្វើជាកម្មការនីរោងចក្រនៅទីក្រុង ដោយពួកគាត់ត្រូវរស់នៅ និងធ្វើការងារឆ្ងាយពីផ្ទះ និងទីកន្លែងកំណើតរបស់ពួកគាត់។ យើងសង្កេតឃើញថា ៦៦% ការនៃស្ត្រីដែលជាកម្មនីរោងចក្រ គឺមានអាយុក្រោម ៣០ ឆ្នាំ ដែល ៥១% គឺបានរៀបការរួច និង ៦៤% នៃស្ត្រីដែលជាកម្មការនីរោងចក្រនៅក្នុងប្រទេសកម្ពុជា គឺជាអ្នកចំណាកស្រុក ហើយជាក់ស្តែងរោងចក្រកាត់ដេរនៅក្នុងរាជធានីភ្នំពេញ មានស្ត្រីដែលបានចំណាកស្រុកពីជនបទមកធ្វើជាកម្មការនីរោងចក្រនៅទីក្រុងមានរហូតដល់ ៩៧%។

យ៉ាងណាមិញ យើងក៏សង្កេតឃើញថា ស្ត្រីដែលជាកម្មការនីរោងចក្រទទួលបានប្រាក់ចំណូលជាមធ្យមតិចជាងបុរសដែលជាកម្មករដូចគ្នាដែរ។ ប្រាក់ខែចម្បងជាមធ្យមក្នុងឆ្នាំ ២០១៥ សម្រាប់ស្ត្រីដែលជាកម្មការនីរោងចក្រគឺទទួលបាន ១៤៥ ដុល្លារ ក្នុងមួយខែ ចំណែកឯបុរសទទួលបាន ១៦១ ដុល្លារ ក្នុងមួយខែ។ ចំពោះប្រាក់ខែដែលទទួលបានបន្ទាប់ពីពួកគាត់បានធ្វើការថែមម៉ោងនិងបានមកពីអត្ថប្រយោជន៍ផ្សេងៗ ស្ត្រីទទួលបានតែ ២០៩ ដុល្លារប៉ុណ្ណោះ ក្នុងមួយខែ រីឯបុរសទទួលបានរហូតដល់ ២២៨ ដុល្លារ ក្នុងមួយខែ។

ជាក់ស្តែងស្ត្រីដែលបម្រើការងារនៅក្នុងរោងចក្រកាត់ដេរ ជាទូទៅតែងតែបានផ្ញើរប្រាក់ចំណូលជាមធ្យម ៤០% នៃប្រាក់ឈ្នួលដែលទទួលបានជារៀងរាល់ខែ មកឲ្យគ្រួសារនៅឯជនបទ ដើម្បីផ្គត់ផ្គង់តម្រូវការចាំបាច់នៅក្នុងគ្រួសាររបស់គាត់ដែលមានដូចជា ម្ហូបអាហារប្រចាំថ្ងៃ និងការថែទាំសុខភាពជាដើម។ ដោយសារតែស្ត្រីទទួលបានប្រាក់ខែតិចតួច ហើយត្រូវផ្ញើរមកឲ្យគ្រួសាររបស់ខ្លួនទៀតនោះ ទើបបណ្តាលឲ្យស្ត្រីដែលជាកម្មការនីរោងចក្រភាគច្រើន ត្រូវរស់នៅដោយភាពសន្សំសំចៃ និងភាពខ្វះខាតក្នុងការផ្គត់ផ្គង់ចំណាយចាំបាច់សម្រាប់ខ្លួនឯង។[45]

---

[44] សម្ព័ន្ធសហជីពកម្ពុជា, *ឧបសគ្គក្នុងការធ្វើការងាររោងចក្រ* http://thecatu.blogspot.com/ (ចូលទស្សនាថ្ងៃទី១៨ មិថុនា ២០២០)

[45] CARE organization, *Factory workers in Cambodia* www.care.org.au (ចូលទស្សនាថ្ងៃទី១៩ មិថុនា ២០២០)

## ២.៣. ការលើកទឹកចិត្តឲ្យស្ត្រីទទួលបានការអប់រំ

យើងសង្កេតឃើញថា ក្នុងពេលបច្ចុប្បន្នប្រទេសកម្ពុជាកំពុងតែធ្វើការយ៉ាងសស្រាក់សស្រាំនៅក្នុងការលើកទឹកចិត្តឲ្យស្ត្រីទទួលបានការអប់រំ តាមរយៈការបង្កើតច្បាប់ គោលនយោបាយ ផែនការ និងរចនាសម្ព័ន្ធថ្នាក់ជាតិដ៏រឹងមាំសម្រាប់គាំទ្រនិងលើកកម្ពស់វិស័យអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈផ្សេងៗសម្រាប់ស្ត្រី។ ដើម្បីលើកកម្ពស់វិស័យទាំងនេះឲ្យកាន់តែរីកចម្រើន យើងត្រូវការការចូលរួមយ៉ាងសំខាន់ពីភាគីពាក់ព័ន្ធមួយចំនួនដូចជា ស្ត្រីខ្លួនឯងផ្ទាល់ គ្រួសាររបស់ស្ត្រី សង្គម និងរាជរដ្ឋាភិបាល ដែលអាចលើកទឹកចិត្តឲ្យស្ត្រីទទួលបានការអប់រំខ្ពស់។

### ២.៣.១. ស្ត្រីខ្លួនឯងផ្ទាល់

ស្ត្រីខ្លួនឯងផ្ទាល់ គឺជាភាគីដែលសំខាន់បំផុតក្នុងការជំរុញខ្លួនឯងឲ្យទទួលបានការអប់រំ និងស្វះស្វែងរកចំណេះវិជ្ជាមកដាក់ក្នុងខ្លួន ទាំងនៅក្នុង និងក្រៅសាលារៀន និងជាភាគីដែលអាចលើកទឹកចិត្តខ្លួនឯង មិនឲ្យបោះបង់ការសិក្សាចោលពាក់កណ្តាលទី អាចជំនះរាល់ឧបសគ្គដែលបានជួបប្រទះមិនថាតូច ឬ ធំដោយព្យាយាមឲ្យអស់លទ្ធភាពដើម្បីដោះស្រាយនូវបញ្ហាទាំងនោះ។ ម្យ៉ាងវិញទៀត ស្ត្រីត្រូវចេះបណ្តុះស្មារតីរឹងមាំ អត់ធ្មត់ និងតស៊ូ ដើម្បីសម្រេចគោលដៅដែលខ្លួនចង់បាន ត្រូវមានភាពក្លាហាន ហ៊ានបញ្ចេញមតិ និងហ៊ានតវ៉ាប្រឆាំងនូវរាល់សកម្មភាពដែលមិនឲ្យតម្លៃទៅលើការអប់រំរបស់ស្ត្រី ត្រូវចេះចាប់យកឱកាសដែលអាចផ្តល់អត្ថប្រយោជន៍ដល់ខ្លួនឯង ដូចជាការចូលរួមប្រកួតប្រជែងដណ្តើមយកអាហារូបករណ៍ ដែលបានផ្តល់ឲ្យដោយរាជរដ្ឋាភិបាល ដើម្បីទៅសិក្សានៅក្នុង និងក្រៅប្រទេសជាដើម។

### ២.៣.២. គ្រួសាររបស់ស្ត្រី

ទន្ទឹមនឹងនេះដែរ គ្រួសាររបស់ស្ត្រីផ្ទាល់ក៏ចូលរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញឲ្យស្ត្រីទទួលបានការអប់រំផងដែរ។ ជាក់ស្តែង មាតាបិតាគ្រប់រូបគួរតែផ្តល់ឱកាសឲ្យកូនរបស់ពួកគាត់ទទួលបានការសិក្សាពេញលេញ និងអាចចូលរៀនតាំងពីកុមារនៅក្មេងវ័យ។ គ្រួសារត្រូវផ្តល់ភាពកក់ក្តៅឲ្យកូនៗ ដោយមិនត្រូវប្រព្រឹត្តនូវអំពើហិង្សានានា ដែលអាចជះឥទ្ធិពលអវិជ្ជមានលើការសិក្សារបស់កូនៗឡើយ។ មាតាបិតាក៏ត្រូវចេះតាមដាននូវរាល់សកម្មភាពនៃការសិក្សារបស់កូនៗផងដែរ ដើម្បីឲ្យដឹងថាកូនៗរបស់គាត់ដើរតាមគន្លង និងខិតខំរៀនសូត្រ។ ម្យ៉ាងវិញទៀត មាតាបិតាមិនត្រូវបង្អាក់ទឹកចិត្ត មិនឲ្យកូនទទួលបានការសិក្សាខ្ពង់ខ្ពស់ និងបង្ខំឲ្យកូនស្រីរៀបអាពាហ៍ពិពាហ៍នៅក្នុងវ័យក្មេងពេកនោះទេ។

### ២.៣.៣. សង្គម

ដើម្បីចូលរួមលើកទឹកចិត្តឲ្យស្ត្រីទទួលបានការអប់រំ សង្គមក៏មានតួនាទីដ៏សំខាន់ផងដែរ ក្នុងការ

ជម្រុញឲ្យស្ត្រីទទួលបានការអប់រំខ្ពស់ ដោយសង្គមអាចចូលរួមផ្សព្វផ្សាយយ៉ាងទូលំទូលាយអំពីសារៈសំខាន់នៃការអប់រំដល់ប្រជាជនឲ្យពួកគាត់បានដឹងគ្រប់ៗគ្នា។ សង្គមក៏អាចលើកទឹកចិត្តឲ្យស្ត្រីបានចូលរួមរាល់សកម្មភាពនានាដែលទាក់ទងនឹងការអប់រំ និងធ្វើឲ្យមានសមភាពយេនឌ័រនៅក្នុងវិស័យអប់រំទាំងមូល បញ្ឈប់ការរើសអើងពូជសាសន៍ បញ្ឈប់អំពើហិង្សាលើស្ត្រី និងលើកទឹកចិត្តឲ្យស្ត្រីអាចចូលរួមបញ្ចេញមតិជាដើម។

### ២.៣.៤. រាជរដ្ឋាភិបាល

ប្រទេសកម្ពុជាត្រូវការធនធានមនុស្សជាច្រើនដើម្បីចូលរួមអភិវឌ្ឍប្រទេស។ ជាក់ស្តែងរាជរដ្ឋាភិបាលកម្ពុជាបានកំណត់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ ២០១៩-២០២៣ ដែលក្នុងជំពូកទី ៤ ចំណុច ៤.៩ បានកឡើងអំពីលើការបញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ ដែលសំដៅដល់ការកាត់បន្ថយគម្លាតយេនឌ័រនៅក្នុងវិស័យអប់រំ តាមរយៈគម្រោងនៃកម្មវិធីអប់រំដែលមានដូចជា ការផ្តល់សេវាអប់រំ និងការគ្រប់គ្រងដឹកនាំដោយផ្តោតលើការយកចិត្តទុកដាក់ និងធានាឲ្យកុមារា និងកុមារី ទទួលបានលទ្ធភាពចូលរៀនដោយពេញលេញ និងស្មើភាពគ្នាជាដើម។

# ជំពូកទី ៣
# ការវិភាគលើលទ្ធផល
# ស្រាវជ្រាវ

# ជំពូកទី ៣

# ការវិភាគលើលទ្ធផលស្រាវជ្រាវ

នៅក្នុងជំពូកនេះ យើងនឹងធ្វើការវិភាគទៅលើលទ្ធផលស្រាវជ្រាវ ដែលបានមកពីការធ្វើកម្រងសំណួរសម្រង់ស្ថិតិពីស្ត្រីចំនួន ៥០នាក់ ដែលបម្រើការងារនៅតាមស្ថាប័ននានា និងស្ត្រីចំនួន ៥០នាក់ទៀត ដែលបម្រើការងារក្នុងរោងចក្រកាត់ដេរនៅក្នុងរាជធានីភ្នំពេញ ពោលគឺមានស្ត្រីសរុបទាំងអស់ចំនួន១០០នាក់ ដែលត្រូវបានជ្រើសរើសយកមកវិភាគ ក្នុងការលើកកម្ពស់សេដ្ឋកិច្ចគ្រួសារតាមរយៈការអប់រំរបស់ពួកគាត់។ នៅក្នុងការវិភាគនេះ យើងផ្តោតទៅលើចំនុចសំខាន់ៗមួយចំនួនដូចជា ស្ថានភាពទូទៅរបស់គាត់ដែលរួមមាន អាយុ ស្ថានភាពគ្រួសារ សមាជិកគ្រួសារ កម្រិតនៃការសិក្សា មុខរបរនិងមុខតំណែង កម្រិតនៃប្រាក់ចំណូលជាមធ្យមដែលគាត់ទទួលបាន សារៈសំខាន់នៃការអប់រំរបស់គាត់ ឥទ្ធិពលនៃការអប់រំទៅលើជីវភាពគ្រួសារ កត្តាដែលជំរុញឲ្យពួកគាត់ចូលរួមក្នុងការអប់រំ បញ្ហាប្រឈមដែលពួកគាត់ជួបប្រទះក្នុងការអប់រំ ភាគីដែលរួមចំណែកក្នុងការអប់រំរបស់ពួកគាត់ វិធានការក្នុងការលើកកម្ពស់ការអប់រំរបស់ពួកគាត់ បទពិសោធន៍របស់ពួកគាត់ផ្ទាល់ដើម្បីទទួលបានការអប់រំ និងចំណុចចុងក្រោយគឺទស្សនៈរបស់ពួកគាត់ក្នុងការលើកកម្ពស់សេដ្ឋកិច្ចគ្រួសារតាមរយៈការអប់រំ។

## ៣.១. ការវិភាគតាមបែបពិពណ៌នា

### ៣.១.១. ស្ថានភាពទូទៅនៃស្ត្រីបម្រើការងារនៅតាមស្ថាប័ននានា និងនៅក្នុងរោងចក្រកាត់ដេរនៅរាជធានីភ្នំពេញ

#### ៣.១.១.១. អាយុ

**តារាងទី១៖ អាយុ**

| ទិន្នន័យ | ចន្លោះពី ១៥ ទៅ ២០ ឆ្នាំ | ចន្លោះពី ២១ ទៅ ២៥ ឆ្នាំ | ចាប់ពី ២៦ ឆ្នាំឡើងទៅ |
|---|---|---|---|
| ស្ត្រីបម្រើការងារនៅតាមស្ថាប័ននានា | ១៧ នាក់ / ៣៣,៣% | ៣០នាក់ / ៦០,៨% | ៣នាក់ / ៥,៩% |
| ស្ត្រីបម្រើការងារនៅតាមរោងចក្រកាត់ដេរ | ០នាក់ / ០% | ២៦នាក់ / ៥២% | ២៤នាក់ / ៤៨% |

ប្រភព៖ ទិន្នន័យចម្បង

តាមចម្លើយដែលទទួលបានពីស្ត្រីដែលបម្រើការងារនៅតាមស្ថាប័ននានានៅក្នុងរាជធានីភ្នំពេញ យើងឃើញថា ស្ត្រីដែលមានអាយុចន្លោះពី ១៥ ទៅ ២០ ឆ្នាំ មានចំនួន១៧ នាក់ ដែលស្មើនឹង ៣៣,៣% នៃ

ចំនួនស្ត្រីទាំងអស់ ៥០នាក់។ ស្ត្រីដែលមានអាយុចន្លោះពី ២១ ទៅ ២៥ ឆ្នាំមានចំនួនច្រើនជាងគេរហូតទៅដល់ ៣០នាក់ ដែលស្មើនឹង ៦០,៨%។ ចំណែកឯស្ត្រីដែលមានអាយុចាប់ពី ២៦ ឆ្នាំឡើងទៅ មានចំនួន ៣ នាក់ ដែលស្មើនឹង ៥,៩%។

ម្យ៉ាងវិញទៀត បើតាមចម្លើយដែលទទួលបានពីស្ត្រីបម្រើការងារនៅក្នុងរោងចក្រវិញ ក្នុងចំណោមស្ត្រី ៥០នាក់ យើងឃើញថា មិនមានស្ត្រីដែលមានអាយុចន្លោះពី ១៥ ទៅ ២០ ឆ្នាំនោះទេ។ ឯស្ត្រីដែលមានអាយុចន្លោះពី ២១ ទៅ ២៥ ឆ្នាំ មានចំនួន ២៦នាក់ ដែលស្មើនឹង ៥២%។ ចំនួននេះមានភាពប្រហាក់ប្រហែលទៅនឹងស្ត្រីដែលមានអាយុចាប់ពី ២៦ ឆ្នាំឡើងទៅដែលមានចំនួន ២៤នាក់ ស្មើនឹង ៤៨% នៃចំនួនស្ត្រីសរុប។

នេះសបញ្ជាក់ឲ្យឃើញថាស្ត្រីដែលបានទទួលការអប់រំតាំងពីតូច អាចមានលទ្ធភាពធ្វើការងារនៅតាមស្ថាប័ននានា ដើម្បីរកប្រាក់ចំណូលផ្គត់ផ្គង់សេដ្ឋកិច្ចគ្រួសារបានឆាប់រហ័ស ឯស្ត្រីដែលទទួលបានការអប់រំទាប ចាប់ផ្តើមធ្វើការងារនៅអាយុច្រើនចាប់ពី ២១ឆ្នាំ ឡើងទៅ និងមានសមត្ថភាពធ្វើការងារតែនៅក្នុងរោងចក្រតែប៉ុណ្ណោះ។

### ៣.១.១.២. ស្ថានភាពគ្រួសារ

**តារាងទី ២៖ ស្ថានភាពគ្រួសារ**

| ទិន្នន័យ | នៅលីវ | មានគ្រួសារ | រស់នៅជាមួយឪពុកម្តាយ | ផ្សេងៗ |
|---|---|---|---|---|
| ស្ត្រីបម្រើការងារនៅតាមស្ថាប័ននានា | ៣៧នាក់ / ៧២,៥% | ២នាក់ / ៨% | ១១នាក់ / ២៣,៥% | ០នាក់ / ០% |
| ស្ត្រីបម្រើការងារនៅតាមរោងចក្រកាត់ដេរ | ១០នាក់ / ២០% | ៣៦នាក់ / ៧២% | ៤នាក់ / ៨% | ០នាក់ / ០% |

ប្រភព៖ ទិន្នន័យចម្បង

យោងតាមតារាងខាងលើ យើងឃើញថាស្ត្រីបម្រើការងារនៅតាមស្ថាប័ននានាមួយចំនួនធំ នៅលីវ ដែលមានចំនួនដល់ទៅ ៣៧នាក់ ស្មើនឹង ៧២,៥% នៃចំនួនស្ត្រីទាំងអស់ និងមួយចំនួនទៀតមាន ១១នាក់ ស្មើនឹង ២៣,៥% រស់នៅជាមួយឪពុកម្តាយរបស់ពួកគាត់។ ម្យ៉ាងវិញទៀត មានចំនួនស្ត្រីតែមួយភាគតូច ដែលមានចំនួន ២នាក់ ស្មើនឹង ៨% ប៉ុណ្ណោះដែលមានគ្រួសារ។

ចំណែកឯស្ត្រីដែលបម្រើការងារនៅក្នុងរោងចក្រ យើងឃើញថាភាគច្រើនជាស្ត្រីដែលមានគ្រួសាររួច ហើយដែលមានរហូតដល់ ៣៦ នាក់ ស្មើនឹង ៧២% នៃចំនួនស្ត្រីសរុប។ ចំណែកស្ត្រី ១០នាក់ ទៀតដែលស្មើ

នឹង ២០% នៅលីវមិនទាន់មានគ្រួសារ និងមានស្ត្រីតែ ៤នាក់ ស្មើនឹង ៨% ប៉ុណ្ណោះដែលរស់នៅជាមួយឪពុកម្តាយរបស់ពួកគាត់។

ចំពោះលទ្ធផលនេះយើងអាចសន្និដ្ឋានបានថា ស្ត្រីដែលទទួលបានចំណេះដឹង មិនរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេងពេកទេ ដោយសារពួកគាត់យល់ដឹងពីផលវិបាកនិងសិទ្ធិរបស់ពួកគាត់បានច្រើនជាងមុន។ ម្យ៉ាងវិញទៀត ស្ត្រីទាំងនោះទុកពេលវេលាសម្រាប់ធ្វើការ ឬប្រកបរបររកស៊ីឲ្យបានយូរ ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារនិងជួយសម្រាលបន្ទុកដល់ឪពុកម្តាយរបស់ពួកគាត់មុននឹងសម្រេចចិត្តរៀបអាពាហ៍ពិពាហ៍។ ចំណែកស្ត្រីដែលទទួលបានការអប់រំទាប ច្រើនតែត្រូវឪពុកម្តាយបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍តាំងពីពួកគាត់ទើបនឹងពេញក្រមុំភ្លាមៗម្ល៉េះ ដើម្បីសម្រាលបន្ទុករបស់គាត់ ព្រោះពេលរៀបអាពាហ៍ពិពាហ៍ហើយ ស្ត្រីត្រូវចេញទៅនៅគ្រួសារខាងប្តី ត្រូវរកស៊ីចិញ្ចឹមជីវិត និងគ្រប់គ្រងគ្រួសារដោយខ្លួនឯង ដោយមិនស្ថិតនៅក្នុងបន្ទុករបស់ឪពុកម្តាយរបស់ពួកគាត់ទៀតឡើយ។

#### ៣.១.១.៣. សមាជិកគ្រួសារ

**តារាងទី ៣៖ សមាជិកគ្រួសារ**

| ទិន្នន័យ | ១នាក់ | ២នាក់ | ចន្លោះពី ៣ ទៅ ៥ នាក់ | ចាប់ពី ៦នាក់ ឡើងទៅ |
|---|---|---|---|---|
| ស្ត្រីបម្រើការងារនៅតាមស្ថាប័ននានា | ១នាក់ / ២% | ០នាក់ / ០% | ៣៩នាក់ / ៧៦,៥% | ១០នាក់ / ២១,៦% |
| ស្ត្រីបម្រើការងារនៅតាមរោងចក្រកាត់ដេរ | ១នាក់ / ២% | ២នាក់ / ៤% | ៣៨នាក់ / ៧៦% | ៩នាក់ / ១៨% |

ប្រភព៖ ទិន្នន័យចម្បង

តាមរយៈលទ្ធផលដែលទទួលបាន ចំនួនសមាជិកក្នុងគ្រួសាររបស់ស្ត្រីបម្រើការងារនៅតាមស្ថាប័ននានា និងស្ត្រីដែលបម្រើការងារក្នុងរោងចក្រកាត់ដេរ មានចំនួនប្រហាក់ប្រហែលគ្នា ដោយគ្រួសាររបស់ពួកគាត់មានសមាជិកភាគច្រើនចំនួនចន្លោះពី ៣ ទៅ ៥ នាក់ ដែលស្ត្រីបម្រើការងារនៅតាមស្ថាប័ននានាមាន ៣៩ នាក់ដែលត្រូវនឹង ៧៦.៥% និងស្ត្រីដែលបម្រើការងារក្នុងរោងចក្រកាត់ដេរមាន ៣៨ នាក់ ដែលត្រូវនឹង ៧៦% នៃចំនួនស្ត្រីសរុប។ ចំណែកស្ត្រីមួយចំនួនទៀតមានសមាជិកគ្រួសារចាប់ពី ៦ នាក់ឡើងទៅ ដែលមានប្រហែលពី ១៨% ទៅ ២១% និងស្ត្រីមួយចំនួនតូចមានសមាជិកគ្រួសារពី ១ នាក់ ទៅ ២ នាក់ ដែលស្មើនឹង ២% ទៅ ៤% នៃចំនួនស្ត្រីបម្រើការងារនៅក្នុងស្ថាប័នទាំងពីរ។

នេះសបញ្ជាក់ឲ្យឃើញថា ស្ត្រីក្នុងពេលបច្ចុប្បន្នយល់ដឹងបានច្រើនអំពីការពន្យាកំណើត និងការកាត់បន្ថយសមាជិកក្នុងក្រុមគ្រួសារ ដើម្បីឲ្យពួកគាត់មានពេលវេលាគ្រប់គ្រាន់ក្នុងការរកស៊ីចិញ្ចឹមជីវិត និងធ្វើការងារដើម្បីជួយផ្គត់ផ្គង់ជីវភាពគ្រួសាររបស់ពួកគាត់ឲ្យកាន់តែប្រសើរឡើង។

### ៣.១.១.៤. កម្រិតនៃការសិក្សា

**តារាងទី៤៖ កម្រិតនៃការសិក្សា**

| ទិន្នន័យ | មិនធ្លាប់ទទួលបានការសិក្សា | បឋមសិក្សា | អនុវិទ្យាល័យ | វិទ្យាល័យ | ថ្នាក់បរិញ្ញាបត្រ | អនុបណ្ឌិត | បណ្ឌិត | ជំនាញកាត់ដេរ |
|---|---|---|---|---|---|---|---|---|
| ស្ត្រីបម្រើការងារនៅតាមស្ថាប័ននានា | ០នាក់ / 0% | ០នាក់ / 0% | ០នាក់ / 0% | ៧នាក់ / ៧,៨% | ៤៦នាក់ / ៩០,២% | ១នាក់ / ២% | ០នាក់ / 0% | ០នាក់ / 0% |
| ស្ត្រីបម្រើការងារនៅតាមរោងចក្រកាត់ដេរ | ៤នាក់ / ៨% | ១៤នាក់ / ២៨% | ២០នាក់ / ៤0% | ១២នាក់ / ២៤% | ០នាក់ / 0% | ០នាក់ / 0% | ០នាក់ / 0% | ០នាក់ / 0% |

ប្រភព៖ ទិន្នន័យចម្បង

លទ្ធផលពីការសម្រង់មតិបានបង្ហាញឲ្យឃើញថា កម្រិតនៃការសិក្សារវាងស្ត្រីនៅក្នុងស្ថាប័នទាំងពីរមានភាពខុសគ្នាខ្លាំង ដោយស្ត្រីបម្រើការងារតាមស្ថាប័ននានាស្ទើរតែទាំងអស់ ទទួលបានការសិក្សាដល់កម្រិតបរិញ្ញាបត្រ ដែលមានចំនួន ៤៦ នាក់ ស្មើនឹង ៩០,២% នៃចំនួនស្ត្រីទាំង ៥០ នាក់ដែលត្រូវបានស្រង់មតិ ហើយមានចំនួនស្ត្រីតែ ៧ នាក់ ស្មើនឹង ៧,៨% ប៉ុណ្ណោះដែលកំពុងសិក្សានៅកម្រិតវិទ្យាល័យ។ គួរឲ្យកត់សម្គាល់ផងដែរថា ស្ត្រីចំនួន ១ នាក់ ស្មើនឹង ២% ទទួលបានការសិក្សារហូតដល់កម្រិតអនុបណ្ឌិត។

ចំពោះស្ត្រីបម្រើការងារនៅក្នុងរោងចក្រវិញ យើងឃើញថាស្ត្រីមួយចំនួនធំបានទទួលការសិក្សាត្រឹមកម្រិតអនុវិទ្យាល័យប៉ុណ្ណោះ ដែលមានរហូតដល់ ២០ នាក់ (៤០%)។ ចំណែកឯស្ត្រីដែលមានការសិក្សាដល់កម្រិតវិទ្យាល័យថយចុះស្ទើរតែស្មើនឹងពាក់កណ្តាលនៃកម្រិតអនុវិទ្យាល័យដែលមានចំនួន១២នាក់ (២៤%)។ យ៉ាងណាមិញ ស្ត្រីដែលទទួលបានការសិក្សាត្រឹមកម្រិតបឋមសិក្សាក៏មានចំនួនច្រើនផងដែរ គឺមាន១៤ នាក់

(២៨%) ហើយស្ត្រីដែលមិនធ្លាប់ទទួលបានការសិក្សាសោះមានចំនួន ៤ នាក់ ដែលស្មើនឹង ៨% នៃចំនួនស្ត្រីសរុប។

តាមរយៈលទ្ធផលនេះ សបញ្ជាក់យ៉ាងច្បាស់ពីភាពខុសគ្នារវាងស្ត្រីដែលបម្រើការងារនៅតាមស្ថាប័ននានា ជាមួយនឹងស្ត្រីដែលបម្រើការងារនៅតាមរោងចក្រ ដោយស្ត្រីបម្រើការងារនៅតាមស្ថាប័ននានាទទួលបានការអប់រំខ្ពស់ដោយសារតែពួកគាត់ខ្លួនឯងផ្ទាល់ ព្រមទាំងឪពុកម្ដាយរបស់ពួកគាត់យល់ដឹងបានច្រើនពីអត្ថប្រយោជន៍នៃការអប់រំរបស់កូនស្រីគាត់។ ចំណែកឯស្ត្រីបម្រើការងារនៅតាមរោងចក្រវិញ មិនទទួលបានការអប់រំឬទទួលបានការអប់រំទាប ដោយសារតែជីវភាពគ្រួសារក្រីក្រ និងមិនមានការលើកទឹកចិត្តពីឪពុកម្ដាយឲ្យបន្តការសិក្សាឲ្យបានខ្ពង់ខ្ពស់ដូចស្ត្រីឯទៀត។

### ៣.១.១.៥. មុខរបរនិងមុខតំណែងរបស់ស្ត្រី

**តារាងទី ៥៖ មុខរបរនិងមុខតំណែងរបស់ស្ត្រី**

| ទិន្នន័យ | កម្មការនីរោងចក្រ | បុគ្គលិកក្រុមហ៊ុន | មន្ត្រីរាជការ | អ្នករកស៊ី | ផ្សេងៗ |
|---|---|---|---|---|---|
| ស្ត្រីបម្រើការងារនៅតាមស្ថាប័ននានា | ០នាក់ / ០% | ២៣នាក់ / ៤៥,១% | ២នាក់ / ៣,៩% | ១នាក់ / ២% | ២៥នាក់ / ៤៩% |
| ស្ត្រីបម្រើការងារនៅតាមរោងចក្រកាត់ដេរ | ៥០នាក់ / ១០០% | ០នាក់ / ០% | ០នាក់ / ០% | ០នាក់ / ០% | ០នាក់ / ០% |

ប្រភព៖ ទិន្នន័យចម្បង

យោងតាមទិន្នន័យដែលបានមកពីការចុះសម្រង់មតិផ្ទាល់ ពីស្ត្រីដែលបម្រើការងារនៅក្នុងរោងចក្របានឲ្យដឹងថា ពួកគាត់មានតែមុខរបរមួយនេះឯង ពោលគឺធ្វើជាកម្មការនីរោងចក្រ ដើម្បីចិញ្ចឹមជីវិតនិងផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ។ ចំណែកឯមុខតំណែងដែលពួកគាត់ទទួលបាន គឺមិនមានអ្វីក្រៅតែពីធ្វើជាអ្នកស៊ីឈ្នួលដេរខោអាវឲ្យថៅកែរោងចក្រ ដើម្បីទទួលបានប្រាក់កម្រៃប្រចាំខែបន្តិចបន្តួច យកមកផ្គត់ផ្គង់បាយបីពេលឲ្យគ្រួសារ និងអាចឲ្យកូនរបស់គាត់បានទៅរៀនសូត្រក្រេបជញ្ជក់យកចំណេះវិជ្ជា ដើម្បីបានការងារល្អ មានប្រាក់ខែខ្ពស់ និងអាចមានជីវិតល្អប្រសើរជាងគាត់។

ចំណែកឯទិន្នន័យដែលបានមកពីការធ្វើសម្រង់ស្ថិតិតាមប្រព័ន្ធអ៊ីនធើណេត ពីស្ត្រីដែលបម្រើការងារនៅក្នុងស្ថាប័ននានានៅរាជធានីភ្នំពេញ ឃើញថាស្ត្រីភាគច្រើនមានមុខរបរជាបុគ្គលិកក្រុមហ៊ុន គឺមានចំនួន ២៣ នាក់ ដែលស្មើនឹង ៤៥,១% នៃចំនួនស្ត្រីសរុប ៥០ នាក់ ហើយមានចំនួនស្ត្រីមួយភាគតូច ស្មើនឹង ៥% ប្រកបរបរជាមន្ត្រីរាជការ និងអ្នករកស៊ី។ ម្យ៉ាងវិញទៀតស្ត្រីចំនួន ២៥ នាក់ ដែលស្មើនឹង ៤៩% នៃចំនួនស្ត្រី

ទាំងអស់ មានមុខតំណែងផ្សេងៗគ្នាដូចជាគណនេយ្យករ អ្នកបម្រើសេវាអតិថិជន គ្រូបង្រៀន វិស្វករ អ្នកធ្វើការក្នុងភោជនីយដ្ឋាន និងអ្នករចនាម៉ូតជាដើម។

លទ្ធផលនេះបញ្ជាក់ឲ្យឃើញថា ស្ត្រីដែលមានចំណេះដឹងខ្ពង់ខ្ពស់ដែលបម្រើការងារនៅតាមស្ថាប័ននានាអាចមានជម្រើសការងារច្រើន និងមានមុខតំណែងខ្ពស់ ជាងស្ត្រីដែលមានចំណេះដឹងតិចដែលមានសមត្ថភាពត្រឹមតែធ្វើការងារតូចទាប ដូចជាកម្មការនីរោងចក្រស៊ីឈ្នួលឲ្យគេដើម្បីរកប្រាក់បន្តិចបន្តួចចិញ្ចឹមជីវិត និងផ្គត់ផ្គង់គ្រួសារតែប៉ុណ្ណោះ។

### ៣.១.២. កម្រិតនៃប្រាក់ចំណូលជាមធ្យម

**តារាងទី ៦៖ កម្រិតនៃប្រាក់ចំណូលជាមធ្យម**

| ទិន្នន័យ | ១០០$ ទៅ ២០០$ | ២០១$ ទៅ ៣០០$ | ៣០១$ ទៅ ៤០០$ | ៤០១$ ទៅ ៥០០$ | ៥០១$ ឡើងទៅ |
|---|---|---|---|---|---|
| ស្ត្រីបម្រើការងារនៅតាមស្ថាប័ននានា | ១៦នាក់ / ៣៤% | ១៤នាក់ / ២៩,៨% | ៨នាក់ / ១៧% | ៥នាក់ / ១០,៦% | ៤នាក់ / ៨,៥% |
| ស្ត្រីបម្រើការងារនៅតាមរោងចក្រកាត់ដេរ | ៣៣នាក់ / ៦៦% | ១៥នាក់ / ៣០% | ២នាក់ / ៤% | ០នាក់ / ០% | ០នាក់ / ០% |

ប្រភព៖ ទិន្នន័យចម្បង

ទិន្នន័យតាមតារាងបានបញ្ជាក់ឲ្យឃើញថា ប្រាក់ចំណូលជាមធ្យមដែលស្ត្រីបម្រើការងារនៅតាមស្ថាប័ននានាទទួលបាន មានភាពប្រហាក់ប្រហែលគ្នា ពោលគឺស្ត្រីដែលទទួលបានប្រាក់ចំណូលចន្លោះពី ១០០$ ទៅ ២០០$ មានចំនួន ១៦ នាក់ ដែលស្មើនឹង ៣៤% នៃចំនួនស្ត្រីសរុប និងប្រាក់ចំណូលចន្លោះពី ២០១$ ទៅ ៣០០$ មានចំនួន ១៤ នាក់ ដែលស្មើនឹង ២៩,៨% នៃចំនួនស្ត្រីសរុប។ ស្ត្រីចំនួន ៨ នាក់ (១៧%) ទទួលបានប្រាក់ចំណូលចន្លោះពី ៣០១$ ទៅ ៤០០$ រីឯស្ត្រីចំនួន ៥ នាក់ (១០,៦%) ទទួលបានប្រាក់ចំណូលចន្លោះពី ៤០១$ ទៅ ៥០០$ និងស្ត្រីចំនួន ៤ នាក់ទៀត (៨,៥%) ទទួលបានប្រាក់ចំណូលរហូតទៅដល់ ៥០១$ ឡើងទៅ។

ចំពោះប្រាក់ចំណូលរបស់ស្ត្រីបម្រើការងារនៅក្នុងរោងចក្រវិញ យើងឃើញថាស្ត្រីមួយចំនួនធំទទួលបានប្រាក់ចំណូលត្រឹមតែចន្លោះពី ១០០$ ទៅ ២០០$ ប៉ុណ្ណោះ ដែលមានរហូតដល់ ៣៣ នាក់ ស្មើនឹង ៦៦% នៃចំនួនស្ត្រីទាំងអស់ ៥០ នាក់ និងស្ត្រីមួយចំនួនទៀតគឺ ១៥ នាក់ ស្មើនឹង ៣០% ទទួលបានប្រាក់

ចំណូលចន្លោះពី ២០១$ ទៅ ៣០០$។ យើងឃើញមានស្ត្រីតែ ២ នាក់ប៉ុណ្ណោះ ដែលអាចមានប្រាក់ចំណូលរហូតដល់ ៣០១$ ទៅ ៤០០$ ក្នុងមួយខែ។

លទ្ធផលនេះសបញ្ជាក់ឲ្យឃើញថា ស្ត្រីដែលទទួលបានការអប់រំខ្ពស់អាចមានលទ្ធភាពរកចំណូលបានច្រើនជាងស្ត្រីដែលទទួលបានការអប់រំទាប ពោលគឺស្ត្រីដែលទទួលបានការអប់រំខ្ពស់ មានចំណេះដឹងជ្រៅជ្រះអាចយកចំណេះទាំងនោះទៅប្រកួតប្រជែងនៅក្នុងទីផ្សារការងារ មានឱកាសបានឡើងតំណែង និងបង្កើនប្រាក់ចំណូលបានឆាប់រហ័ស។ ចំណែកឯស្ត្រីដែលមានការអប់រំទាប មិនសូវទទួលបានឱកាសការងារច្រើននោះទេ ហេតុដូច្នេះហើយទើបពួកគាត់រកប្រាក់ចំណូលបានតិច និងមិនអាចផ្គត់ផ្គង់ជីវភាពគ្រួសាររបស់ពួកគាត់បានគ្រប់គ្រាន់ឡើយ។

### ៣.១.៣. សារៈសំខាន់នៃការអប់រំរបស់ស្ត្រី

**តារាងទី ៧៖ សារៈសំខាន់នៃការអប់រំរបស់ស្ត្រី**

| ទិន្នន័យ | ទទួលបានឱកាសការងារ | ទទួលបានប្រាក់ចំណូល | អាចជួយផ្គត់ផ្គង់ជីវភាពគ្រួសារ | យល់ដឹងពីសិទ្ធិរបស់ខ្លួន | អាចចូលរួមការងារសង្គម | ផ្សេងៗ |
|---|---|---|---|---|---|---|
| ស្ត្រីបម្រើការងារនៅតាមស្ថាប័ននានា | ៣៨នាក់ / ៧៤,៥% | ៣៥នាក់ / ៦៨,៦% | ៣៥នាក់ / ៦៨,៦% | ៣៩នាក់ / ៧៦,៥% | ៤៣នាក់ / ៨៤,៣% | ១០នាក់ / ១៩,៦% |
| ស្ត្រីបម្រើការងារនៅតាមរោងចក្រកាត់ដេរ | ៤០នាក់ / ៨០% | ៤៣នាក់ / ៨៦% | ៣៨នាក់ / ៧៦% | ១០នាក់ / ២០% | ៦នាក់ / ១២% | ២នាក់ / ៤% |

ប្រភព៖ ទិន្នន័យចម្បង

តាមតារាងយើងឃើញថា ស្ត្រីដែលបម្រើការងារនៅតាមស្ថាប័ននានារហូតទៅដល់ ៤៣ នាក់ (៨៤,៣%) នៃចំនួនស្ត្រីសរុប យល់ថាការអប់រំធ្វើឲ្យស្ត្រីអាចចូលរួមក្នុងការងារសង្គមបានច្រើន ហើយស្ត្រីជិត ៤០ នាក់ ដែលស្មើនឹង ជិត ៨០% យល់ថាការអប់រំអាចឲ្យពួកគាត់យល់ដឹងពីសិទ្ធិរបស់ខ្លួន និងអាចទទួលបានឱកាសការងារច្រើនជាងមុន និងស្ត្រីចំនួន ៣៥ នាក់ទៀត (៦៨,៦%) យល់ថាការអប់រំជួយឲ្យពួកគាត់ទទួលបានប្រាក់ចំណូល និងអាចផ្គត់ផ្គង់ជីវភាពគ្រួសាររបស់ពួកគាត់បាន។

ចំណែកស្ត្រីដែលបម្រើការងារនៅក្នុងរោងចក្រកាត់ដេរវិញ មានចំនួនស្ត្រី ៤៣ នាក់ ដែលស្មើនឹង ៨៦% និងស្ត្រីចំនួន ៤០ នាក់ ស្មើនឹង ៨០% នៃចំនួនស្ត្រីសរុប ៥០ នាក់ ភាគច្រើនយល់ថាការអប់រំអាចឲ្យ

ពួកគាត់ទទួលបានប្រាក់ចំណូល និងមានឱកាសការងារច្រើនជាងមុន ព្រមទាំងស្ត្រីចំនួន ៣៨ នាក់ ស្មើនឹង ៧៦% យល់ថាការអប់រំអាចឲ្យពួកគាត់ផ្គត់ផ្គង់ជីវភាពគ្រួសារបានគ្រប់គ្រាន់។ យើងឃើញមានចំនួនស្ត្រីមួយភាគតូចដែលស្មើនឹង ១២% ទៅ ២០% ប៉ុណ្ណោះដែលយល់ថាការអប់រំអាចឲ្យពួកគាត់យល់ដឹងពីសិទ្ធិរបស់ខ្លួន និងអាចចូលរួមក្នុងការងារសង្គមបានច្រើនជាងមុន។

បើតាមលទ្ធផលនេះ យើងអាចសន្និដ្ឋានបានថា ស្ត្រីដែលទទួលបានការអប់រំខ្ពស់ អាចយល់ដឹងបានច្រើនអំពីសារៈសំខាន់នៃការអប់រំហើយពួកគាត់យល់ថាការអប់រំអាចជំរុញឲ្យពួកគាត់ចូលរួមក្នុងការងារសង្គមដូចជាការផ្សព្វផ្សាយពីការលើកកម្ពស់ការអប់រំ ជាពិសេសការអប់រំរបស់ស្ត្រី ការលុបបំបាត់ភាពក្រីក្រ ការជួយក្នុងការអភិវឌ្ឍសហគមន៍ ជាពិសេសសហគមន៍ក្រីក្រជាដើម។ ម្យ៉ាងវិញទៀត ពួកគាត់អាចយល់ដឹងពីសិទ្ធិរបស់ខ្លួនបានច្រើនជាងមុន។ ចំណែកស្ត្រីដែលទទួលបានការអប់រំទាប ភាគច្រើនដឹងត្រឹមថា ការអប់រំអាចជួយឲ្យពួកគាត់ទទួលបានប្រាក់ចំណូល ឱកាសការងារ និងអាចផ្គត់ផ្គង់ជីវភាពគ្រួសាររបស់ពួកគាត់ប៉ុណ្ណោះដោយពួកគាត់មិនសូវយល់ដឹងពីការចូលរួមក្នុងការងារសង្គម និងយល់ដឹងពីសិទ្ធិរបស់ខ្លួនឡើយ។

### ៣.១.៤. ឥទ្ធិពលនៃការអប់រំទៅលើជីវភាពគ្រួសារ

**តារាងទី ៨៖ ឥទ្ធិពលនៃការអប់រំទៅលើជីវភាពគ្រួសារ**

| ទិន្នន័យ | ជះឥទ្ធិពល | មិនជះឥទ្ធិពលទេ | ជះឥទ្ធិពលខ្លះដែរ |
|---|---|---|---|
| ស្ត្រីបម្រើការងារនៅតាមស្ថាប័ននានា | ៣៦នាក់ / ៧០,៦% | ២នាក់ / ៣,៩% | ១៣នាក់ / ២៥,៥% |
| ស្ត្រីបម្រើការងារនៅតាមរោងចក្រកាត់ដេរ | ៤៦នាក់ / ៩២% | ៣នាក់ / ៦% | ១នាក់ / ២% |

ប្រភព៖ ទិន្នន័យចម្បង

តាមទិន្នន័យដែលទទួលបានពីការសម្រង់ស្ថិតិ បានបង្ហាញឲ្យឃើញថា ទាំងស្ត្រីដែលបម្រើការងារក្នុងស្ថាប័ននានា និងស្ត្រីដែលបម្រើការងារនៅក្នុងរោងចក្រកាត់ដេរ ភាគច្រើនសុទ្ធតែយល់ថា ការអប់រំជះឥទ្ធិពលដល់ជីវភាពគ្រួសាររបស់ពួកគាត់ ពោលគឺមានចំនួនស្ត្រីរហូតដល់ ៣៦នាក់ (៧០,៦%) នៅតាមស្ថាប័ននានា និង ៤៦នាក់ (៩២%) នៅក្នុងរោងចក្រកាត់ដេរ ហើយមានស្ត្រីមួយចំនួនក៏យល់ថា ការអប់រំជះឥទ្ធិពលខ្លះដែរទៅលើជីវភាពគ្រួសាររបស់ពួកគាត់ ដោយនៅតាមស្ថាប័ននានាមានស្ត្រីចំនួន ១៣នាក់ (២៥,៥%) និង

នៅតាមរោងចក្រមានស្ត្រីតែ១នាក់ (២%) ប៉ុណ្ណោះ។ ផ្ទុយទៅវិញមានចំនួនស្ត្រីភាគតិច ប្រហែលជា ២ ទៅ ៣ នាក់ ដែលស្មើនឹង ៣,៩% ទៅ ៦% ប៉ុណ្ណោះ ដែលយល់ថាការអប់រំមិនជះឥទ្ធិពលទាល់តែសោះទៅលើជីវភាពគ្រួសាររបស់ពួកគាត់។

នេះសបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ថា ស្ត្រីភាគច្រើនបានដឹងថាការអប់រំបានជះឥទ្ធិពលយ៉ាងខ្លាំងទៅដល់ជីវភាពគ្រួសាររបស់ពួកគាត់។ ហេតុដូច្នេះហើយទើបពួកគាត់ប្រឹងប្រែងធ្វើការងារ ដើម្បីរកប្រាក់ចំណូលផ្គត់ផ្គង់ឲ្យកូនរបស់ពួកគាត់ទទួលបានការសិក្សារៀនសូត្រពេញលេញ ព្រោះពួកគាត់សង្ឃឹមថា កូនរបស់គាត់នឹងមានលទ្ធភាពរកប្រាក់ចំណូលបានច្រើន ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសាររបស់ពួកគាត់ទៅថ្ងៃអនាគតឲ្យបានប្រសើរជាងនៅជំនាន់របស់គាត់ ដែលមិនមានលទ្ធភាព និងមិនមានការគាំទ្រពីឪពុកម្ដាយឲ្យទទួលបានការអប់រំខ្ពង់ខ្ពស់ដូចស្ត្រីឯទៀតនោះឡើយ។

### ៣.១.៥. កត្តាដែលជំរុញឲ្យស្ត្រីចូលរួមក្នុងការអប់រំ

**តារាងទី ៩៖ កត្តាដែលជំរុញឲ្យស្ត្រីចូលរួមក្នុងការអប់រំ**

| ទិន្នន័យ | ចង់បានជីវភាពប្រសើរ | ចង់ជួយក្រុមគ្រួសារ | ចង់ជួយសង្គម | ចង់ចូលរួមក្នុងឆាកនយោបាយ | ចង់ឲ្យសង្គមទទួលស្គាល់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ស្ត្រីបម្រើការងារនៅតាមស្ថាប័ននានា | ៤៦នាក់ / ៩០,២% | ៣៥នាក់ / ៦៨,៦% | ៣៧នាក់ / ៧២,៥% | ៦នាក់ / ១១,៥% | ២៨នាក់ / ៥៤,៩% | ៩នាក់ / ១៧,៦% |
| ស្ត្រីបម្រើការងារនៅតាមរោងចក្រកាត់ដេរ | ៤៣នាក់ / ៨៦% | ៤១នាក់ / ៨២% | ១៨នាក់ / ៣៦% | ៣នាក់ / ៦% | ៩នាក់ / ១៨% | ១នាក់ / ២% |

ប្រភព៖ ទិន្នន័យចម្បង

តាមចម្លើយដែលទទួលបានពីស្ត្រីបម្រើការងារនៅតាមស្ថាប័ននានា យើងឃើញថាស្ត្រីចំនួន ៤៦ នាក់ (៩០,២%) នៃស្ត្រីទាំងអស់ ដែលចូលរួមក្នុងការអប់រំ គឺដោយសារតែពួកគាត់ចង់បានជីវភាពល្អប្រសើរ ហើយស្ត្រីជិត ៤០ នាក់ទៀត ប្រហែលជា ៧០% ចង់ជួយក្រុមគ្រួសាររបស់ពួកគាត់ ព្រមទាំងចង់ចូលរួមក្នុងការជួយសង្គមផងដែរ និងមានស្ត្រីចំនួនជាង ៥០% ទៀត ចង់ឲ្យសង្គមទទួលស្គាល់និងឲ្យតម្លៃលើការអប់រំ

របស់ពួកគាត់។ រីឯស្ត្រីមួយភាគតូចដែលស្មើនឹងជិត ២០% ចង់មានឱកាសចូលរួមក្នុងឆាកនយោបាយ និងឱកាសផ្សេងៗទៀតជាដើម។

ចំពោះស្ត្រីបម្រើការងារក្នុងរោងចក្រកាត់ដេរវិញ ក៏យល់ឃើញប្រហាក់ប្រហែលគ្នាដែរ ដោយពួកគាត់យល់ថាកត្តាដែលជំរុញឲ្យពួកគាត់ចូលរួមក្នុងការអប់រំ គឺដោយសារតែពួកគាត់ភាគច្រើនចង់បានជីវភាពល្អប្រសើរជាងមុន ព្រមទាំងចង់ជួយក្រុមគ្រួសាររបស់គាត់ ដែលមានចំនួនស្ត្រី ៤១ នាក់ ទៅ ៤៣ នាក់ ដែលស្មើនឹង ៨២% ទៅ ៨៦% ដែលផ្តល់ចម្លើយដូច្នេះ។ ចំណែកស្ត្រី ១៨ នាក់ ដែលស្មើនឹង ៣៦% ចង់ជួយដល់សង្គម និងស្ត្រីចំនួន ៩ នាក់ទៀត ដែលស្មើនឹង ១៨% ចង់ឲ្យសង្គមទទួលស្គាល់។

ទិន្នន័យនេះអាចឲ្យយើងសន្និដ្ឋានបានថា ទាំងស្ត្រីដែលបម្រើការងារនៅតាមស្ថាប័ននានា និងស្ត្រីដែលបម្រើការងារក្នុងរោងចក្រកាត់ដេរ ភាគច្រើនយល់ថាការទទួលបានការអប់រំអាចឲ្យពួកគាត់មានជីវភាពប្រសើរឡើង និងអាចជួយផ្គត់ផ្គង់ជីវភាពក្នុងក្រុមគ្រួសាររបស់ពួកគាត់ឲ្យចាកចេញពីភាពក្រីក្រ ព្រមទាំងអាចរស់នៅក្នុងជីវិតដ៏សមរម្យមួយ។ ម្យ៉ាងវិញទៀត ពួកគាត់ចង់ឲ្យសង្គមទទួលស្គាល់ពីតម្លៃរបស់ពួកគាត់ ដោយផ្តល់សិទ្ធិឲ្យពួកគាត់ទទួលបានការងារធ្វើដូចបុរស និងលុបបំបាត់ការរើសអើងភេទ ព្រមទាំងឲ្យតម្លៃលើការងារ និងផ្តល់ប្រាក់ចំណូលសមរម្យឲ្យពួកគាត់ដូចទៅនឹងបុរសដែរ។

### ៣.១.៦. បញ្ហាប្រឈមដែលស្ត្រីជួបប្រទះក្នុងការអប់រំ

**តារាងទី ១០៖ បញ្ហាប្រឈមដែលស្ត្រីជួបប្រទះក្នុងការអប់រំ**

| ទិន្នន័យ | ខ្វះធនធានសិក្សា | សង្គមមិនសូវឲ្យតម្លៃ | មានពេលវេលាសម្រាកតិច | កន្លែងសិក្សាឆ្ងាយពីផ្ទះ (ឬកន្លែងធ្វើការ) | ជួបជុំគ្រួសារបានតិច | សុខភាពចុះខ្សោយ |
|---|---|---|---|---|---|---|
| ស្ត្រីបម្រើការងារនៅតាមស្ថាប័ននានា | ១២នាក់ / ២៣,៥% | ១៦នាក់ / ៣១,៤% | ២៧នាក់ / ៥២,៩% | ១៦នាក់ / ៣១,៤% | ២៤នាក់ / ៤៧,១% | ១៧នាក់ / ៣៣,៣% |
| ស្ត្រីបម្រើការងារនៅតាមរោងចក្រកាត់ដេរ | ៤២នាក់ / ៨៤% | ១៤នាក់ / ២៨% | ២៤នាក់ / ៤៨% | ២៦នាក់ / ៥២% | ២០នាក់ / ៤០% | ២នាក់ / ៤% |

ប្រភព៖ ទិន្នន័យចម្បង

ថ្វីត្បិតតែមានកត្តាជាច្រើនដែលជំរុញឲ្យស្ត្រីចង់ទទួលបានការអប់រំ ក៏ប៉ុន្តែពួកគាត់ក៏ជួបប្រទះនូវបញ្ហាមួយចំនួនក្នុងការអប់រំរបស់ពួកគាត់ផងដែរ។ ដោយយោងតាមទិន្នន័យដែលយើងទទួលបានពីស្ត្រីដែលបម្រើការងារនៅតាមស្ថាប័ននានាបានឲ្យដឹងថា ចំនួនស្ត្រីជាងពាក់កណ្ដាល ដែលមានចំនួន ២៧ នាក់ (៥២,៩%) មានពេលវេលាសម្រាកតិច និងស្ត្រីចំនួន ២៤ នាក់ (៤៧,១%) បានលើកឡើងថា ពួកគាត់មានពេលវេលាជួបជុំគ្រួសារបានតិច។ ចំណែកស្ត្រីចំនួន ១៦ និង ១៧ នាក់ទៀត ដែលស្មើនឹង ៣១,៤% និង ៣៣,៣% បានឲ្យដឹងថាកន្លែងសិក្សារបស់ពួកគាត់នៅឆ្ងាយពីផ្ទះ ឬកន្លែងធ្វើការ ហើយការអប់រំរបស់ពួកគាត់គឺមិនសូវត្រូវបានសង្គមឲ្យតម្លៃ និងពេលខ្លះសុខភាពរបស់ពួកគាត់មិនសូវអំណោយផល។ ម្យ៉ាងវិញទៀតមានចំនួនស្ត្រីមួយភាគតូច ដែលស្មើនឹង ១២ នាក់ (២៣,៥%) បានលើកឡើងថា ពេលខ្លះពួកគាត់ខ្វះខាតធនធានក្នុងការសិក្សា។

បើមើលទៅលើទិន្នន័យដែលទទួលបានពីស្ត្រីបម្រើការងារនៅក្នុងរោងចក្រវិញ យើងឃើញថាស្ត្រីដល់ទៅ ៤២ នាក់ ដែលស្មើនឹង ៨៤% នៃចំនួនស្ត្រីទាំងអស់ បានលើកឡើងថា ពួកគាត់ខ្វះខាតធនធានច្រើនក្នុងការសិក្សា ពីព្រោះពួកគាត់រស់នៅតំបន់ដាច់ស្រយាល និងតំបន់ក្រីក្រ ដូច្នេះហើយទើបមិនសូវទទួលបានការយកចិត្តទុកដាក់ និងផ្ដល់ការឧបត្ថម្ភនានាពីសំណាក់ភាគីពាក់ព័ន្ធនានា។ ស្ត្រីជាងពាក់កណ្ដាលទៀត ដែលស្មើនឹង ២០នាក់ (៤០%), ២៤ នាក់ (៤៨%), និង ២៦នាក់ (៥២%) បានឲ្យដឹងថាពួកគាត់មានពេលវេលាជួបជុំគ្រួសារបានតិច និងមានពេលវេលាសម្រាកតិច ហើយកន្លែងសិក្សារបស់ពួកគាត់ភាគច្រើននៅឆ្ងាយពីផ្ទះ ឬកន្លែងធ្វើការ។ ម្យ៉ាងវិញទៀត ស្ត្រីចំនួន ១៤ នាក់ ស្មើនឹង ២៨% យល់ថាបញ្ហាដែលពួកគាត់ជួបប្រទះគឺ សង្គមមិនសូវឲ្យតម្លៃទៅលើការសិក្សារបស់ពួកគាត់ឡើយ និងមានចំនួនស្ត្រីតែ ៤% ប៉ុណ្ណោះ ដែលយល់ថាបញ្ហាប្រឈមរបស់គាត់គឺសុខភាពចុះខ្សោយ។

តាមរយៈលទ្ធផលនេះ យើងអាចសន្និដ្ឋានបានថា ស្ត្រីបម្រើការងារនៅតាមស្ថាប័ននានាភាគច្រើនបញ្ហាដែលពួកគាត់ជួបប្រទះគឺពួកគាត់មានពេលវេលាសម្រាកបានតិច និងមានពេលជួបជុំគ្រួសារបានតិចដោយសារតែពួកគាត់បានចំណាយពេលវេលាមួយចំនួនធំទៅលើការសិក្សា ដើម្បីស្វែងរកចំណេះវិជ្ជាបន្ថែម និងដើម្បីអាចចូលរួមប្រកួតប្រជែងក្នុងទីផ្សារការងារ ទើបធ្វើឲ្យពួកគាត់នៅសេសសល់ពេលតិចសម្រាប់ខ្លួនឯងនិងគ្រួសារ។ ចំណែកស្ត្រី បម្រើការងារនៅក្នុងរោងចក្រវិញ បញ្ហាចម្បងដែលពួកគាត់ជួបប្រទះនោះគឺការខ្វះខាតធនធានក្នុងការសិក្សាពីព្រោះតែពួកគាត់មានជីវភាពក្រីក្រ និងមិនមានលទ្ធភាពទិញសម្ភារៈសិក្សាឲ្យបានគ្រប់គ្រាន់។ ម្យ៉ាងវិញទៀតពួកគាត់ច្រើនតែរស់នៅតំបន់ជនបទដាច់ស្រយាល ហេតុដូច្នេះហើយទើបមិនសូវទទួលបានការឧបត្ថម្ភនានាដើម្បីឲ្យពួកគាត់សិក្សារៀនសូត្របានពេញលេញ។

### ៣.១.៧. ភាគីដែលរួមចំណែកក្នុងការអប់រំរបស់ស្ត្រី

**តារាងទី ១១៖ ភាគីដែលរួមចំណែកក្នុងការអប់រំរបស់ស្ត្រី**

| ទិន្នន័យ | ស្ត្រីខ្លួនឯងផ្ទាល់ | ក្រុមគ្រួសាររបស់ស្ត្រី | សង្គម | រដ្ឋាភិបាល | អង្គការក្រៅរដ្ឋាភិបាល | ផ្សេងៗ |
|---|---|---|---|---|---|---|
| ស្ត្រីបម្រើការងារនៅតាមស្ថាប័ននានា | ៤៤នាក់ / ៨៦,៣% | ៤៤នាក់ / ៨៦,៣% | ៤១នាក់ / ៨០,៤% | ៣៣នាក់ / ៦៤,៧% | ២៦នាក់ / ៥១% | ១០នាក់ / ១៩,៦% |
| ស្ត្រីបម្រើការងារនៅតាមរោងចក្រកាត់ដេរ | ៤១នាក់ / ៨២% | ៤១នាក់ / ៨២% | ៨នាក់ / ១៦% | ៩នាក់ / ១៨% | ៤នាក់ / ៨% | ១នាក់ / ២% |

ប្រភព៖ ទិន្នន័យចម្បង

តាមទិន្នន័យដែលទទួលបាន យើងឃើញថាមានស្ត្រីដែលបម្រើការងារនៅតាមស្ថាប័ននានាមួយចំនួនធំដែលមានរហូតដល់ ៤១ ទៅ ៤៤ នាក់ ស្មើនឹង ៨០,៤% និង ៨៦,៣% យល់ថាភាគីដែលចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអប់រំរបស់ពួកគាត់ គឺជាពួកគាត់ខ្លួនឯងផ្ទាល់ ក្រុមគ្រួសាររបស់ពួកគាត់ និងសង្គមជាតិទាំងមូល។ ទន្ទឹមនឹងនេះ មានស្ត្រីចំនួន ៣៣ នាក់ ស្មើនឹង ៦៤,៧% និងស្ត្រីចំនួន ២៦ នាក់ ស្មើនឹង ៥១% យល់ថារដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលជាអ្នកដែលអាចចូលរួមចំណែកក្នុងការអប់រំរបស់ពួកគាត់បាន។

ចំណែកស្ត្រីបម្រើការងារនៅក្នុងរោងចក្រវិញ គឺមានស្ត្រីមួយភាគធំដែលមានចំនួនរហូតដល់ ៤១ នាក់ (៨២%) យល់ថាពួកគាត់ផ្ទាល់ និងក្រុមគ្រួសាររបស់ពួកគាត់ គឺជាភាគីសំខាន់ដែលអាចជំរុញឲ្យពួកគាត់ទទួលបានការអប់រំ។ គួរឲ្យកត់សម្គាល់ផងដែរថា មានតែចំនួនស្ត្រីមួយភាគតូចប៉ុណ្ណោះដែលយល់ថាសង្គម រាជរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ជាភាគីដែលរួមចំណែកក្នុងការអប់រំរបស់ពួកគាត់។

លទ្ធផលនេះ ធ្វើឲ្យយើងអាចសន្និដ្ឋានបានថា ទាំងស្ត្រីបម្រើការងារនៅតាមស្ថាប័ននានា និងស្ត្រីបម្រើការងារនៅក្នុងរោងចក្រ ភាគច្រើនសុទ្ធតែយល់ថាពួកគាត់ខ្លួនឯង និងក្រុមគ្រួសាររបស់ពួកគាត់គឺជាភាគីសំខាន់ក្នុងការលើកទឹកចិត្តឲ្យពួកគាត់ទទួលបានការអប់រំ ពីព្រោះថាបើស្ត្រីខ្លួនឯងមិនខិតខំប្រឹងប្រែងស្វែងរកចំណេះវិជ្ជា និងទាមទារសិទ្ធិក្នុងការអប់រំរបស់ខ្លួន ព្រមទាំងមានការជំរុញនិងគាំទ្រពីគ្រួសារឲ្យពួកគាត់សិក្សារៀនសូត្របានខ្ពង់ខ្ពស់ទេនោះ ស្ត្រីក៏មិនអាចទទួលបានចំណេះវិជ្ជាជ្រៅជ្រះបានឡើយ។ ម្យ៉ាងវិញទៀត ភាគី

ពាក់ព័ន្ធនានាដូចជាសង្គម រាជរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលជាដើម ក៏បានចូលរួមចំណែកយ៉ាងសកម្មក្នុងការលើកកម្ពស់ការអប់រំរបស់ស្ត្រីផងដែរ។

### ៣.១.៨. វិធានការក្នុងការលើកកម្ពស់ការអប់រំរបស់ស្ត្រី

**តារាងទី ១២៖ វិធានការក្នុងការលើកកម្ពស់ការអប់រំរបស់ស្ត្រី**

| ទិន្នន័យ | លុបបំបាត់ការរើសអើងស្ត្រី | ផ្តល់អាហារូបករណ៍ឲ្យស្ត្រីទទួលបានការសិក្សាពេញលេញ | ផ្សព្វផ្សាយពីសារៈសំខាន់នៃការអប់រំរបស់ស្ត្រី | ជំរុញឲ្យស្ត្រីចូលរួមបញ្ចេញមតិ | លើកកម្ពស់ឲ្យស្ត្រីទទួលបានការងារដូចបុរស | ផ្សេងៗ |
|---|---|---|---|---|---|---|
| ស្ត្រីបម្រើការងារនៅតាមស្ថាប័ននានា | ៤១នាក់ / ៨០,៤% | ៣៨នាក់ / ៧៤,៥% | ៣៦នាក់ / ៧០,៦% | ៣៤នាក់ / ៦៦,៧% | ៤៤នាក់ / ៨៦,៣% | ៩នាក់ / ១៧,៦% |
| ស្ត្រីបម្រើការងារនៅតាមរោងចក្រកាត់ដេរ | ៣៩នាក់ / ៧៨% | ២៨នាក់ / ៥៦% | ១៨នាក់ / ៣៦% | ២៣នាក់ / ៤៦% | ៣៩នាក់ / ៧៨% | ១នាក់ / ២% |

ប្រភព៖ ទិន្នន័យចម្បង

តាមតារាងខាងលើយើងឃើញថា ស្ត្រីដែលបម្រើការងារនៅតាមស្ថាប័ននានា មានចំនួនប្រហាក់ប្រហែលគ្នាដែលបានលើកឡើងពីវិធានការក្នុងការលើកកម្ពស់ការអប់រំរបស់ស្ត្រី ពោលគឺមានស្ត្រីចំនួន ៤៤ នាក់ (៨៦,៣%) យល់ថាការលើកកម្ពស់ឲ្យស្ត្រីទទួលបានការងារដូចបុរស គឺជាវិធានការចាំបាច់ដែលភាគីពាក់ព័ន្ធនានាត្រូវធ្វើ។ ស្រដៀងគ្នានេះដែរ ក៏មានស្ត្រីចំនួន ៣៨ នាក់ (៧៤,៥%) លើកឡើងអំពីវិធានការក្នុងការលុបបំបាត់ការរើសអើងស្ត្រីផងដែរ។ ចំណែកឯស្ត្រីចន្លោះពី ៣០ ទៅ ៤០ នាក់ទៀត ប្រហែលនឹង ៦០% ទៅ ៧០% នៃស្ត្រីទាំងអស់ យល់ថាវិធានការក្នុងការលើកកម្ពស់ការអប់រំរបស់ស្ត្រីមានដូចជា ការផ្តល់អាហារូបករណ៍ឲ្យស្ត្រីទទួលបានការសិក្សាពេញលេញ ការផ្សព្វផ្សាយពីសារៈសំខាន់នៃការអប់រំរបស់ស្ត្រី ព្រមទាំងការជំរុញឲ្យស្ត្រីចូលរួមបញ្ចេញមតិជាដើម។

ទន្ទឹមនឹងនេះ ចំពោះស្ត្រីដែលបម្រើការងារនៅក្នុងរោងចក្រ ក៏មានទស្សនៈស្រដៀងគ្នាដែរ ដោយស្ត្រីចំនួន ៣៩ នាក់ ដែលស្មើនឹង ៧៨% នៃចំនួនស្ត្រីសរុបយល់ថា ការលុបបំបាត់ការរើសអើងស្ត្រី និងការលើកកម្ពស់ឲ្យស្ត្រីទទួលបានការងារដូចបុរស គឺជាវិធានការចម្បងក្នុងការលើកកម្ពស់ការអប់រំរបស់ស្ត្រី។ ចំណែក

ស្ត្រីចំនួន ២៣ នាក់ (៤៦%) និង ២៨ នាក់ (៥៦%) ទៀត លើកឡើងថា ការផ្តល់អាហារូបករណ៍ឲ្យស្ត្រីទទួលបានការសិក្សាពេញលេញ និងការជំរុញឲ្យស្ត្រីចូលរួមបញ្ចេញមតិក៏ជាវិធានការចាំបាច់ដែរ។ ម្យ៉ាងវិញទៀត ស្ត្រីចំនួន ១៨ នាក់ ដែលស្មើនឹង ៣៦% យល់ថាការផ្សព្វផ្សាយពីសារៈសំខាន់នៃការអប់រំរបស់ស្ត្រី ក៏ជាវិធានការដែលភាគីពាក់ព័ន្ធត្រូវយកចិត្តទុកដាក់ផងដែរ។

ដូច្នេះតាមលទ្ធផលនេះ យើងអាចសន្និដ្ឋានបានថា វិធានការដែលសំខាន់បំផុត ដែលស្ត្រីគិតថាអាចលើកកម្ពស់ការអប់រំរបស់ពួកគាត់ឲ្យកាន់តែប្រសើរឡើងនោះគឺ ការលុបបំបាត់ការរើសអើងស្ត្រី និងការលើកកម្ពស់ឲ្យស្ត្រីទទួលបានការងារដូចបុរស ពីព្រោះថាបច្ចុប្បន្ននេះថ្វីត្បិតតែបញ្ហាដែលស្ត្រីជួបប្រទះ ត្រូវបានយកចិត្តទុកដាក់ច្រើនក៏ពិតមែន ក៏យើងនៅតែសង្កេតឃើញថានៅតំបន់មួយចំនួន ជាពិសេសតំបន់ជនបទដាច់ស្រយាល រូបភាពនៃការរើសអើងស្ត្រីគឺនៅតែកើតមានឡើង។ ដូច្នេះ ដើម្បីលើកកម្ពស់ឲ្យស្ត្រីទទួលបានការអប់រំកាន់តែខ្ពស់ យើងគួរតែរួមគ្នាផ្តល់តម្លៃឲ្យស្ត្រី និងចូលរួមទប់ស្កាត់ការរើសអើង និងការប្រើអំពើហិង្សានានាមកលើស្ត្រីជាដើម។

### ៣.១.៩. បទពិសោធន៍របស់ស្ត្រីផ្ទាល់ដើម្បីទទួលបានការអប់រំ

តាមរយៈចម្លើយដែលទទួលបានពីស្ត្រីទាំងអស់ បានឲ្យដឹងថា ចំពោះបទពិសោធន៍របស់ពួកគាត់ផ្ទាល់ដើម្បីទទួលបានការអប់រំគឺ៖

- ស្ត្រីខ្លួនឯងគួរតែប្រឹងប្រែងស្វែងរកចំណេះវិជ្ជាដោយខ្លួនឯង ពីព្រោះពួកគាត់គិតថា មានតែការខិតខំប្រឹងប្រែងរៀនសូត្រដោយខ្លួនឯងប៉ុណ្ណោះទេ ដែលអាចឲ្យពួកគាត់មានចំណេះវិជ្ជាជ្រៅជ្រះ អាចមានលទ្ធភាពរកប្រាក់ចំណូលមកជួយលើកកម្ពស់សេដ្ឋកិច្ចគ្រួសារតាមរយៈការប្រកបមុខរបរប្រចាំថ្ងៃ ដោយប្រើប្រាស់នូវចំណេះដឹងដែលគាត់បានសិក្សារៀនសូត្រកន្លងមក។
- គ្រួសាររបស់ស្ត្រីក៏គួរតែលើកទឹកចិត្តឲ្យស្ត្រីទទួលបានការអប់រំតាំងពីនៅក្មេងវ័យផងដែរ។ ឪពុកម្តាយមានតួនាទីផ្តល់ភាពកក់ក្តៅ និងផ្តល់ចំណេះដឹងដល់កូនៗ ដោយបញ្ជូនកូនៗរបស់ពួកគាត់ទៅសាលារៀននៅពេលដែលកូនរបស់ពួកគាត់គ្រប់អាយុចូលរៀន។ ម្យ៉ាងវិញទៀត ឪពុកម្តាយដែលរស់នៅតាមទីជនបទ គួរតែផ្លាស់ប្តូរទស្សនៈដែលមិនឲ្យតម្លៃទៅលើការសិក្សារបស់ស្ត្រី និងទស្សនៈដែលយល់ឃើញថា ការដែលស្ត្រីទទួលបានចំណេះដឹងគឺគ្មានប្រយោជន៍នោះទេ ពីព្រោះស្ត្រីគង់តែនឹងក្លាយជាមេផ្ទះ និងមើលថែកូនៗដដែលនាពេលអនាគត ដោយបែរមកគិតពីអត្ថប្រយោជន៍ដ៏ច្រើនលើសលប់ដែលពួកគាត់អាចទទួលបាន នៅពេលដែលពួកគាត់ផ្តល់ឱកាសឲ្យកូនស្រីរបស់គាត់សិក្សារៀនសូត្របានជ្រៅជ្រះ។

- ភាគីពាក់ព័ន្ធនានា ដូចជារាជរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល សង្គម និងសហគមន៍ជាដើម គួរតែផ្សព្វផ្សាយអំពីសារៈសំខាន់នៃការអប់រំដល់ស្ត្រី ព្រមទាំងផ្សព្វផ្សាយឲ្យស្ត្រីយល់ដឹងពីសមភាពយេនឌ័រ លុបបំបាត់ការរើសអើងគ្រប់ទម្រង់ទាំងអស់នៃការអប់រំរបស់ស្ត្រី ផ្តល់អាហារូបករណ៍ឲ្យស្ត្រីទទួលបានការសិក្សាពេញលេញ និងលើកទឹកចិត្តឲ្យស្ត្រីចូលរួមបញ្ចេញមតិ។ ម្យ៉ាងវិញទៀត រដ្ឋាភិបាលគឺតែសាងសង់សាលារៀនឲ្យបានគ្រប់គ្រាន់នៅតាមជនបទ និងតំបន់ដាច់ស្រយាល ព្រមទាំងផ្តល់នូវបរិស្ថានស្អាត និងសុវត្ថិភាពខ្ពស់នៅក្នុងសាលារៀន ដើម្បីធានាឲ្យស្ត្រី និងឪពុកម្តាយមានទំនុកចិត្តក្នុងការជំរុញឲ្យកូនបានទៅរៀនសូត្រ។

### ៣.១.១០. ទស្សនៈរបស់ស្ត្រីក្នុងការលើកកម្ពស់សេដ្ឋកិច្ចគ្រួសារតាមរយៈការអប់រំ

តាមទិន្នន័យដែលទទួលបានពីការធ្វើសម្រង់មតិពីស្ត្រីទាំងអស់ យើងឃើញថា ទស្សនៈរបស់ពួកគាត់ក្នុងការលើកកម្ពស់សេដ្ឋកិច្ចគ្រួសារតាមរយៈការអប់រំគឺ៖

- ស្ត្រីខ្លួនឯងផ្ទាល់អាចទទួលបានឱកាសការងារច្រើន និងរកប្រាក់ចំណូលបានច្រើនជាងមុន ដែលអាចឲ្យពួកគាត់មានលទ្ធភាពទិញសម្ភារៈចាំបាច់នានាសម្រាប់ជីវិតរស់នៅប្រចាំថ្ងៃបាន។ កាលណាស្ត្រីមានការអប់រំខ្ពស់ ពួកគាត់អាចទទួលបានមុខតំណែងខ្ពស់នៅតាមបណ្តាស្ថាប័ននានា ដែលនាំឲ្យពួកគាត់ទទួលបានប្រាក់ចំណូលច្រើន និងអាចរស់នៅក្នុងជីវភាពប្រសើរជាងមុនបានផងដែរ។ លើសពីនេះទៅទៀត កាលណាស្ត្រីទទួលបានការអប់រំ ស្ត្រីអាចយល់ដឹងពីតម្លៃ និងសិទ្ធិរបស់ខ្លួនឯងបានច្រើនជាងមុន ដោយពួកគាត់អាចគេចផុតពីភាពអយុត្តិធម៌ ដែលអាចកើតមាននៅក្នុងកន្លែងធ្វើការងាររបស់គាត់ ដូចជាការកេងប្រវ័ញ្ចកម្លាំងពលកម្ម អសមភាពនៃប្រាក់ចំណូល និងការរើសអើងជាដើម។
- ការទទួលបានចំណេះដឹងខ្ពង់ខ្ពស់ ក៏អាចជួយស្ត្រីឲ្យរកចំណូលបន្ថែមដើម្បីផ្គត់ផ្គង់គ្រួសាររបស់ពួកគាត់ឲ្យកាន់តែប្រសើរឡើងផងដែរ ដោយពួកគាត់អាចចែករំលែកបន្ទុកគ្រួសារជាមួយស្វាមីរបស់គាត់បានមួយចំណែក អាចមើលថែគ្រួសារ និងរៀបចំផែនការគ្រួសារបានច្បាស់លាស់ជាងមុន និងអាចឲ្យគ្រួសាររបស់គាត់រស់នៅក្នុងជីវភាពប្រសើរជាងមុន ព្រោះកាលណាគាត់មានចំណេះដឹង ពួកគាត់ចេះបែងចែកប្រាក់ចំណូលដែលពួកគាត់រកបានសម្រាប់ការចំណាយផ្សេងៗ ដូចជាការចំណាយទៅលើការហូបចុក ការថែទាំសុខភាព ការវិនិយោគ និងការសន្សំទុកជាដើម។ ម្យ៉ាងវិញទៀត ស្ត្រីអាចកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារបាន ដោយគាត់ចេះឲ្យតម្លៃទៅលើស្វាមី និងកូនៗរបស់គាត់ ចេះប្រើពាក្យសម្តីទន់ភ្លន់ សុភាពរាបសារ ចេះគិតគូរបានវែងឆ្ងាយ ទើបធ្វើឲ្យស្វាមីរបស់គាត់គោរពគាត់វិញ និងមិនប្រព្រឹត្តអំពើហិង្សាមកលើគាត់។
- បន្ថែមពីលើនេះទៀត កាលណាស្ត្រីមានចំណេះដឹង ពួកគាត់អាចចូលរួមកាត់បន្ថយភាពក្រីក្រនៅក្នុងសង្គម ដោយពួកគាត់អាចយល់ដឹងបានច្រើនជាងមុនពីបញ្ហាសុខភាពរបស់គាត់ផ្ទាល់ និងទារកក្នុងផ្ទៃរបស់

គាត់ យល់ដឹងពីការផ្តល់សារធាតុចិញ្ចឹមគ្រប់គ្រាន់ ដែលអាចជួយកាត់បន្ថយអត្រាមរណភាពរបស់មាតានិងទារក និងកាត់បន្ថយកង្វះអាហារូបត្ថម្ភជាដើម។ ក្រៅពីនេះ ចំណេះដឹងរបស់ស្ត្រីក៏អាចឲ្យពួកគាត់ប្រើប្រាស់ក្នុងការចូលរួមធ្វើការងារសង្គម ដូចជាការធ្វើការងារស្ម័គ្រចិត្តតាមបណ្តាអង្គការឬស្ថាប័ននានា ដែលធ្វើការទាក់ទងទៅនឹងការអប់រំរបស់កុមារ និងស្ត្រី ដើម្បីអភិវឌ្ឍប្រទេសនិងបង្កើនធនធានមនុស្សនៅក្នុងសង្គមឲ្យកាន់តែរីកចម្រើនឡើងផងដែរ។

# សេចក្តីសន្និដ្ឋាន
# និងអនុសាសន៍

# សេចក្ដីសន្និដ្ឋាន និងអនុសាសន៍

## ១. សេចក្ដីសន្និដ្ឋាន

ដោយយោងតាមលទ្ធផលដែលទទួលបានសរុប ពីការសម្រង់ស្ថិតិតាមប្រព័ន្ធអ៊ីនធើណេតពីស្ត្រីបម្រើការងារនៅក្នុងស្ថាប័ននានា និងការចុះសម្រង់ស្ថិតិដោយផ្ទាល់ពីស្ត្រីបម្រើការងារនៅក្នុងរោងចក្រកាត់ដេរនៅក្នុងរាជធានីនៅភ្នំពេញ យើងអាចសន្និដ្ឋានបានថា ទិន្នន័យទាំងពីរមានខ្លះស្រដៀងគ្នា ខ្លះខុសគ្នាបន្តិចបន្តួច និងខ្លះទៀតខុសគ្នាខ្លាំង។ ជាក់ស្ដែង ចំនុចស្រដៀងគ្នារវាងស្ត្រីបម្រើការងារក្នុងស្ថាប័នទាំងពីរ គឺនៅត្រង់សមាជិកគ្រួសាររបស់ពួកគាត់ ដោយពួកគាត់មានសមាជិកគ្រួសារជាមធ្យមចន្លោះពី ៣ ទៅ ៥ នាក់ដូចគ្នា។ ម្យ៉ាងវិញទៀត ពួកគាត់សុទ្ធតែយល់ថាការអប់រំអាចជួយឲ្យពួកគាត់ទទួលបានឱកាសការងារច្រើន ទទួលបានប្រាក់ចំណូលសមរម្យ និងអាចផ្គត់ផ្គង់ជីវភាពគ្រួសាររបស់ពួកគាត់ឲ្យកាន់តែប្រសើរឡើង។ ទន្ទឹមនឹងនេះ ពួកគាត់ក៏យល់ថា ការអប់រំបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ជីវភាពគ្រួសាររបស់ពួកគាត់ ដោយពួកគាត់អាចជួយក្រុមគ្រួសារឲ្យចាកផុតពីភាពក្រីក្រតាមរយៈការទទួលបានការងារសមរម្យធ្វើ។

លើសពីនេះទៅទៀត មានចំនុចខ្លះដែលខុសគ្នាបន្តិចបន្តួចរវាងទិន្នន័យទាំងពីរផងដែរ ដោយស្ត្រីដែលចូលរួមក្នុងទីផ្សារការងារដើម្បីជួយលើកស្ទួយជីវភាពគ្រួសារ ភាគច្រើនមានអាយុចន្លោះពី ២១ ទៅ ២៥ ឆ្នាំដូចគ្នា ប៉ុន្តែទិន្នន័យនេះខុសគ្នាត្រង់ថា ស្ត្រីបម្រើការងារតាមស្ថាប័ននានា ចាប់ផ្ដើមធ្វើការងារតាំងពីពួកគាត់មានអាយុចន្លោះពី ១៥ ទៅ ២០ ឆ្នាំមកម្ល៉េះ ពោលគឺពួកគាត់បានចូលប្រលូកក្នុងវិស័យការងារលឿនជាងស្ត្រីបម្រើការងារនៅក្នុងរោងចក្រ ព្រោះពួកគាត់បានទទួលការអប់រំតាំងពីតូច ដូច្នេះហើយទើបពួកគាត់អាចមានសមត្ថភាពរកប្រាក់ចំណូលដើម្បីជួយសម្រាលបន្ទុកគ្រួសារបានតាំងពីនៅក្មេងវ័យ។ ដោយឡែកចំនុចដែលប្រហាក់ប្រហែលគ្នាមួយទៀតគឺ កម្រិតនៃប្រាក់ចំណូលដែលពួកគាត់ទទួលបានជាមធ្យម ដោយភាគច្រើនពួកគាត់ទទួលបានប្រាក់ចំណូលចន្លោះពី ១០០$ ទៅ ៣០០$ ដូចគ្នា ប៉ុន្តែស្ត្រីបម្រើការងារនៅតាមស្ថាប័ននានាអាចមានលទ្ធភាពទទួលបានប្រាក់ចំណូលច្រើនជាងនេះទៅទៀត ដោយសារតែពួកគាត់ទទួលបានចំណេះវិជ្ជាច្រើនជាងស្ត្រីបម្រើការងារតាមរោងចក្រ។

គួរឲ្យកត់សម្គាល់ផងដែរថា មានចំនុចមួយចំនួនដែលស្ត្រីបម្រើការងារក្នុងស្ថាប័នទាំងពីរមានភាពខុសគ្នាខ្លាំង ពោលគឺត្រង់កម្រិតនៃការសិក្សារបស់ពួកគាត់ ដោយស្ត្រីបម្រើការងារក្នុងស្ថាប័ននានា ភាគច្រើនទទួលបានការអប់រំរហូតដល់កម្រិតបរិញ្ញាបត្រ ឯស្ត្រីបម្រើការងារនៅក្នុងរោងចក្រកាត់ដេរ ភាគច្រើនទទួលបានការសិក្សាត្រឹមកម្រិតបឋមសិក្សា ដល់កម្រិតវិទ្យាល័យតែប៉ុណ្ណោះ ដោយពួកគាត់មិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបន្តការសិក្សាឲ្យបានខ្ពង់ខ្ពស់ឡើយ។ ចំនុចដែលខុសគ្នាខ្លាំងមួយទៀត គឺត្រង់ស្ថានភាពគ្រួសារ

របស់ពួកគាត់ ដោយស្ត្រីបម្រើការងារនៅតាមស្ថាប័ននានា ភាគច្រើននៅលីវ និងខ្លះទៀតរស់នៅជាមួយគ្រួសាររបស់ពួកគាត់ ឯចំណែកស្ត្រីបម្រើការងារនៅក្នុងរោងចក្រ មួយចំនួនធំសុទ្ធតែមានគ្រួសារ។ មូលហេតុនេះគឺដោយសារតែស្ត្រីបម្រើការងារនៅតាមស្ថាប័ននានាទទួលបានចំណេះដឹងខ្ពង់ខ្ពស់ យល់ដឹងពីសិទ្ធិរបស់ខ្លួនបានច្រើន ទើបពួកគាត់មិនយល់ព្រមឲ្យឪពុកម្តាយរបស់ពួកគាត់បង្ខំឲ្យរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេងពេក ឯស្ត្រីបម្រើការងារនៅក្នុងរោងចក្រ មានចំណេះដឹងតិចតួច មិនបានយល់ដឹងពីបញ្ហាប្រឈម និងផលវិបាកនានាដែលអាចកើតមាន ទើបពួកគាត់ព្រមធ្វើតាមឪពុកម្តាយរបស់គាត់។

យោងតាមការបកស្រាយបង្ហាញខាងលើ យើងអាចសរុបសេចក្តីបានថា ការអប់រំពិតជាចូលរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់សេដ្ឋកិច្ចគ្រួសាររបស់ស្ត្រី ដោយអាចឲ្យពួកគាត់ទទួលបានឱកាសការងារ មានប្រាក់ចំណូល និងបង្កើននូវកម្រិតជីវភាពរបស់ពួកគាត់ និងគ្រួសារពិតប្រាកដមែន។

## ២. អនុសាសន៍

ថ្វីត្បិតតែការអប់រំរបស់ស្ត្រីបានជួយដល់ការលើកកម្ពស់សេដ្ឋកិច្ចគ្រួសាររបស់ពួកគាត់ក៏ពិតមាន ក៏ប៉ុន្តែ បន្ទាប់ពីការសិក្សាស្រាវជ្រាវ យើងនៅតែសង្កេតឃើញថា ពួកគាត់ទទួលរងនូវបញ្ហាប្រឈមមួយចំនួនក្នុងការសិក្សានិងការប្រកបការងាររបស់ពួកគាត់ដូចជា កង្វះខាតក្នុងការទទួលបានធនធានសិក្សា កន្លែងសិក្សាឆ្ងាយពីផ្ទះ សង្គមមិនសូវឲ្យតម្លៃ មានពេលវេលាសម្រាកតិច ជួបជុំគ្រួសារបានតិច និងសុខភាពចុះខ្សោយជាដើម។ ហេតុដូច្នេះហើយ ក្នុងនាមយើងខ្ញុំជាអ្នកសិក្សាស្រាវជ្រាវ សូមផ្តល់ជាអនុសាសន៍ និងសំណូមពរមួយចំនួនដល់រាជរដ្ឋាភិបាល ព្រមទាំងស្ថាប័នពាក់ព័ន្ធនានាឲ្យផ្តោតការយកចិត្តទុកដាក់ទៅលើការៈ

- ផ្សព្វផ្សាយពីសារៈសំខាន់នៃការអប់រំ ដល់ឪពុកម្តាយនៅតាមជនបទឲ្យពួកគាត់ផ្តល់ឱកាសឲ្យកូនស្រីរបស់ពួកគាត់បានសិក្សារៀនសូត្រស្វែងរកចំណេះវិជ្ជាឲ្យបានខ្ពង់ខ្ពស់។
- លើកកម្ពស់ការចុះឈ្មោះចូលរៀនរបស់កុមារី និងស្ត្រីនៅគ្រប់កម្រិតនៃការសិក្សាតាំងពីក្មេងវ័យទៅ។
- ផ្តល់នូវជំនួយផ្សេងៗដើម្បីឲ្យការសិក្សារបស់ស្ត្រីមានភាពងាយស្រួលជាងមុន ដូចជាផ្តល់នូវសម្ភារៈសិក្សា សាងសង់អាគារសិក្សា និងបណ្ណាល័យ ព្រមទាំងផ្តល់នូវអាហារូបករណ៍ដល់ស្ត្រី ជាពិសេសស្ត្រីនៅតាមតំបន់ជនបទដាច់ស្រយាល។
- លើកទឹកចិត្តឲ្យស្ត្រីទទួលបានប្រាក់ខែ និងលក្ខខណ្ឌការងារស្មើភាពគ្នាជាមួយនឹងបុរស ទោះជានៅក្នុងមុខតំណែងណាក៏ដោយ។

- បង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងការសិក្សាពីជំនាញបច្ចេកទេស និងវិជ្ជាជីវៈដែលពាក់ព័ន្ធនានានៅក្នុងកម្មវិធីអប់រំ និងបណ្តុះបណ្តាល ដើម្បីឲ្យពួកគាត់អាចមានលទ្ធភាពចូលរួមក្នុងទីផ្សារការងារនិងធានាថាស្ត្រីទទួលបានការបណ្តុះបណ្តាលដោយមិនមានការរើសអើង។
- លុបបំបាត់អំពើហិង្សានានានៅក្នុងគ្រួសារ និងបង្កើនសមភាពយេនឌ័រនៅក្នុងសង្គម។
- ផ្តល់នូវយន្តការដែលមានប្រសិទ្ធភាពក្នុងការលើកទឹកចិត្តឲ្យស្ត្រីស្វែងរកការអន្តរាគមចំពោះការរើសអើងគ្រប់រូបភាពនៅក្នុងបរិស្ថានការងាររបស់ពួកគាត់។
- បង្កើននូវឱកាសការងារសមរម្យសម្រាប់ស្ត្រីនៅក្នុងវិស័យនានា ដូចជាវិស័យកសិកម្ម ឧស្សាហកម្ម ផលិតកម្ម និងសេវាកម្ម ក៏ដូចជាការបង្កើននូវសហគ្រិនភាពរបស់ស្ត្រីផងដែរ។

ជាចុងក្រោយ យើងខ្ញុំទាំងពីរ សូមផ្តល់ជាសំណូមពរដល់សិស្សានុសិស្សដែលមានបំណងចង់សិក្សាស្រាវជ្រាវបន្តពីបញ្ហាទាក់ទងនឹងការលើកកម្ពស់សេដ្ឋកិច្ចគ្រួសារតាមរយៈការអប់រំរបស់ស្ត្រី ឲ្យផ្តោតការយកចិត្តទុកដាក់បន្ថែមចំពោះស្ត្រីដែលបម្រើការងារនៅតាមខេត្តក្រុងនានានៅក្នុងប្រទេសកម្ពុជា ពីព្រោះការសិក្សាស្រាវជ្រាវរបស់យើង គឺផ្តោតសំខាន់តែទៅលើស្ត្រីបម្រើការងារនៅក្នុងរាជធានីភ្នំពេញតែប៉ុណ្ណោះ។ ដូច្នេះទិន្នន័យដែលទទួលបានប្រហែលជាមិនអាចគ្រប់ជ្រុងជ្រោយនោះឡើយ។ ហេតុនេះហើយទើបយើងខ្ញុំលើកទឹកចិត្តឲ្យធ្វើការស្រាវជ្រាវបន្ថែម ដើម្បីលើកកម្ពស់ការអប់រំរបស់ស្ត្រីទាំងឡាយនៅក្នុងប្រទេសកម្ពុជាយើង និងដើម្បីចូលរួមអភិវឌ្ឍប្រទេសជាតិឲ្យកាន់តែរីកចម្រើនឡើងថែមទៀត៕

# ឯកសារយោង

# ឯកសារយោង

- **ឯកសារយោងជាភាសាខ្មែរ**


ក្រសួងអប់រំ យុវជន និងកីឡា *ផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច 2014-2018* https://drive.google.com/file/d/0B1ash2991v8FOXRUYkNLV0FDMGc/view (ចូលទស្សនាថ្ងៃទី ០៣ មិថុនា ២០២០)

ក្រសួងអប់រំយុវជន និង កីឡា *ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ២០១៥,* អាចរកបាននៅ http://www.moeys.gov.kh (ចូលទស្សនាថ្ងៃទី០៣ មិថុនា ២០២០)

ក្រសួងអប់រំយុវជន និងកីឡា *ស្ថិតិ និងសូចនាករអប់រំសាធារណៈឆ្នាំ ២០១៦-២០១៧*

ខ្លូត ធីតា (២០០៥) *ទំនាក់ទំនងសីលធម៌និងច្បាប់នៅក្នុងសង្គមខ្មែរ* ភ្នំពេញ

គឹម សេរី. ២០១៧. *ការបង្កើនប្រាក់ចំណូលបុគ្គលតាមរយៈការអប់រំ (២០១៧)* សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ. សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច

ឃីន សុខ (២០០៣) *កម្មវិធីប្រវត្តិសាស្រ្តខ្មែរ* ភ្នំពេញ

ច្បាប់ស្តីពីការអប់រំ រាជកិច្ច ទំព័រ ៩៨០២ មាត្រាទី៤

ឌី ខាំបូលី, *ប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)* របស់មជ្ឈមណ្ឌលឯកសារកម្ពុជា

ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ USAID *វិស័យអប់រំ និងការគាំពារកុមារ* (23 សីហា 2019),https://www.usaid.gov/km/cambodia/education (ចូលទស្សនាថ្ងៃទី៥ មិថុនា ២០២០)

បណ្ឌិត ឈុន ពហុ និង ងួន ហេង, *ប្រវត្តិសេដ្ឋកិច្ចនៃប្រទេសកម្ពុជា* បោះពុម្ពលើកទី២ ឆ្នាំ២០១៦

ភ្នំពេញប៉ុស្តិ៍, *ការព្រួយបារម្ភអំពីគម្លាតនៃប្រាក់ចំណូលរវាងយេនឌ័រ*, (១២ កុម្ភៈ ២០១៦) https://www.phnompenhpost.com/national/gender-wage-gap-daunting (ចូលទស្សនាថ្ងៃទី១០ មិថុនា ២០២០)

រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា, *ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣*, ទំព័រទី ២៥៧-២៥៩

លីម រិនដើ និង រឿន សុភា. ២០១៧. *ប្រសិទ្ធភាពនៃការអប់រំកំណើអង្គការដើម្បីភាពញញឹមនៃកុមារ (២០១៧)* សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ. សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច

វចនានុក្រម Oxford Learner's Dictionaries

វចនានុក្រមខ្មែរ ការផ្សាយរបស់ពុទ្ធសាសនាបណ្ឌិត្យ ព.ស ២៥១១ គ.ស ១៩៦៧

វ៉ាន់ វី (២០១២), *ការសិក្សាអប់រំនៅសម័យអាណានិគមបារាំង* ភ្នំពេញ: ភូមិស្រុកខ្មែរ

វិទ្យាស្ថានជាតិស្ថិតិនៅកម្ពុជា, *ការអង្កេតអំពីសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ ២០១៧* https://www.nis.gov.kh/nis/CSES/Final%20Report%20CSES%202017.pdf (ចូលទស្សនាថ្ងៃទី០៧ មិថុនា ២០២០)

វិទ្យុអាស៊ីសេរី, *ការអប់រំ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (៧១)* (២៦ មេសា ២០០៨)

សម្ព័ន្ធសហជីពកម្ពុជា, *ឧបសគ្គក្នុងការធ្វើការងាររោងចក្រ* http://thecatu.blogspot.com/ (ចូលទស្សនាថ្ងៃទី ១៨ មិថុនា ២០២០)

សារឌី, *សាធារណរដ្ឋប្រជាមានិតកម្ពុជា និង រដ្ឋកម្ពុជា (១៩៧៩-១៩៩៣)* ដោយខ្មែរដឹង, ដកស្រង់ពីគេហទំព័រ https://khmerdeng.com/khmer-public/

សូ អឿ (២០០៤) *ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាជាមួយប្រទេសអណ្ណាម និងប្រទេសសៀមក្រោយសតវត្សទី១៦*

សួស សាកល, *វិស័យអប់រំ សម័យកម្ពុជាប្រជាធិបតេយ្យ* (១៥ កញ្ញា ២០១៦)

*សេដ្ឋកិច្ច និងសេដ្ឋសាស្ត្រ,* ដកស្រង់ចេញពីគេហទំព័រ https://www.wikiwand.com/km (ចូលទស្សនាថ្ងៃទី ១១ មិថុនា ២០២០)

សៅ ឆាត (១៩៩៣) *ឯកសារប្រវត្តិសាស្ត្រវិបត្តិកម្ពុជា (១២ កក្កដា ២០១៨)* ភ្នំពេញ

- **ឯកសារយោងជាភាសាអង់គ្លេស**

AnnaMarie L. Sheldon, *Cambodia* https://education.stateuniversity.com/pages/225/Cambodia.html (ចូលទស្សនាថ្ងៃទី០៧ ឧសភា ២០២០)

CARE organization, *Factory workers in Cambodia,* www.care.org.au (ចូលទស្សនាថ្ងៃទី១៩ មិថុនា ២០២០)

Central Asia Institute (ស្ថាប័នអាស៊ីកណ្តាល) https://centralasiainstitute.org/ (ចូលទស្សនាថ្ងៃទី ១២ មិថុនា ២០២០)

Chey Elizabeth *THE STATUS OF KHMER WOMEN*, Mekong.net http://www.mekong.net/cambodia/women.htm (ចូលទស្សនាថ្ងៃទី១០ មិថុនា ២០២០)

CNV internationaal, *Our work where we work*, https://www.cnvinternationaal.nl/en/our-work/where-we-work/asia/cambodja (ចូលទស្សនាថ្ងៃទី ១៧ មិថុនា ២០២០)

Ebihara, May & Judy Ledgerwood, *Woman in Cambodia Society* http://www.seasite.niu.edu/khmer/ledgerwood/women.htm (ចូលទស្សនាថ្ងៃទី១២ មិថុនា ២០២០)

Jeffrey Hays, *FACTS AND DETAILS: EDUCATION AND SCHOOLS IN CAMBODIA* (May 2014) http://factsanddetails.com/southeast-asia/Cambodia (ចូលទស្សនាថ្ងៃទី០៥ ឧសភា ២០២០)

*Literacy and Education* ដកស្រង់ពី https://www.stat.go.jp/info/meetings/cambodia/pdf (ចូលទស្សនាថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២០)

*Review of Changes of Education Policy for Development in Cambodia from the 1860s to the 1960s*, https://www.researchgate.net/publication/331588169_Review_of_Changes_of_Education_Policy_for_Development_in_Cambodia_from_the_1860s_to_the_1980s (ចូលទស្សនាថ្ងៃទី០៦ មេសា ២០២០)

Sam Rany, Ahmad Nurulazam, Hazri Jamil (May 2012) *Cambodia's Higher Education Development in Historical Perspectives (1863-2012)* https://www.researchgate.net/publication/224777173_Cambodia's_Higher_Education_Development_in_Historical_Perspectives_1863-2012 (ចូលទស្សនាថ្ងៃទី០៤ មិថុនា ២០២០)

Sideth S. Dy, *Strategies and Policies for Basic Education in Cambodia: Historical Perspectives,*https://files.eric.ed.gov/fulltext/EJ903840.pdf (ចូលទស្សនាថ្ងៃទី១០ ឧសភា ២០២០)

Sokhan Khut, *The Education System in Cambodia* (១៨ មិនា ២០១៩)

UNESCO *Institute for Statistics* (ខែសីហា ឆ្នាំ២០១៦)

http://www.ibe.unesco.org/fileadmin/user_upload/archive/Countries/WDE/2006/ASIA_and_the_PACIFIC/Cambodia/Cambodia.htm (ចូលទស្សនាថ្ងៃទី០៤ មិថុនា ២០២០)

URSULA WEKEMANN, *Women in Cambodia*

https://core.ac.uk/download/pdf/154915211.pdf (ចូលទស្សនាថ្ងៃទី១២ មិថុនា ២០២០)

VOA, *Women's Garment Workers,* https://www.voacambodia.com/ (ចូលទស្សនាថ្ងៃទី១៧ មិថុនា ២០២០)

World bank, *Cambodia and World Bank Join Forces to Improve Higher Education and Connectivity*

https://www.worldbank.org/en/news/pressrelease/2018/07/12/cambodia-and-world-bank-join-forces-to-improve-higher-education-and-connectivity (ចូលទស្សនាថ្ងៃទី ០៥ មិថុនា ២០២០)

World Bank, *Girls' Education*

http://documents.worldbank.org/curated/en/924471541079772899/pdf/131634-BRI-girls-PUBLIC-Series-World-Bank-Education-Overview.pdf (ចូលទស្សនាថ្ងៃទី ១៤ មិថុនា ២០២០)

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១៖ កម្រងសំណួរ

## សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Royal University of Law and Economics

## កម្រងសំណួរស្រាវជ្រាវ

**ជាបឋមយើងខ្ញុំ សូមធ្វើគារវកិច្ចគោរព និងជម្រាបសួរដល់លោកស្រីទាំងអស់គ្នា ក្នុងឱកាសថ្ងៃនេះ យើងខ្ញុំសូមការអនុញ្ញាត ដើម្បីសួរនូវសំណួរស្រាវជ្រាវ**

កម្រងសំណួរនេះត្រូវបានរៀបរៀងឡើងដោយក្រុមនិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រោមប្រធានបទ «**ការលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ តាមរយៈការអប់រំរបស់ស្ត្រី**» ក្នុងគោលបំណងសិក្សាស្វែងយល់ អំពីព័ត៌មានដែលទាក់ទងទៅនឹងការសិក្សារបស់ស្ត្រី ដែលបម្រើការងារនៅក្នុងរាជធានីភ្នំពេញ។ យើងខ្ញុំសន្យាថា នឹងប្រើប្រាស់ព័ត៌មានដែលទទួលបានឲ្យបានត្រឹមត្រូវក្នុងបរិបទនៃការសិក្សា និងរក្សានូវការសំងាត់ជូនលោកស្រីទាំងអស់គ្នា។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចំណាយពេលវេលាដ៏មានតម្លៃរបស់លោកស្រី ក្នុងការបំពេញកម្រងសំណួរនេះដោយយកចិត្តទុកដាក់។

- ចូរគូសសញ្ញា √ នៅក្នុងប្រអប់ដែលអ្នកគិតថា ជាចម្លើយដែលត្រឹមត្រូវសម្រាប់អ្នក និងសូមអនុញ្ញាតឆ្លើយនូវសំណួរខាងក្រោម៖

១. អាយុ

☐ ចន្លោះពី ១៥ ទៅ ២០ ឆ្នាំ ☐ ចន្លោះពី ២១ ទៅ ២៥ ឆ្នាំ ☐ ចាប់ពី ២៦ ឆ្នាំឡើងទៅ

២. ស្ថានភាពគ្រួសារ

☐ នៅលីវ ☐ មានគ្រួសារ ☐ រស់នៅជាមួយឪពុកម្ដាយ ☐ ផ្សេងៗ

៣. តើគ្រួសាររបស់អ្នកមានសមាជិកប៉ុន្មាននាក់?

☐ ១ នាក់ ☐២ នាក់ ☐ចន្លោះពី ៣ ទៅ ៥ នាក់ ☐ចាប់ពី ៦ នាក់ឡើងទៅ

៤. កម្រិតនៃការសិក្សា

☐ មិនធ្លាប់ទទួលបានការសិក្សា ☐ បឋមសិក្សា ☐ អនុវិទ្យាល័យ

☐ វិទ្យាល័យ ☐ ថ្នាក់បរិញ្ញាបត្រ ☐ អនុបណ្ឌិត

☐ បណ្ឌិត ☐ ជំនាញកាត់ដេរ

៥. តើបច្ចុប្បន្ននេះ អ្នកប្រកបមុខរបរអ្វីដែរ?

☐ កម្មការនីរោងចក្រ ☐បុគ្គលិកក្រុមហ៊ុន ☐ មន្ត្រីរាជការ ☐អ្នករកស៊ី ☐ផ្សេងៗ

៦. តើសព្វថ្ងៃនេះ មុខតំណែងរបស់អ្នកជាអ្វី? ..................................................

(សម្រាប់បុគ្គលិកក្រុមហ៊ុន និងមន្ត្រីរាជការ)

៧. តើអ្នកទទួលបាននូវប្រាក់ចំណូល គិតជាមធ្យមប៉ុន្មានក្នុង១ខែ (គិតជាដុល្លារ)?

☐ ១០០$ ដល់ ២០០$ ☐ ២០១$ ដល់ ៣០០$ ☐ ៣០១$ ដល់ ៤០០$

☐ ៤០១$ ដល់ ៥០០$ ☐ ចាប់ពី ៥០១$ ឡើងទៅ

៨. តើប្រាក់ចំណូលរបស់អ្នក គ្រប់គ្រាន់ក្នុងការផ្គត់ផ្គង់ជីវភាពគ្រួសារដែរឬទេ?

☐ មិនគ្រប់គ្រាន់ ☐ គ្រប់គ្រាន់ ☐ គ្រប់ខ្លះមិនគ្រប់ខ្លះ

៩. តើអ្នកយល់ថា ស្ត្រីគួរតែទទួលបានការអប់រំដែរឬទេ?

☐ គួរ ☐ មិនគួរសោះ ☐ គួរតែទទួលបានខ្លះ

១០. តើមានមូលហេតុអ្វីខ្លះ បានជាអ្នកគិតថា ការអប់រំមានសារៈសំខាន់ចំពោះស្ត្រី?

(អាចជ្រើសរើសចម្លើយលើសពី ១)

☐ ទទួលបានឱកាសការងារ ☐ ទទួលបានប្រាក់ចំណូល ☐ អាចជួយផ្គត់ផ្គង់ជីវភាពគ្រួសារ

☐ យល់ដឹងពីសិទ្ធិរបស់ខ្លួន ☐ អាចចូលរួមការងារសង្គម ☐ ផ្សេងៗ

១១. តើអ្នកយល់ថា ការអប់រំរបស់អ្នកកន្លងមក ពិតជាបានជះឥទ្ធិពលទៅលើជីវភាពគ្រួសារដែរឬទេ?

☐ ជះឥទ្ធិពល ☐ មិនជះឥទ្ធិពលទេ ☐ ជះឥទ្ធិពលខ្លះដែរ

១២. ចំពោះអ្នកផ្ទាល់ តើកត្តាអ្វីខ្លះដែលបានជម្រុញឲ្យអ្នកចូលរួមក្នុងការអប់រំ?

(អាចជ្រើសរើសចម្លើយលើសពី ១)

☐ ចង់បានជីវភាពប្រសើរ ☐ ចង់ជួយក្រុមគ្រួសារ ☐ ចង់ជួយសង្គម

☐ ចង់ចូលរួមក្នុងនាកនយោបាយ ☐ ចង់ឲ្យសង្គមទទួលស្គាល់ ☐ ផ្សេងៗ

១៣. តើការសិក្សារបស់អ្នកផ្ទាល់ (ដែលជាស្ត្រីភេទ) បានជួបប្រទះនូវការលំបាកអ្វីខ្លះ?

(អាចជ្រើសរើសចម្លើយលើសពី ១)

☐ ខ្វះធនធានសិក្សា ☐ សង្គមមិនសូវឲ្យតម្លៃ ☐ មានពេលវេលាសម្រាកតិច

☐ កន្លែងសិក្សាឆ្ងាយពីផ្ទះ (ឬកន្លែងធ្វើការ) ☐ ជួបជុំគ្រួសារបានតិច ☐ សុខភាពចុះខ្សោយ

១៤. តើអ្នកដឹងទេថា ភាគីណាខ្លះ ដែលអាចចូលរួមចំណែកក្នុងការគាំទ្រឲ្យស្ត្រីទទួលបានការអប់រំ?(អាចជ្រើសរើសចម្លើយលើសពី ១)

☐ ស្ត្រីខ្លួនឯងផ្ទាល់ ☐ ក្រុមគ្រួសាររបស់ស្ត្រី ☐ សង្គម

☐ រដ្ឋាភិបាល ☐ អង្គការក្រៅរដ្ឋាភិបាល ☐ ផ្សេងៗ

១៥. តើសង្គមគួរតែមានវិធានការយ៉ាងណាខ្លះ ដើម្បីលើកកម្ពស់ការអប់រំរបស់ស្ត្រី?

(អាចជ្រើសរើសចម្លើយលើសពី ១)

☐ លុបបំបាត់ការរើសអើងស្ត្រី ☐ ផ្តល់អាហារូបករណ៍ឲ្យស្ត្រីទទួលបានការសិក្សាពេញលេញ

☐ ផ្សព្វផ្សាយពីសារៈសំខាន់នៃការអប់រំរបស់ស្ត្រី ☐ ជំរុញឲ្យស្ត្រីចូលរួមបញ្ចេញមតិ

☐ លើកកម្ពស់ឲ្យស្ត្រីទទួលបានការងារដូចបុរស ☐ ផ្សេងៗ

១៦. យោងតាមបទពិសោធន៍របស់អ្នកផ្ទាល់ តើគួរធ្វើដូចម្តេចខ្លះ ដើម្បីឲ្យស្ត្រីទទួលបាននូវការអប់រំ?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

១៧. បើតាមទស្សនៈរបស់អ្នក តើការអប់រំរបស់ស្ត្រី អាចជួយលើកកម្ពស់ដល់សេដ្ឋកិច្ចគ្រួសារយ៉ាងដូចម្តេចខ្លះ?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

សូមអរគុណ!

# ឧបសម្ព័ន្ធទី២៖ ការវិភាគតាមបែប SPSS



Female garment workers.sav [DataSet1] - IBM SPSS Statistics Data Editor

File Edit View Data Transform Analyze Direct Marketing Graphs Utilities Add-ons Window Help

| | Name | Type | Width | Decimals | Label | Values | Missing | Columns | Align | Measure | Role |
|---|---|---|---|---|---|---|---|---|---|---|---|
| 1 | Age | Numeric | 8 | 0 | | {1, [15-20]}... | None | 8 | Right | Scale | Input |
| 2 | Family_condition | Numeric | 8 | 0 | | {1, Single}... | None | 8 | Right | Nominal | Input |
| 3 | Family_members | Numeric | 8 | 0 | | {1, 1}... | None | 8 | Right | Scale | Input |
| 4 | Education | Numeric | 8 | 0 | | {1, never}... | None | 8 | Right | Nominal | Input |
| 5 | Occupation | Numeric | 8 | 0 | | {1, female g... | None | 8 | Right | Nominal | Input |
| 6 | Position | Numeric | 8 | 0 | | {1, female g... | None | 8 | Right | Nominal | Input |
| 7 | Income | Numeric | 8 | 0 | | {1, [100-200... | None | 8 | Right | Scale | Input |
| 8 | Income_enough_for_family_or_not | Numeric | 8 | 0 | | {1, not enou... | None | 8 | Right | Nominal | Input |
| 9 | Should_women_be_educated | Numeric | 8 | 0 | | {1, should}... | None | 8 | Right | Nominal | Input |
| 10 | Have_job_opportunities | Numeric | 8 | 0 | | {1, yes}... | None | 7 | Right | Nominal | Input |
| 11 | Have_income | Numeric | 8 | 0 | | {1, yes}... | None | 7 | Right | Nominal | Input |
| 12 | Support_family_economy | Numeric | 8 | 0 | | {1, yes}... | None | 7 | Right | Nominal | Input |
| 13 | Know_our_own_right | Numeric | 8 | 0 | | {1, yes}... | None | 7 | Right | Nominal | Input |
| 14 | Contribute_to_social_works | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 15 | Others_1 | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Scale | Input |
| 16 | Impact_of_edcuation_on_family_condition | Numeric | 8 | 0 | | {1, effect}... | None | 8 | Right | Nominal | Input |
| 17 | Want_better_standard_of_living | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 18 | Want_to_help_family | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 19 | Want_to_help_society | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 20 | Want_to_participate_in_politics | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 21 | Want_to_be_acknowledge_by_society | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 22 | Others_2 | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Scale | Input |
| 23 | Not_enough_study_resources | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 24 | Society_does_not_give_much_value | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |

Data View | Variable View

IBM SPSS Statistics Processor is ready | Unicode:ON



*Female garment workers.sav [DataSet1] - IBM SPSS Statistics Data Editor

File Edit View Data Transform Analyze Direct Marketing Graphs Utilities Add-ons Window Help

| | Name | Type | Width | Decimals | Label | Values | Missing | Columns | Align | Measure | Role |
|---|---|---|---|---|---|---|---|---|---|---|---|
| 25 | Have_little_time_to_relax | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 26 | School_far_away_from_home_or_workplace | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 27 | Have_little_time_with_family | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 28 | Have_poor_health_conditions | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 29 | Women_themselves | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 30 | Women_family | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 31 | Society | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 32 | Government | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 33 | Non_governmental_organization | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 34 | Others_3 | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Scale | Input |
| 35 | Eliminate_discrimination_against_women | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 36 | Provide_scholarships_to_women_to_get_full_education | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 37 | Promote_the_importance_of_women_education | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 38 | Encourage_women_to_share_their_perspectives | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 39 | Encourage_women_to_get_the_same_job_as_men | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 40 | Others_4 | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Scale | Input |
| 41 | Family_encouragement_to_get_education_since_she_was_young | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 42 | Women_themselves_desire_to_get_education | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 43 | Related_parties_encouragement | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 44 | Educate_women_about_gender_equality | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 45 | Promote_the_important_of_education_to_women | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 46 | Provide_scholarships_to_women | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 47 | Give_right_to_women_to_share_their_perspectives | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 48 | Change_perspectives_of_parents_living_in_rural_areas | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |

Data View | Variable View

IBM SPSS Statistics Processor is ready | Unicode:ON



*Female garment workers.sav [DataSet1] - IBM SPSS Statistics Data Editor

| | Name | Type | Width | Decimals | Label | Values | Missing | Columns | Align | Measure | Role |
|---|---|---|---|---|---|---|---|---|---|---|---|
| 49 | Eliminate_discrimination_in_all_forms_of_education | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 50 | Provide_clean_environment_and_security_at_school | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 51 | Build_enough_school_in_rural_area | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 52 | Women_knwow_how_to_care_of_their_family | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 53 | Women_know_how_to_prepare_family_planning | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 54 | Women_can_earn_more_icome_for_their_families | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 55 | Women_can_share_family_burden_wtih_her_husband | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 56 | Women_enough_money_to_buy_basic_needs_for_their_families | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 57 | Women_help_their_family_have_better_stadard_of_living | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 58 | Women_can_reduce_poverty | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 59 | Women_have_esteem | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 60 | Women_can_have_more_job_opportunities | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 61 | Women_contribute_to_social_work_to_develope_their_country | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 62 | Women_can_help_to_increase_human_resources | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 63 | Women_can_be_her_husband_advisors | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 64 | Women_can_reduce_violence_in_their_family | Numeric | 8 | 0 | | {1, yes}... | None | 8 | Right | Nominal | Input |
| 65 | | | | | | | | | | | |
| 66 | | | | | | | | | | | |
| 67 | | | | | | | | | | | |
| 68 | | | | | | | | | | | |
| 69 | | | | | | | | | | | |
| 70 | | | | | | | | | | | |
| 71 | | | | | | | | | | | |
| 72 | | | | | | | | | | | |

Data View | Variable View

IBM SPSS Statistics Processor is ready | Unicode:ON



*Female garment workers.sav [DataSet1] - IBM SPSS Statistics Data Editor

Visible: 64 of 64 Variables

| | Age | Family_condition | Family_members | Education | Occupation | Position | Income | Income_enough_for_family_or_not | Should_women_be_educated | Have_job_opportunities | Have_income | Support_family_economy | Know_our_own_right | Contribut_social_s |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | 2 | 3 | 3 | 3 | 1 | 1 | 1 | 1 | 1 | 2 | 1 | 1 | 2 | |
| 2 | 2 | 2 | 3 | 3 | 1 | 1 | 2 | 3 | 1 | 2 | 1 | 1 | 2 | |
| 3 | 2 | 2 | 4 | 2 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 2 | |
| 4 | 2 | 2 | 3 | 3 | 1 | 1 | 1 | 3 | 1 | 1 | 1 | 1 | 2 | |
| 5 | 2 | 2 | 3 | 4 | 1 | 1 | 2 | 3 | 1 | 1 | 1 | 2 | 2 | |
| 6 | 2 | 1 | 1 | 3 | 1 | 1 | 1 | 1 | 1 | 1 | 2 | 1 | 1 | |
| 7 | 2 | 2 | 2 | 2 | 1 | 1 | 1 | 3 | 1 | 2 | 1 | 1 | 1 | |
| 8 | 2 | 2 | 3 | 3 | 1 | 1 | 2 | 1 | 1 | 2 | 1 | 1 | 2 | |
| 9 | 2 | 2 | 4 | 2 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 2 | |
| 10 | 2 | 3 | 3 | 3 | 1 | 1 | 1 | 1 | 1 | 2 | 1 | 1 | 2 | |
| 11 | 3 | 2 | 3 | 3 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 2 | |
| 12 | 3 | 2 | 3 | 3 | 1 | 1 | 1 | 1 | 1 | 1 | 1 | 2 | 2 | |
| 13 | 2 | 2 | 3 | 4 | 1 | 1 | 2 | 3 | 1 | 1 | 1 | 2 | 1 | |
| 14 | 2 | 1 | 3 | 2 | 1 | 1 | 1 | 1 | 1 | 1 | 1 | 2 | 1 | |
| 15 | 2 | 1 | 3 | 4 | 1 | 1 | 2 | 1 | 1 | 1 | 1 | 1 | 2 | |
| 16 | 3 | 3 | 4 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 2 | |
| 17 | 2 | 2 | 3 | 3 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 2 | |
| 18 | 2 | 1 | 4 | 4 | 1 | 1 | 2 | 1 | 1 | 1 | 1 | 1 | 2 | |
| 19 | 2 | 1 | 3 | 3 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | |
| 20 | 2 | 2 | 3 | 1 | 1 | 1 | 2 | 1 | 1 | 1 | 1 | 2 | 2 | |
| 21 | 3 | 2 | 2 | 2 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 2 | |

Data View | Variable View

IBM SPSS Statistics Processor is ready | Unicode:ON

*Female garment workers.sav [DataSet1] - IBM SPSS Statistics Data Editor

File Edit View Data Transform Analyze Direct Marketing Graphs Utilities Add-ons Window Help

1 : Visible: 64 of 64 Variables

| | Age | Family_condition | Family_members | Education | Occupation | Position | Income | Income_enough_for_family_or_not | Should_women_be_educated | Have_job_opportunities | Have_income | Support_family_economy | Know_our_own_right | Contribut_social_s |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 22 | 3 | 2 | 4 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 2 | |
| 23 | 3 | 2 | 4 | 3 | 1 | 1 | 2 | 1 | 1 | 1 | 1 | 1 | 2 | |
| 24 | 3 | 2 | 3 | 3 | 1 | 1 | 3 | 1 | 1 | 1 | 1 | 2 | 2 | |
| 25 | 3 | 2 | 3 | 3 | 1 | 1 | 2 | 1 | 1 | 1 | 1 | 1 | 2 | |
| 26 | 2 | 1 | 4 | 4 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | |
| 27 | 3 | 2 | 3 | 3 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 2 | |
| 28 | 2 | 2 | 3 | 3 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 2 | |
| 29 | 3 | 2 | 3 | 4 | 1 | 1 | 1 | 1 | 1 | 1 | 2 | 2 | 1 | |
| 30 | 3 | 2 | 4 | 4 | 1 | 1 | 1 | 1 | 1 | 2 | 2 | 1 | 2 | |
| 31 | 3 | 2 | 3 | 2 | 1 | 1 | 1 | 1 | 1 | 1 | 1 | 2 | 2 | |
| 32 | 3 | 1 | 3 | 4 | 1 | 1 | 2 | 3 | 1 | 2 | 2 | 1 | 2 | |
| 33 | 3 | 2 | 3 | 3 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 2 | |
| 34 | 3 | 2 | 3 | 2 | 1 | 1 | 2 | 1 | 1 | 2 | 2 | 1 | 2 | |
| 35 | 2 | 2 | 3 | 2 | 1 | 1 | 3 | 3 | 1 | 1 | 2 | 2 | 2 | |
| 36 | 3 | 2 | 3 | 2 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 2 | |
| 37 | 3 | 2 | 3 | 2 | 1 | 1 | 2 | 1 | 1 | 1 | 1 | 1 | 2 | |
| 38 | 3 | 1 | 3 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 2 | |
| 39 | 3 | 1 | 3 | 4 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 2 | |
| 40 | 3 | 2 | 3 | 4 | 1 | 1 | 2 | 1 | 1 | 1 | 1 | 1 | 2 | |
| 41 | 3 | 2 | 3 | 3 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 2 | |
| 42 | 3 | 2 | 3 | 4 | 1 | 1 | 1 | 3 | 1 | 2 | 1 | 1 | 2 | |

Data View | Variable View

IBM SPSS Statistics Processor is ready | Unicode:ON

*Female garment workers.sav [DataSet1] - IBM SPSS Statistics Data Editor

File Edit View Data Transform Analyze Direct Marketing Graphs Utilities Add-ons Window Help

1 : Visible: 64 of 64 Variables

| | Age | Family_condition | Family_members | Education | Occupation | Position | Income | Income_enough_for_family_or_not | Should_women_be_educated | Have_job_opportunities | Have_income | Support_family_economy | Know_our_own_right | Contribut_social_s |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 40 | 3 | 2 | 3 | 4 | 1 | 1 | 2 | 1 | 1 | 1 | 1 | 1 | 2 | |
| 41 | 3 | 2 | 3 | 3 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 2 | |
| 42 | 3 | 2 | 3 | 4 | 1 | 1 | 1 | 3 | 1 | 2 | 1 | 1 | 2 | |
| 43 | 3 | 2 | 3 | 3 | 1 | 1 | 2 | 1 | 1 | 1 | 1 | 1 | 1 | |
| 44 | 2 | 1 | 3 | 3 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | |
| 45 | 2 | 3 | 4 | 2 | 1 | 1 | 1 | 3 | 1 | 1 | 1 | 1 | 2 | |
| 46 | 3 | 2 | 3 | 2 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 2 | |
| 47 | 2 | 2 | 3 | 3 | 1 | 1 | 1 | 1 | 1 | 1 | 1 | 2 | 2 | |
| 48 | 2 | 2 | 3 | 2 | 1 | 1 | 1 | 1 | 1 | 2 | 1 | 1 | 2 | |
| 49 | 2 | 2 | 3 | 4 | 1 | 1 | 2 | 1 | 1 | 1 | 1 | 2 | 2 | |
| 50 | 2 | 2 | 3 | 2 | 1 | 1 | 1 | 1 | 1 | 1 | 2 | 2 | 1 | |
| 51 | | | | | | | | | | | | | | |
| 52 | | | | | | | | | | | | | | |
| 53 | | | | | | | | | | | | | | |
| 54 | | | | | | | | | | | | | | |
| 55 | | | | | | | | | | | | | | |
| 56 | | | | | | | | | | | | | | |
| 57 | | | | | | | | | | | | | | |
| 58 | | | | | | | | | | | | | | |
| 59 | | | | | | | | | | | | | | |
| 60 | | | | | | | | | | | | | | |

Data View | Variable View

IBM SPSS Statistics Processor is ready | Unicode:ON

**Statistics**

| | | Age | Family condition | Family members | Education | Occupation | Position |
|---|---|---|---|---|---|---|---|
| N | Valid | 50 | 50 | 50 | 50 | 50 | 50 |
| | Missing | 0 | 0 | 0 | 0 | 0 | 0 |
| Mean | | 2.48 | 1.88 | 3.10 | 2.80 | 1.00 | 1.00 |
| Median | | 2.00 | 2.00 | 3.00 | 3.00 | 1.00 | 1.00 |
| Mode | | 2 | 2 | 3 | 3 | 1 | 1 |
| Sum | | 124 | 94 | 155 | 140 | 50 | 50 |

**Age**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | [21-25] | 26 | 52.0 | 52.0 | 52.0 |
| | [26-up] | 24 | 48.0 | 48.0 | 100.0 |
| | Total | 50 | 100.0 | 100.0 | |

**Family condition**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Single | 10 | 20.0 | 20.0 | 20.0 |
| | Married | 36 | 72.0 | 72.0 | 92.0 |
| | Live with parents | 4 | 8.0 | 8.0 | 100.0 |
| | Total | 50 | 100.0 | 100.0 | |

**Family_members**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | 1 | 1 | 2.0 | 2.0 | 2.0 |
| | 2 | 2 | 4.0 | 4.0 | 6.0 |
| | [3-5] | 38 | 76.0 | 76.0 | 82.0 |
| | [6-up] | 9 | 18.0 | 18.0 | 100.0 |
| | Total | 50 | 100.0 | 100.0 | |

**Education**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | never | 4 | 8.0 | 8.0 | 8.0 |
| | primary school | 14 | 28.0 | 28.0 | 36.0 |
| | lower secondary school | 20 | 40.0 | 40.0 | 76.0 |
| | upper secondary school | 12 | 24.0 | 24.0 | 100.0 |
| | Total | 50 | 100.0 | 100.0 | |

**Occupation**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | female garment worker | 50 | 100.0 | 100.0 | 100.0 |

**Position**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | female garment worker | 50 | 100.0 | 100.0 | 100.0 |

**Income**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | [100-200] | 33 | 66.0 | 66.0 | 66.0 |
| | [201-300] | 15 | 30.0 | 30.0 | 96.0 |
| | [301-400] | 2 | 4.0 | 4.0 | 100.0 |
| | Total | 50 | 100.0 | 100.0 | |

**Income_enough_for_family_or_not**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | not enough | 41 | 82.0 | 82.0 | 82.0 |
| | sometimes enough and sometimes not enough | 9 | 18.0 | 18.0 | 100.0 |
| | Total | 50 | 100.0 | 100.0 | |

**Should_women_be_educated**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | should | 50 | 100.0 | 100.0 | 100.0 |

**Important_of_women_education Frequencies**

| | | Responses | | Percent of Cases |
|---|---|---|---|---|
| | | N | Percent | |
| Important_of_women_education | Have_job_opportunities | 40 | 28.8% | 80.0% |
| | Have_income | 43 | 30.9% | 86.0% |
| | Support_family_economy | 38 | 27.3% | 76.0% |
| | Know_our_own_right | 10 | 7.2% | 20.0% |
| | Contribute_to_social_works | 6 | 4.3% | 12.0% |
| | Others_1 | 2 | 1.4% | 4.0% |
| Total | | 139 | 100.0% | 278.0% |

**Impact_of_edcuation_on_family_condition**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | effect | 46 | 92.0 | 92.0 | 92.0 |
| | no effect | 3 | 6.0 | 6.0 | 98.0 |
| | have some effect | 1 | 2.0 | 2.0 | 100.0 |
| | Total | 50 | 100.0 | 100.0 | |

**Factors_that_contribute_to_women_education Frequencies**

| | | Responses | | Percent of Cases |
|---|---|---|---|---|
| | | N | Percent | |
| Factors_that_contribute_to_women_education | Want_better_standard_of_living | 43 | 37.4% | 86.0% |
| | Want_to_help_family | 41 | 35.7% | 82.0% |
| | Want_to_help_society | 18 | 15.7% | 36.0% |
| | Want_to_participate_in_politics | 3 | 2.6% | 6.0% |
| | Want_to_be_acknowledge_by_society | 9 | 7.8% | 18.0% |
| | Others_2 | 1 | 0.9% | 2.0% |
| Total | | 115 | 100.0% | 230.0% |

**Obstacles_of_women_education Frequencies**

| | | Responses | | Percent of Cases |
|---|---|---|---|---|
| | | N | Percent | |
| Obstacles_of_women_education | Not_enough_study_resources | 42 | 32.8% | 84.0% |
| | Society_does_not_give_much_value | 14 | 10.9% | 28.0% |
| | Have_little_time_to_relax | 24 | 18.8% | 48.0% |
| | School_far_away_from_home_or_workplace | 26 | 20.3% | 52.0% |
| | Have_little_time_with_family | 20 | 15.6% | 40.0% |
| | Have_poor_health_conditions | 2 | 1.6% | 4.0% |
| Total | | 128 | 100.0% | 256.0% |

**Parties_contribute_to_women_education Frequencies**

| | | Responses | | Percent of Cases |
|---|---|---|---|---|
| | | N | Percent | |
| Parties_contribute_to_ women_education | Women_themselves | 41 | 39.4% | 82.0% |
| | Women_family | 41 | 39.4% | 82.0% |
| | Society | 8 | 7.7% | 16.0% |
| | Government | 9 | 8.7% | 18.0% |
| | Non_governmental_organization | 4 | 3.8% | 8.0% |
| | Others_3 | 1 | 1.0% | 2.0% |
| Total | | 104 | 100.0% | 208.0% |

**Strategies_to_enhance_women_education Frequencies**

| | | Responses | | Percent of Cases |
|---|---|---|---|---|
| | | N | Percent | |
| Strategies_to_enhance_ women_education | Eliminate_discrimination_ against_women | 39 | 26.5% | 78.0% |
| | Provide_scholarships_to_ women_to_get_full_education | 28 | 19.0% | 56.0% |
| | Promote_the_importance_of_ women_education | 18 | 12.2% | 36.0% |
| | Encourage_women_to_share_ their_perspectives | 23 | 15.6% | 46.0% |
| | Encourage_women_to_get_ the_same_job_as_men | 39 | 26.5% | 78.0% |
| Total | | 147 | 100.0% | 294.0% |